ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ថ្នាក់រៀនប្រវត្តិសាស្ត្រនៅអតីតគុកខ្មែរក្រហមមន្ទីរស-២១
- សវនាការអង្គបុរេជំនុំជម្រះ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៤៣ ខែវិច្ឆិកា ឆ្នាំ២០១១

# ស្វែងរកការពិត

លេខ១៤៣ ខែវិច្ឆិកា ឆ្នាំ២០១១

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ ថ្នាក់រៀនប្រវត្តិសាស្ត្រនៅអតីតគុកខ្មែរក្រហម ........................................១

**ផ្នែកឯកសារ**

◆ ចលនាលើកទំនប់កសិកម្ម ........................................................................៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ អតីតកម្មាភិបាលខ្មែរក្រហមនៅស្រុករវៀង ........................................៦

◆ បក់ សួង ៖ អនុវរសេនាតូចពិសេសនៃកងពល២០៧ ........................៩

◆ អ្នកទោសគុកភ្នំទ្រយោង ..........................................................................១១

◆ បាត់បង់ឪពុកក្នុងរបបខ្មែរក្រហម ..........................................................១៤

◆ ខ្ញុំដឹងពីសិទ្ធិរបស់ខ្ញុំក្នុងការនៅស្ងៀមមិនឆ្លើយតប ..............................២០

**ផ្នែកច្បាប់**

◆ សវនាការអង្គបុរេជំនុំជម្រះ ៖ សំណើបឋម ............................................២១

◆ ការលាលែងចេញពីតំណែងរបស់សហចៅក្រម ........................................៣០

**វេទិកាពិភាក្សាសាធារណៈ**

◆ ចៅក្រមស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុង. ................................៣៦

◆ ការពិនិត្យមើលសាឡើងវិញលើការចរចាឆ្ពោះទៅរកការ ........................៤២

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆រឿងរ៉ាវពិតរបស់ខ្ញុំ ...................................................................................៥៥

## អៀង ធីរិទ្ធ (រូបក្របក្រៅ)

នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ អៀង ធីរិទ្ធ ត្រូវចៅក្រមរបស់អង្គជំនុំជម្រះសាលាក្តីខ្មែរក្រហមសម្រេចថាមិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងដំណើរការកាត់ទោសទេ។ សេចក្តីសម្រេចនេះធ្វើឡើងរយៈពេលបីថ្ងៃមុននឹងសវនាការករណី០០២ចាប់ផ្តើមនៅថ្ងៃ២១ ខែវិច្ឆិកានេះ ។ អង្គជំនុំជម្រះបានតែងតាំងអ្នកឯកទេសដើម្បីវិនិច្ឆ័យលើកាយសម្បទារបស់ អៀង ធីរិទ្ធ ចាប់ពីដើមឆ្នាំ២០១១មក ។ ក្រោយពីការវិនិច្ឆ័យរោគទៅលើជនជាប់ចោទ អៀង ធីរិទ្ធ អង្គសវនាការសម្រេចថាជនជាប់ចោទរូបនេះមិនអាចចូលរួមក្នុងដំណើរការសវនាការទេ ដោយសារគាត់មានជំងឺវង្វេងវង្វាន់ ។ ប៉ុន្តែទោះជាមានសេចក្តីសម្រេចបែបនេះក្តី អៀង ធីរិទ្ធ នៅតែស្ថិតនៅក្រោមបទចោទប្រកាន់ដដែល ។

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ*** ៖ ចាន់ ដល្លា, ឆាយ ឈុនលី, ម៉ម សុវណ្ណ, គីម ម៉ារីយ៉ាន, រ៉េនដល ដឺហ្វាលកូ, លីស រ៉ូស ម៉ូហូ, ស៊ីវ ហេឌើ, ឡៃ ហួត ***អ្នកនិពន្ធនិងស្រាវជ្រាវ*** ៖ គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា ***អ្នកបកប្រែ*** ៖ ទែន សុខស្រីនិត ***និពន្ធនាយកទូទៅ*** ៖ ឆាំង យុ ***ជំនួយការនិពន្ធនាយក*** ៖ ញាណ សុជាតិ ***ក្រាហ្វិកកុំព្យូទ័រ*** ៖ ស៊ឹម សុភ័ក្ត្រ ***គ្រប់គ្រងការចែកផ្សាយ*** ៖ ម៉ម សុដាត Email: dccam@online.com.kh, Homepage: www.dccam.org

# ថ្នាក់រៀនប្រវត្តិសាស្ត្រនៅអតីតគុកខ្មែរក្រហមមន្ទីរស-២១

ពាក្យស្លោកខ្មែរក្រហមប្រឆាំងនឹងការអប់រំសាធារណៈមួយនិយាយថា "អង្គការគ្មានទេសញ្ញាបត្រ មានតែសញ្ញាឃើញ បើចង់បានបាក់អង បាក់ឌុប ត្រូវទៅយកនៅទំនប់ប្រឡាយ" ។ ពាក្យស្លោកមួយទៀតនិយាយថា "ការរៀនអក្សររៀនលេខមិនសំខាន់ទេ ការសំខាន់គឺ ការងារ និងចលនាបដិវត្តន៍" ។ ជាលទ្ធផល ការសិក្សានៅតាមសាលារៀនជាផ្លូវការត្រូវបានហាមឃាត់ទាំងស្រុងនៅក្រោមការគ្រប់គ្រងប្រកបដោយភាពផ្តាច់ការ និងឃោរឃៅរបស់ខ្មែរក្រហម ។ របបនេះបានប្រែក្លាយសាលារៀន និងវត្តអារាមឲ្យទៅជាគុក ក្រោលគោ និងឃ្លាំងដាក់សម្ភារៈ ។

គុកទួលស្លែងដែលត្រូវបានស្គាល់ថាជាគុកសម្ងាត់ "ស-២១" ត្រូវបានបង្កើតឡើងនៅក្នុងបរិវេណអតីតវិទ្យាល័យ ចៅពញាយ៉ាត ដែលសាងសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ ១៩៦២ ។ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះឲ្យទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ នៅទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេអ៊ីអា ឬកាហ្សេបេ ជាដើម ។ ជាទូទៅក្រុមគ្រួសារទាំងមូលរបស់អ្នកជាប់ចោទពីបទក្បត់ជាតិត្រូវសន្តិសុខចាប់ឃុំឃាំងទាំងអស់ ហើយជាញឹកញយ អ្នកទោសទាំងនោះមិនបានដឹងអំពីមូលហេតុនៃការចោទប្រកាន់ប្រឆាំងនឹងខ្លួនទេ នៅពេលចាប់ខ្លួន ។ ប៉ុន្តែ អ្នកទោសត្រូវឆ្មាំគុកធ្វើទារុណកម្មរហូតទាល់តែអ្នកទោសទាំងនោះសារភាពពីបទល្មើសទាំងឡាយ ដែលត្រូវបានចោទប្រកាន់មកលើខ្លួន ។ បន្ទាប់ពីបានសារភាពរួច អ្នកទោសម្នាក់ៗត្រូវបានកត់ចំណាំដើម្បីយកទៅសម្លាប់ ។

ក្រុមអ្នកជំនាញបានប៉ាន់ស្មានថា អ្នកទោសប្រហែលពី១៤.០០០ទៅ ២០.០០០នាក់ ត្រូវបានឃុំឃាំង និងសម្លាប់នៅគុកទួលស្លែង ។ មានតែអ្នកទោសប្រមាណប្រាំពីរនាក់ប៉ុណ្ណោះ ដែលបានរួចរស់រានមានជីវិតពីគុកនេះ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នៅក្នុងសាលក្រមកាត់សេចក្តីអតីតប្រធានគុកទួលស្លែង ឈ្មោះកាំង ហ្គេកអ៊ាវ ហៅ ឌុច បានកំណត់ថា យ៉ាងហោចណាស់មានអ្នកទោសចំនួនប្រហែល១២.២៧៣ នាក់ បានជាប់ឃុំនៅគុកទួលស្លែង ។ ដោយសារតែចំនួនអ្នកដែលនៅរស់រានមានជីវិតមិនសូវមានការចាប់អារម្មណ៍ អ្នកសារព័ត៌មានលោកខាងលិចភាគច្រើននៅតែប្រើប្រាស់តួលេខប្រាំពីរនាក់ដដែល ហើយតួលេខនេះត្រូវបានប្រើប្រាស់ម្តងហើយម្តងទៀតអស់ជាងសាមសិបឆ្នាំមកហើយ ។ ទោះជាយ៉ាងនេះក្តី បន្ទាប់ពីបានធ្វើការស្រាវជ្រាវអស់រយៈពេលប៉ុន្មានឆ្នាំមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានប៉ាន់ស្មានថា មាន


ការសិក្សានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

អ្នកទោសយ៉ាងតិច១៧៩នាក់ត្រូវបានដោះលែងពីគុកទួលស្លែង ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៨ ហើយមានអ្នកទោសប្រមាណជា ២៣នាក់បន្ថែមទៀតដែលនៅរស់រានមានជីវិត នៅពេលវៀតណាមផ្តួលរំលំរបបខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

បច្ចុប្បន្ន អគារទាំងបួននៅក្នុងបរិវេណគុក បង្កើតបានទៅជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលត្រូវបានបើកជាសាធារណៈនៅក្នុងឆ្នាំ១៩៨០ ។ នៅក្នុងរយៈពេលពីរបីខែនៃការចាប់ផ្តើមបើកសារមន្ទីរនេះ មានប្រជាពលរដ្ឋក្នុងស្រុកចំនួនជាង៣០០.០០០នាក់ និងជនបរទេសប្រមាណ ១១.០០០នាក់ បានចូលទស្សនាសារមន្ទីរនេះ ។ ប្រជាពលរដ្ឋនៅទូទាំងពិភពលោកបានមកទស្សនាសារមន្ទីរនេះ ហើយបច្ចុប្បន្នមានអ្នកមកទស្សនាជាមធ្យមចំនួនប្រហែល២៥០នាក់ក្នុងមួយថ្ងៃ ។ ប្រជាជនកម្ពុជាជាច្រើនបានមកសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដើម្បីស្វែងរកព័ត៌មានអំពីសាច់ញាតិដែលបានបាត់ខ្លួននៅក្នុងរបបខ្មែរក្រហម ។

ខណៈពេលដែលសារមន្ទីរសម្រេចបានដោយជោគជ័យនៅក្នុងការលើកកម្ពស់ការយល់ដឹងជាទូទៅទាក់ទងនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងររបស់ខ្មែរក្រហម សារមន្ទីរនេះនៅមានកង្វះខាតការអប់រំច្បាស់លាស់មួយដែលអាចធ្វើឲ្យបទពិសោធន៍នៃការមកទស្សនាសារមន្ទីរកាន់តែមានប្រយោជន៍ប្រកបដោយការអប់រំ និងគួរឲ្យចងចាំ ។ ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀនមួយត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀននិងការពិភាក្សា ដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនានិងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១នឹងបង្រៀននៅថ្នាក់រៀននេះ ។

ថ្នាក់រៀនប្រវត្តិសាស្ត្រនេះ រៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។

កម្មវិធីនេះ ឧបត្ថម្ភគាំទ្រដោយរដ្ឋាភិបាលប្រទេសប៊ែលហ្ស៊ិក ប្រទេសស៊ុយអែត និងសហរដ្ឋអាមេរិក ។

**ឆាំង យុ**



ណង ចាន់ផល (អ្នករួចរស់ជីវិតពីស-២១) ហ៊ឹម ហ៊ុយ (អតីតកងការពារមន្ទីរស-២១)

# ចលនាលើកទំនប់កសិកម្ម

## ដកស្រង់ចេញពីឯកសារខ្មែរក្រហម D២១៣៨២

### ១) ចលនាលើកទំនប់នៅខេត្តស្ទឹងត្រែង

ខេត្តស្ទឹងត្រែង ដែលកាលពីដើមពុំធ្លាប់ធ្វើស្រែ ហើយទិញស្រូវអង្ករតែពីកន្លែងដទៃទាំងស្រុង ក្រោយពេលរំដោះក៏បានខិតខំធ្វើស្រែបង្កបង្កើនផលឧបត្ថម្ភខ្លួនដោយគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួនកម្រិតខ្ពស់ ។ ទន្ទឹមនឹងចលនាធ្វើស្រែនិងការដាំដំណាំជាយុទ្ធសាស្ត្រផ្សេងៗទៀតក្រោមការដឹកនាំ និងការឃោសនាអប់រំរបស់អង្គការបដិវត្តន៍យើង ចលនាលើកទំនប់ជីកប្រឡាយដើម្បីដោះស្រាយបញ្ហាទឹកទុកសម្រាប់បង្កបង្កើនផល ក៏មានសន្ទុះផុលផុស គគ្រឹកគគ្រេងនៅតាមគ្រប់ភូមិឃុំដែរ ។

ឧទាហរណ៍ នៅឃុំកែងញៀ ស្រុកសៀមបាំង ប្រជាជនបានរួបរួមសាមគ្គីគ្នាលើកទំនប់ទប់ទឹកបញ្ចូលស្រែបានពីរ ។ ទំនប់ទីមួយ នៅត្រពាំងអ៊ិតក់ មានបណ្តោយប្រវែង២០០ម៉ែត្រ បាតក្រោម២ម៉ែត្រ និងកម្ពស់០.៨០ម៉ែត្រ ។ ទំនប់នេះអាចបញ្ចូលទឹកស្រែបាន៤ហិកតា ។

នៅទំនប់ទីពីរ នៅស្រែក្រវ៉ាន់ មានបណ្តោយប្រវែង១១៥ម៉ែត្រ បាតក្រោម២ម៉ែត្រ និង កម្ពស់១ម៉ែត្រ អាចបញ្ចូលទឹកស្រែបាន៣ហិកតា ។

នៅឃុំគិរីវង្សា ក្នុងស្រុកសៀមបាំង ប្រជាជនបានរួបរួមសាមគ្គីគ្នាលើកទំនប់ នៅអូរតាឡៃ បណ្តោយ២២០ម៉ែត្រ បាតក្រោម៣.៥០ម៉ែត្រ និងកម្ពស់១ម៉ែត្រ បិទអូរចាស់ រួចជីកអូរថ្មីប្រវែង ២០ម៉ែត្រ ធ្វើទ្វារបើកបិទ សម្រាប់សន្សំទឹកទុក ។ រួចហើយ បងប្អូនជីកប្រឡាយសងខាងដែលអាចនាំទឹកបញ្ចូលស្រែបាន១០០ហិកតា ។

នៅអូររនោង ក្នុងឃុំគិរីវង្សាដដែលនេះ ប្រជាជនបានសាមគ្គីគ្នាលើកទំនប់មួយប្រវែង១០០ម៉ែត្រ បាតក្រោម៥ម៉ែត្រ ខ្នង៣ម៉ែត្រ និងកម្ពស់៣ម៉ែត្រ ។ ទំនប់នេះអាចរក្សាទឹកបញ្ចូលស្រែបានរាប់ពាន់ហិកតា ។

នៅឃុំចន្ទុ ស្រុកសៀមបាំង ប្រជាជនជនជាតិលុនបានរួបរួមសាមគ្គីគ្នាលើកទំនប់បានបីៈ

- នៅត្រពាំងណុកតិនមួយ បណ្តោយ២០០ម៉ែត្រ បាត២ម៉ែត្រ កម្ពស់១.៨០ម៉ែត្រ ។
- នៅភូមិស្រមរមួយ បណ្តោយ២០០ម៉ែត្រ បាត២ម៉ែត្រ កម្ពស់១.៨០ម៉ែត្រ ។
- នៅភូមិចន្ទុ បងប្អូនលើកទំនប់មួយ នៅអូរពង្រ ហើយជីកប្រឡាយបានប្រវែង៥០ម៉ែត្រ សម្រាប់នាំទឹកចូលស្រែ ។

ក្រៅពីនេះ នៅគ្រប់ភូមិ គ្រប់ឃុំ ប្រជាជនយើងបានរួបរួមសាមគ្គីគ្នាលើកទំនប់ ជីកប្រឡាយ ដោះស្រាយបញ្ហាទឹកបង្កបង្កើនផលបានមួយកម្រិតធំ ។ សរុបមក ក្នុងខេត្តស្ទឹងត្រែងទាំងមូលប្រជាជនយើងបានលើកទំនប់តូចនិងមធ្យម ១០៩កន្លែង ហើយជីកប្រឡាយតូច-មធ្យមបាន៨កន្លែង និងជីកស្រះបាន ១៥ ។ ដោយមានប្រព័ន្ធសំណង់ទឹកនៅគ្រប់កន្លែងទាំងនេះនៅកន្លែងច្រើន ប្រជាជនខេត្តស្ទឹងត្រែង អាចធ្វើស្រែបានពីររដូវក្នុងមួយឆ្នាំ គឺធ្វើស្រូវស្រាលនៅដើមឆ្នាំ និងធ្វើស្រូវសម្រក ស្ទូងបណ្តេញទឹកនៅពេលទឹកស្រកចុះទៅវិញ ។ ឆ្នាំនេះ ប្រជាជនខេត្តស្ទឹងត្រែងដែលធ្លាប់តែទិញស្រូវពីក្រៅមួយរយភាគរយអាចឧបត្ថម្ភខ្លួនបានទាំងស្រុង ហើយមានសល់ស្រូវខ្លះលក់ជូនរដ្ឋទៀតសម្រាប់ទិញដូរពីរដ្ឋវិញ ជាអំបិល ក្រណាត់ ថ្នាំពេទ្យ ។ល ។

### ២) ពិសោធន៍កសិកម្មនៅខេត្តសៀមរាប

#### ១) ពិសោធន៍ចិញ្ចឹមជ្រូកដោយមិនបាច់ចំណាយស្រូវអង្ករ និងកន្ទក់

ក្រោយពេលរំដោះទូទាំងប្រទេសភ្លាម គ្រប់មូលដ្ឋានចាស់យើងមានបន្ទុកជួយចិញ្ចឹមស្បៀងដល់ប្រជាជនដែលទើបត្រូវបានរំដោះថ្មីចំនួនជាង២លាននាក់ ។ នេះជាបន្ទុកធ្ងន់ តែក៏ជាភារកិច្ចចាំបាច់របស់បដិវត្តន៍ និងប្រជាជនយើងដែរ ។ ដោយគោល

ជំហរឯករាជ្យ ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួនខ្ពស់ អង្គការបដិវត្តន៍ និងប្រជាជនយើង នៅតាមគ្រប់មូលដ្ឋាន ខំដោះស្រាយប្រមែប្រមូលស្បៀង និងសន្សំសំចៃស្បៀងជាអតិបរមា ។ ក្នុងស្មារតីសន្សំសំចៃស្បៀងនេះហើយដែលប្រជាជន យុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍ក្នុងខេត្តសៀមរាប បានរកឃើញវិធីចិញ្ចឹមជ្រូកដោយមិនបាច់ចំណាយស្រូវអង្ករ ឬកន្ទក់ឡើយ ។ បងប្អូនបានយកអង្កាមទៅត្រាំទឹកឲ្យរលួយ រួចហើយយកមកបបរលាយនឹងដើមចេក ឬស្លឹកឈើ ស្លឹកព្រៃឲ្យជ្រូកស៊ី ។ ជ្រូកស៊ីឆ្អែត ហើយធំធាត់រហ័សដូចតែយើងចិញ្ចឹមនឹងស្រូវអង្ករ កន្ទក់ដូច្នោះដែរ ។

ព្រមជាមួយនេះ បងប្អូននៅបានប្រមែប្រមូលសន្សំអាចម៍ជ្រូកយកទៅធ្វើជីដាក់ស្រែចម្ការបានជាច្រើនទៀត ។ ជាពិសោធន៍ឃើញថា អាចម៍ជ្រូកនេះមានគុណភាពខ្ពស់ជាងជីដទៃទៀតទាំងអស់ ។ ក្នុងស្រែចម្ការដែលប្រើជីអាចម៍ជ្រូកនេះឃើញថា ស្រូវ និងដំណាំផ្សេងៗដុះលូតលាស់ល្អណាស់ ។

## ២) ពិសោធន៍ដោះស្រាយការខ្វះពូជ

ឆ្នាំនេះ ចលនាបង្កបង្កើនផល មានសភាពផុលផុសខ្លាំងក្លាអស្ចារ្យណាស់នៅទូទាំងប្រទេសកម្ពុជា ។ ស្រែចាស់ទាំងអស់ត្រូវបានភ្ជួររាស់ហើយស្រេច ។ ព្រមជាមួយនេះ ដោយមានកម្លាំងពលកម្ម ប្រជាជនដែលទើបបានរំដោះថ្មីជាងពីរលាននាក់ ចេញទៅរួមផ្សំផង ផ្ទៃដីបង្កបង្កើនផលថ្មីក៏ត្រូវបានត្រួសត្រាយ ពង្រីកជាច្រើនថែមទៀត ។ ដូច្នេះ ពូជដែលបានត្រៀមបម្រុងទុកពីឆ្នាំទៅមិនគ្រប់គ្រាន់ទេ ។ ដើម្បីកុំឲ្យខាតពេលមួយរដូវនេះផង និងដើម្បីធ្វើឲ្យអស់ដីថ្មីដែលបានរុករានមកហើយផង ប្រជាជន យុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍នៅខេត្តសៀមរាបបានច្នៃប្រឌិតដោះស្រាយបញ្ហាខ្វះខាតពូជដូចតទៅ ៖

ក) រត់ដោះដូរពូជពីកន្លែងដទៃដែលមានច្រើន យកមកចែកជូនប្រជាជនថ្មី ។

ខ) ប្រមូលសំណាបពីកន្លែងផ្សេងៗដែលស្ទូងសល់យកមកផ្តល់ជូនកន្លែងខ្វះខាត ។

គ) បំបែកគុម្ពស្រូវតាមស្រែផ្សេងៗដែលស្មោកយកទៅស្ទូងនៅស្រែថ្មីទៀត ។

ឃ) ដកស្រូវមួរតាមកន្លែងផ្សេងៗយកទៅស្ទូងស្រែថ្មី ។

ធ្វើយ៉ាងនេះ បងប្អូនយើងនៅខេត្តសៀមរាប អាចដោះស្រាយបញ្ហាខ្វះពូជដោយឯករាជ្យ ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួនបានកម្រិតខ្ពស់ ។

## ៣) ដំណើរសិប្បកម្ម និងរោងជាង

តាំងពីសម័យតស៊ូនយោបាយ សម័យតស៊ូអាវុធរួមផ្សំនយោបាយ រហូតដល់សម័យតស៊ូធ្វើសង្គ្រាមបដិវត្តន៍ វាយកម្ទេចសង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិក និងបរិវារ ។ ប្រជាជនកម្ពុជា ក្រោមការដឹកនាំដ៏ភ្លឺស្វាងរបស់អង្គការបដិវត្តន៍បានប្រកាន់ខ្ជាប់នូវគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ។ ហើយគោល



កងចល័តលើកទំនប់ ជីកប្រឡាយ

ជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួននេះបានក្លាយទៅជាប្រពៃណីបដិវត្តន៍ដ៏រុងរឿងរបស់ប្រជាជាតិ ប្រជាជន និងបដិវត្តន៍កម្ពុជាយើងទៅហើយ ដែលធ្វើឲ្យសកលលោកគោរពកោតស្ញប់ស្ញែង និងយកគំរូសម្រាប់រៀនសូត្រតាម ។

ឥឡូវ ក្នុងសម័យសន្តិភាព និងឯករាជ្យនេះហើយ ក៏ប្រជាជនកម្ពុជាយើងនៅតែប្រកាន់ខ្ជាប់នូវគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួននេះយ៉ាងរឹងមាំតទៅទៀត ។ ដើម្បីការពារប្រទេសជាតិ និងកសាងកម្ពុជាឲ្យខ្លាំងក្លា សម្បូរសប្បាយថ្កុំថ្កើងរុងរឿង ដោយឯករាជ្យ ម្ចាស់ការ បានប្រជាជនយើងរឹតតែចាំបាច់ត្រូវពង្រឹងគោលជំហរបដិវត្តន៍ខាងលើនេះឲ្យបានកាន់តែ

រឹងមាំថែមទៀត ។

ដោយយល់ស្របគ្នាជាឯកច្ឆន្ទយ៉ាងនេះហើយ ទើបក្រោយពេលរំដោះទូទាំងប្រទេសបានភ្លាម ប្រជាជនកម្ពុជាយើងនៅគ្រប់តំបន់ គ្រប់ភូមិភាគ ទូទាំងប្រទេស ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃអង្គការបដិវត្តន៍បានវាយសម្រុកកសាងប្រទេសទាំងយប់ទាំងថ្ងៃយ៉ាងមមាញឹក ញាប់ដៃ ញាប់ជើងទៅតាមលទ្ធភាព និងមធ្យោបាយដែលខ្លួនមាន តែដោយស្មារតីច្នៃប្រឌិត កសាងរស់រវើក ។ បងប្អូនគ្មានស្មារតីពឹងផ្អែក ឬដេករង់ចាំជំនួយបរទេសឡើយ ។ សិប្បកម្មគ្រប់ប្រភេទ និងរោងជាងតូច



មធ្យម ធំ បានកើតមានឡើងព្រោងព្រាតនៅតាមគ្រប់ភូមិភាគ តំបន់ ស្រុក រហូតដល់គ្រប់ឃុំ-ភូមិទៀត ដើម្បីប្រឡងប្រណាំងជាមួយរោងចក្រនៅទីក្រុង ផលិតចេញរបស់របរប្រើប្រាស់ចាំបាច់ផ្សេងៗជូនប្រជាជននៅក្នុងតំបន់ខ្លួន ដោយឯករាជ្យ ម្ចាស់ការខ្លួនទីពឹងខ្លួនកម្រិតខ្ពស់បំផុត ។

ឧទាហរណ៍ នៅក្រចេះ មានរោងជាងចាក់ផាលបី ដែលប្រើកម្លាំងមនុស្សតែដប់នាក់ប៉ុណ្ណោះ អាចផលិតបានពី១.០០០ ទៅ១.២០០ផាលក្នុងមួយថ្ងៃ ។ ដូច្នេះ រោងជាងទាំងបីនេះ មិនត្រឹមតែអាចបម្រើសេចក្តីត្រូវការខាងកសិកម្មនៅក្នុងតំបន់ក្រចេះមួយប៉ុណ្ណោះទេ តែនៅមានផលសល់សម្រាប់លក់ដូរ ចែកចាយជូនប្រជាជននៅតំបន់ជិតខាងនោះទៀតផង ។

ក្រៅពីនេះ ក្រចេះនៅមានទូ្ល និងរោងជាងធ្វើឆ្នាំងស្ពាបព្រា ធ្វើស្លាបចក្រកាណូត និងរបស់របរប្រើប្រាស់ផ្សេងៗមួយចំនួនទៀត ដូចជា ដែកកេះ ចង្កៀង ។ល ។ ព្រមជាមួយនេះ ក្រចេះ នៅមានរោងជាង៧ទៀតសម្រាប់ជួសជុលកប៉ាល់ កាណូត និងម៉ាស៊ីនតូចៗ ។

ឧទាហរណ៍ នៅស្រុកអង្គរជ័យ ខេត្តតាកែវ មានរោងជាងធ្វើផាល ធ្វើឆ្នាំង ធ្វើថាំងទឹក ធ្វើចបកាប់ កាំបិតផ្គាក់ ខ្វែវ ។ល ។ ដែលអាចបម្រើសេចក្តីត្រូវការរបស់ប្រជាជនក្នុងស្រុកខ្លួនបាន ។ ក្រៅពីនេះ ស្រុកអង្គរជ័យ នៅមានរោងជាងធ្វើដែកកេះ រោងជាងប្រើម៉ាស៊ីនពាក់កណ្តាលស្វ័យប្រវត្តិ សម្រាប់រំលាយអម្បែងកែវ ធ្វើអំពូលថ្នាំចាក់ និងរោងជាងធ្វើរបស់របរប្រើប្រាស់ផ្សេងៗទៀត ។

ឧទាហរណ៍ នៅភូមិភាគបូព៌ា និងភូមិភាគឧត្តរ មានរោងជាងសិប្បកម្មធំៗ សម្រាប់ធ្វើសាប៊ូ ធ្វើក្រដាស់ ធ្វើស្បែកជើង ។ល ។ ក្រៅពីនេះ ភូមិភាគទាំងពីរនេះនៅមានសិប្បកម្មត្បាញរវៃយ៉ាងទំនើបទៀត ។ កីតម្បាញដៃពីមុនៗមកដែលត្បាញឃើតភាគច្រើនលើសលប់ត្រូវបានជំនួសដោយស្វ័យប្រវត្តិ និងកីពាក់កណ្តាលស្វ័យប្រវត្តិហើយ ។ សព្វថ្ងៃ តម្បាញក្រមា មុង ភួយ អាចឧបត្ថម្ភខ្លួនបាន ដោយឯករាជ្យ ម្ចាស់ការមួយកម្រិតខ្ពស់ហើយ ។ ឥឡូវ ប្រជាជនយើងនៅក្នុងភូមិភាគទាំងពីរ នេះក៏ដូចប្រជាជនកម្ពុជាទូទាំងប្រទេសដែលកំពុងតែសម្រុកដាំមន កប្បាសយ៉ាងច្រើនថែមទៀត ។ ដូច្នេះ នៅពេលណាដែលដំណាំសិប្បកម្មទាំងនេះហុចផលបរិបូរពេញទំហឹង សិប្បកម្មត្បាញរវៃនៅក្នុងភូមិភាគទាំងពីរនេះ និងរីកចម្រើនយ៉ាងឆាប់រហ័សទៀត ព្រោះទុនជាឧបករណ៍ និងបច្ចេកទេសមានសព្វគ្រប់អស់ហើយ ។

ឧទាហរណ៍ទាំងនេះ បញ្ជាំងឲ្យឃើញអនាគតរីកបំព្រងនៃសិប្បកម្មប្រជាជនយើងដែលមានលក្ខណៈជាតិ និងចម្រើនជឿនលឿនផង ហើយឈរលើមូលដ្ឋាននៃគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន យ៉ាងរឹងប៉ឹង ខ្ជាប់ខ្ជួនជានិច្ចផង ។ តទៅអនាគតសិប្បកម្មតាមតំបន់ទាំងនេះនឹងប្រែក្លាយជាឧស្សាហកម្មតំបន់យ៉ាងជាក់ស្តែង ។ ហើយរោងជាងទាំងនេះនឹងប្រែក្លាយទៅជារោងចក្រប្រចាំតំបន់វិញពុំខានឡើយ ។

# អតីតកម្មាភិបាលខ្មែរក្រហមនៅស្រុករវៀង

នៅពេលតុលាការកំពុងដំណើរការកាត់ទោស និងចោទប្រកាន់បន្ថែមទៅលើអតីតមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតខ្មែរក្រហមដែលធ្វើឲ្យប្រជាជនប្រមាណជិតពីរលាននាក់ស្លាប់ក្នុងអំឡុងពេលគ្រប់គ្រងរបស់ខ្លួនក៏ដោយ ក៏អតីតកម្មាភិបាលខ្មែរក្រហមថ្នាក់ទាបនៅស្រុករវៀង នៅតែទទួលការគោរព និងគាំទ្រពីប្រជាជន និងអ្នកភូមិនៅមូលដ្ឋានដដែល ដោយសារការងារដឹកនាំ និងគ្រប់គ្រងល្អរបស់គាត់ ។

រវៀងជាស្រុកមួយនៃខេត្តព្រះវិហារ ។ ស្រុកនេះត្រូវបានចលនាបដិវត្តន៍ខ្មែរក្រហមរំដោះភ្លាមៗបន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ នៅឆ្នាំ១៩៧០ ។ ប្រជាជនក្នុងស្រុករវៀង បានចូលរួមឧបត្ថម្ភគាំទ្រ និងចូលបម្រើបដិវត្តន៍ខ្មែរក្រហម ឬ រណសិរ្សប្រវាស់ដៃ រហូតទទួលជ័យជម្នះ ។ អតីតកម្មាភិបាលដែលធ្លាប់បម្រើឲ្យចលនាខ្មែរក្រហមទាំងនោះមានដូចជា ៈ

**សៅ អួន** អាយុ៥០ឆ្នាំ កើតនៅឃុំប្រវត្តិ (បច្ចុប្បន្ន ឃុំរស្មី) ស្រុករវៀង ខេត្តព្រះវិហារ ។ អួន មានបងប្អូន១០នាក់ និងមានឪពុកម្តាយជាកសិករ ។ អួន រៀនដល់ថ្នាក់ទី១០ នៅសាលាឆទាន ក្រោមការគ្រប់គ្រងរបស់កងកម្លាំងរំដោះ ។ ក្រោយមកអួនឈប់រៀនមកជួយធ្វើការងារស្រែចម្ការឪពុកម្តាយវិញ ។

នៅឆ្នាំ១៩៧២ អួន ត្រូវបានគណៈឃុំឈ្មោះ សុក លុយ ជ្រើសរើសគាត់ឲ្យចូលរៀននៅក្រសួងបណ្តុះបណ្តាលកុមារ ឬក្រសួងបណ្តុះបណ្តាលគ្រូបង្រៀន ដោយសម្គាល់ឃើញគាត់ឆ្លាតចេះនិយាយ អាចបង្រៀន និងដឹកនាំកុមារឲ្យធ្វើការងារបាន ។ អួនបានមកស្នាក់នៅ និងរៀននៅក្រសួង ដែលមានទីតាំងនៅអនុវិទ្យាល័យរវៀង (បច្ចុប្បន្នវិទ្យាល័យរវៀង) ជាមួយសិក្ខាកាមមកពីគ្រប់ស្រុកក្នុងខេត្តព្រះវិហារ ដោយមានឈ្មោះ អាន់ មកពីស្រុកស្មោង និងប្រពន្ធគាត់ឈ្មោះ អឿន មកពីភ្នំពេញ ជុន និងនារី រឿន (ដែលតែងតែដាក់កាំភ្លើងជាប់នឹងខ្លួន) មកពីស្រុកថាឡាបរិវ៉ាត់ខេត្តស្ទឹងត្រែង ជាអ្នកបង្រៀន និងគ្រប់គ្រង ។

នៅទីនោះ អួន បានរៀនពីគោលការណ៍បង្រៀនសិស្សមេរៀនប្រវត្តិសាស្ត្រ ចំណោទក្រឡាផ្ទៃចតុកោណកែងស្មើ និងការជំរុញកុមារឲ្យក្លាហានតស៊ូដឹកស្រះ ដឹកប្រឡាយ និងលើកទំនប់ ។ អួន បន្តថា គ្រូក៏បានណែនាំគាត់អំពី «មិនត្រូវឲ្យសិស្សខ្ជិល ហើយសិស្សត្រូវតែស្តាប់តាមការណែនាំរបស់គ្រូ ប្រសិនបើមិនធ្វើតាមទេ គ្រូត្រូវយកសិស្សនោះទៅអប់រំ» ។ ពេលនោះក្រសួងបានបែងចែកកាលវិភាគសិស្សពីរពេល គឺពេលព្រឹករៀនចាប់ពីម៉ោងប្រាំពីរដល់ម៉ោងប្រាំបី បន្ទាប់មកគាត់


ក្រុមប្រឹក្សាឃុំឡើងរៀបរាប់ពីបទពិសោធន៍ក្នុងរបបខ្មែរក្រហម

ត្រូវឲ្យបាយជ្រូក កាប់ដីធ្វើចម្ការ កាប់រណ្តៅដាំដើមដូង ជីកអណ្តូង លើកទំនប់និងជីកស្រះរហូតដល់ថ្ងៃត្រង់ ។ នៅពេលរសៀលចាប់ពីម៉ោងពីរដល់ម៉ោងបី គាត់ធ្វើពលកម្មរហូតដល់ល្ងាចទើបឈប់ហូបបាយ រួចហើយបន្តជីកស្រះរហូតដល់ម៉ោង១១យប់ ។ ចំពោះវិន័យ សិស្សទាំងអស់ត្រូវមករៀនឲ្យទាន់ពេលវេលា និងធ្វើការតាមការណែនាំរបស់គ្រូ ប្រសិនបើអនុវត្តមិនបានទេ គ្រូនឹងធ្វើការទិតៀននៅពេលបើកអង្គប្រជុំ ។ ចំណែករបបអាហារ ក្រសួងបានរៀបចំឲ្យបីពេល គឺពេលព្រឹកហូបបបរ ពេលថ្ងៃ និងពេលល្ងាចហូបបាយ ។ នៅអំឡុងពេលចូលរួមវគ្គបណ្តុះបណ្តាលនោះ អួន មកលេងផ្ទះពីរដងប៉ុណ្ណោះ ដោយគាត់ប្រាប់គ្រូបង្រៀនថា ឪពុកម្តាយគាត់ឈឺធ្ងន់ ។

បន្ទាប់ពីបណ្តុះបណ្តាលបានរយៈពេលមួយឆ្នាំ ក្រសួងបណ្តុះបណ្តាលកុមារ បានចាត់តាំងគ្រូទាំងអស់ឲ្យទៅតាមមូលដ្ឋានរៀងខ្លួន ដោយឡែក អួន ត្រឡប់មកបង្រៀនកុមារនៅសាលាតារ (បច្ចុប្បន្នស្រែតារ) ដែលមានពីរបន្ទប់សង់ពីឈើ ប្រក់ស្បូវ ។ អួន បង្រៀនសិស្សថ្នាក់ទីពីរដែលមានអាយុចាប់ពីដប់បួនទៅដប់ប្រាំមួយឆ្នាំ និងមានចំនួនសរុបទាំងអស់៤០នាក់ ។ ក្រោយមក ទើបមានសិស្សដែលជម្លៀសមកដល់ថ្មីចូលរៀនបន្ថែមទៀត ។ អួន បង្រៀនសិស្សរយៈពេលពីរម៉ោងក្នុងមួយថ្ងៃ អំពីការប្តេជ្ញាទិតខំធ្វើការងារ និងទិតខំបង្កបង្កើនផល បន្ទាប់មកគាត់ត្រូវដឹកនាំសិស្សដកស្ទូង លើកភ្លឺស្រែ លើកទំនប់ និងជីកប្រឡាយ ។ ចំណែករបបអាហារ អួន និងសិស្សរបស់គាត់ត្រូវទៅហូបបបរនៅការដ្ឋានដូចកងចល័តដែរ ។

រៀងរាល់ថ្ងៃ បន្ទាប់ពីហូបបាយល្ងាចរួច អួន ត្រូវដឹកនាំសិស្សធ្វើការបន្តរហូតដល់ម៉ោង១១យប់ទៀត ។ ពេលនោះ សិស្សខ្លះ មិនអាចទ្រាំទ្រនឹងការហត់ហេវ អស់កម្លាំង និងអត់ងងុយ បានដេកនៅវាលស្រែតែម្តង ។ ដូច្នេះ ក្រោយពេលចប់ម៉ោងការងារ អួន ត្រូវដើរប្រមូលក្មេងៗទាំងនោះឲ្យមកដេកក្នុងជំរំវិញ និងធ្វើការអប់រំ ។

អួន បង្រៀនសិស្សរហូតដល់ឆ្នាំ១៩៧៨ ទើបមានកម្មាភិបាល ធ្វើការផ្នែកជួសជុលរថយន្តនៅមន្ទីរសាធារណការ ដែលមានស្រុកកំណើតនៅខេត្តស្ទឹងត្រែងមកស្នើគាត់រៀបការ ។ អង្គការបានរៀបចំពិធីរៀបការចំនួន៦០គូ នៅរោងបាយរួម ដោយមានធ្វើជ្រូក និងធ្វើគោដើម្បីជប់លៀង ។ បន្ទាប់ពីរៀបការរួច អួន បានផ្លាស់មករស់នៅជាមួយប្តីនៅមន្ទីរមានទីតាំងស្ថិតនៅស្រុករវៀង (បច្ចុប្បន្ន មន្ទីរសាធារណការ និងដឹកជញ្ជូនស្រុករវៀង) ហើយគាត់បន្តបង្រៀនសិស្សនៅទីនោះរហូតដល់ឆ្នាំ១៩៧៩ ទើបត្រឡប់មករស់នៅភូមិវិញ ។ ក្រោយមក អួន ត្រូវបានប្រជាជនជ្រើសរើសឲ្យធ្វើមេភូមិរហូតមកដល់បច្ចុប្បន្ននេះ ។


សៅ អួន

អួន បញ្ជាក់ថា គាត់ចង់ឲ្យក្មេងៗជំនាន់ក្រោយបានយល់ដឹងពីរបបខ្មែរក្រហម ប៉ុន្តែគាត់មិនចង់ឲ្យមានការរើសអើងចំពោះខ្មែរក្រហមទេ ព្រោះការដឹកនាំអាស្រ័យទៅតាមសង្គម ប្រសិនបើយើងមិនធ្វើតាមគេ គេនឹងសម្លាប់ចោល ។ អួន បន្តថា សម័យនោះ ទោះបីគាត់ធ្វើការងារលំបាក នឿយហត់ និងគ្មានពេលសម្រាកយ៉ាងណាក៏ដោយ ក៏គាត់សប្បាយ និងពេញចិត្តដែរ ព្រោះជាការងារដែលអង្គការចាត់តាំង ហើយមានក្មេងៗជាច្រើននៅក្នុងភូមិបានចូលរួមធ្វើការងារទាំងនោះដែរ ។

**សុក លុយ** មានអាយុ៦២ឆ្នាំ រស់នៅស្រុករវាង ខេត្តព្រះវិហារ ។ លុយ មានបងប្អូនបីនាក់ និងមានឪពុកម្តាយជាកសិករ ។ នៅឆ្នាំ១៩៥៩ លុយ បានបួសនៅវត្តច័ន្ទនិម្មិត្ត ហៅវត្តរវៀង ក្រោយមកគាត់បានរៀនសាលាបាលីរង ។ រហូតដល់ឆ្នាំ១៩៦៦ លុយ បានសឹករួច ត្រឡប់មកជួយធ្វើការងារស្រែចម្ការក្រុមគ្រួសារដែលមានជីវភាពខ្វះខាតវិញ ។


សុក លុយ

មកដល់ឆ្នាំ១៩៧០ ខ្មែរក្រហមចូលមកដល់ភូមិ រួចហើយបែងចែកប្រជាជនជាក្រុម កង និង សហគមន៍ ក្រោយមកនៅឆ្នាំ១៩៧៣ ទើបបែងចែកទៅជាសហករណ៍ ដោយមានឈ្មោះ ខ ហង្ស មកពីខេត្តតាកែវ ជាគណៈតំបន់ និងជាអ្នកដឹកនាំផ្ទាល់ ។ នៅពេលនោះ លុយ ត្រូវបានខ្មែរក្រហមជ្រើសរើសឲ្យធ្វើជាប្រធានក្រុមដឹកនាំប្រជាជនពីរយនាក់ លើកទំនប់ ប្រព័ន្ធភ្លឺស្រែ និងជីកប្រឡាយ ។

បន្ទាប់ពីយោធាខ្មែរក្រហមរំដោះប្រទេសនៅឆ្នាំ១៩៧៥ អង្គការបានផ្លាស់ លុយ ឲ្យមកធ្វើការងារនៅឃុំ ដោយពេលនោះគាត់មានតួនាទីដឹកអង្ករ និងស្បៀងពីឃុំផ្សេងៗមកបែងចែកឲ្យប្រជាជននៅសហករណ៍របស់គាត់ ។ ចំណែកប្រជាជនដែលជម្លៀសមកថ្មី អង្គការបានបែងចែកជាបីក្រុម គឺអ្នកមិនសូវមានកម្លាំងត្រូវឲ្យនៅធ្វើការ និងហូបបាយនៅសហករណ៍ឃុំ អ្នកដែលមានប្តីប្រពន្ធត្រូវទៅលើកទំនប់ និងយុវជនយុវនារីនៅកងចល័ត ។ ដោយឡែកអ្នកដែលមិនធ្លាប់ធ្វើការធ្ងន់ទាំងនោះ អង្គការបានចាត់តាំងឲ្យមើលគោ និងពុះឬស្សី ។ ចំណែករបបអាហារ ប្រជាជនថ្មីទាំងនោះទទួលបានស្មើគ្នាដូចប្រជាជនមូលដ្ឋានដែរ ។ ទោះបីមានការណែនាំ និងបែងចែកការងារច្បាស់លាស់យ៉ាងនេះក៏ដោយ ក៏មានប្រជាជនថ្មីបានបដិសេធ និងមិនស្តាប់បញ្ជារបស់អង្គការដែរ ហើយអ្នកនោះត្រូវឈ្លបយកទៅសម្លាប់ ។

ចាប់តាំងពីរំដោះឆ្នាំ១៩៧៥ ស្រុករវៀង តំបន់១០៣ មានការប្រែប្រួល ដោយដំបូងតំបន់នេះ ស្ថិតនៅភូមិភាគឦសាន ដែលរួមមានខេត្តព្រះវិហារ ស្ទឹងត្រែង ក្រចេះ រតនគិរី និងមណ្ឌលគិរី ។ ក្រោយពីមានការចោទប្រកាន់ និងចាប់កម្មាភិបាលនៅភូមិភាគឦសាន ពិសេសកម្មាភិបាលនៅខេត្តស្ទឹងត្រែង ទើបអង្គការផ្តាច់តំបន់១០៣ ដែលរួមមានស្រុកសេរីការ (បច្ចុប្បន្ន សង្គមថ្មី) បុទុមពរ (បច្ចុប្បន្ន បុទុមសាគរ) ជាំក្សាន្ត ឆែបជ័យសែន និងរវៀង ទៅជាតំបន់ស្វយ័ត ។

នៅឆ្នាំ១៩៧៨ អង្គការបានចាប់អតីតគណៈតំបន់ ១០៣ ឈ្មោះ ហង្ស រួចផ្លាស់ ឃឹម មកពីខេត្តសៀមរាប ជាគណៈតំបន់១០៣ថ្មី និង កង ចាប ហៅ សែ ជាលេខាភូមិភាគឧត្តរមកគ្រប់គ្រងនៅស្រុករវៀងវិញ ។ ឃឹម បានចាប់ប្រជាជនប្រធានកង មេភូមិ គណៈឃុំ គណៈស្រុក គណៈតំបន់ និងកម្មាភិបាលនៅមន្ទីរជាច្រើន ។ លើសពីនោះ កង ចាប បានកោះហៅប្រជាជន និងកម្មាភិបាលនៅស្រុករវៀងទាំងអស់ឲ្យមកប្រជុំរយៈពេលបីថ្ងៃនៅវត្តរីករាយ ។ នៅក្នុងអង្គប្រជុំ កង ចាប បានចោទប្រកាន់ខ្លាំងៗទៅគណៈតំបន់ចាស់ ហង្ស និងខ្សែក្បត់ និង គៀសដៃបណ្តាលឲ្យបែកកែវជាច្រើន ។ បន្ទាប់ពីប្រជុំចប់ កង ចាប បញ្ជាឲ្យចាប់ប្រជាជន និងកម្មាភិបាលជាច្រើនដាក់ឡានយកទៅឃុំឃាំងនៅមន្ទីរសន្តិសុខតំបន់១០៣ និងមួយចំនួនទៀតយកទៅឃុំឃាំងនៅខេត្តសៀមរាប ។ នៅឆ្នាំ១៩៧៨ដដែល អង្គការបានបញ្ជូន មាស វឿន ដែលមានស្រុកកំណើតនៅខេត្តកំពង់ស្ពឺមកចាប់ ឃឹម, គណៈស្រុក និងទាហាន រួចគាត់ទទួលនាទីជាគណៈតំបន់១០៣ថ្មី ។ ចំណែក កង ចាប បានបាត់ខ្លួនចាប់តាំងពីពេលនោះមក ។

ទោះបីមានការបោសសម្អាតច្រើនយ៉ាងនេះក៏ដោយ ក៏មិនប៉ះពាល់ដល់ លុយ ដែរ ដោយសារតែគាត់ធ្វើការងារតាមការបញ្ជារបស់អង្គការ ។ ចំណែកកម្មាភិបាលមួយចំនួនទៀតអង្គការចាប់យកទៅបាត់រហូត ។ លុយ រៀបរាប់ថា នៅអំឡុងឆ្នាំ ១៩៧៨ ឃុំរបស់គាត់មានអង្ករតែពីរកំប៉ុងប៉ុណ្ណោះ សម្រាប់ចែកឲ្យប្រជាជនពីររយនាក់ ទោះបីគាត់ខិតខំស្នើសុំថ្នាក់លើបន្ថែមរបបក៏ដោយ ។ ដូច្នេះ ប្រជាជនទាំងនោះត្រូវយកដើមចេក បេះស្លឹកកន្ទួតមកបបរលាយបន្ថែមទៀត ។ ការហូបមិនគ្រប់គ្រាន់បែបនេះបានធ្វើឲ្យប្រជាជននៅក្នុងឃុំរបស់ លុយ ធ្លាក់ខ្លួនឈឺហើម និងស្លាប់ជាបន្តបន្ទាប់ ។

លុយ កាន់តួនាទីឃុំរហូតដល់ខ្មែរក្រហមដួលរលំ ។ នៅឆ្នាំ ១៩៨២ លុយ ត្រូវបានប្រជាជនជ្រើសរើសឲ្យធ្វើការជាក្រុមប្រឹក្សាឃុំម្តងទៀត ហើយក្រោយមកគាត់ធ្វើជាប្រធានឃុំរស្មី ។

រហូតមកដល់ពេលបច្ចុប្បន្ន លុយ និង អួន នៅតែមានការគោរពរាប់អាន និងគាំទ្រពីប្រជាជននៅមូលដ្ឋានរបស់គាត់ដដែល ដោយសារការងារដឹកនាំ និងគ្រប់គ្រងនៅក្នុងភូមិឃុំបានល្អ ។ លុយ និង អួន តែងតែពិភាក្សា និងធ្វើការផ្ទាល់ជាមួយប្រជាជនអំពីសុខភាព ការអប់រំ ផ្សព្វផ្សាយ និងគម្រោងផ្សេងៗរបស់ឃុំ ។

**សោម ប៊ុនថន**

# បក់ សួង : អនុវរសេនាតូចពិសេសនៃកងពល២០៧

បក់ សួង ហៅ ស៊ូ កើតនៅស្រុកត្រាំកក់ ខេត្តតាកែវ ។ នៅឆ្នាំ១៩៦៣ គ្រួសារ សួង បានផ្លាស់ពីខេត្តតាកែវ ទៅស្រុកចម្ការលើ ខេត្តកំពង់ចាម ។ រហូតដល់ឆ្នាំ១៩៧២ ស្រុកចម្ការលើត្រូវយោធាខ្មែរក្រហមរំដោះបាន ហើយពេលនោះ សួង ដែលទើបមានអាយុ១៨ឆ្នាំ ក៏បានស្ម័គ្រចូលបម្រើបដិវត្តន៍ ។

ក្រោយពីមានការបញ្ចុះបញ្ចូលពីខ្មែរក្រហម សួង បានចូលធ្វើពេទ្យឃុំស្ដី ព្រោះគាត់គិតថានឹងទទួលបានចំណេះដឹងម្យ៉ាងទៀតគាត់ឃើញក្មេងនៅក្នុងភូមិបានចូលធ្វើពេទ្យដូចគាត់ដែរ ។ ទោះបីយ៉ាងណាក៏ដោយ ក៏ឪពុកម្ដាយ សួង មិនចង់ឲ្យ សួង ចូលធ្វើពេទ្យដែរព្រោះខ្លាចខ្មែរក្រហមបំបែកមិនឲ្យរស់នៅជាមួយកូន ម្យ៉ាងគិតថា សួង នៅក្មេងពេក ។ ប៉ុន្តែដោយសារការរឹងមានះរបស់ សួង ទើបគាត់យល់ព្រម ។

ដំបូង សួង ចូលធ្វើការនៅមន្ទីរពេទ្យឃុំ ដោយមានប្រធានឈ្មោះ ណា និងអនុប្រធាន ឈ្មោះ ផាន មានតួនាទីជាអ្នកពិនិត្យ និងព្យាបាលជំងឺទូទៅ ។ នៅទីនោះ ណា បានចាត់តាំង សួង ឲ្យធ្វើជានិរសា និងភារកិច្ចទៅបើកថ្នាំពីមន្ទីរយកមកព្យាបាលឲ្យអ្នកជំងឺ ។


បក់ សួង

សួង ធ្វើការនៅពេទ្យបានរយៈពេលពីរឆ្នាំកន្លះ គឺនៅឆ្នាំ១៩៧៤ គាត់ក៏បបួលមិត្តភក្តិដែលធ្វើការជាមួយគ្នាចាកចេញពីមន្ទីរ ព្រោះគាត់មិនពេញចិត្តនឹងការងារនិរសា ។ សួង បានទៅចូលបម្រើនៅក្នុងកងពល៣១០ ភូមិភាគឧត្តរ ដោយមានឈ្មោះ អឿន និង វឿង ជាមេបញ្ជាការ ។ សួង ត្រូវបានចាត់តាំងឲ្យឡើងទៅវាយនៅសមរភូមិដូចជា សៀមរាប និង កំពង់ចាម ដោយវាយពីព្រៃទឹងចូលមកក្រុងភ្នំពេញ ។ សួង បាននិយាយថា គាត់មិនមានគំនិតចង់ធ្វើសង្គ្រាមទេ ប៉ុន្តែ ដោយសារការចាត់តាំង និងបញ្ជាពីថ្នាក់លើឲ្យវាយយកទីក្រុងភ្នំពេញ ។

នៅឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានទទួលជ័យជម្នះលើកងទ័ព លន់ នល់ ទាំងស្រុង ។ អង្គភាពរបស់ សួង បានចូលមកបោះទីតាំងនៅទួលត្បែង មុំទំនប់កប់ស្រូវ ជាយទីក្រុងភ្នំពេញ ។ អង្គការចាប់ផ្ដើមផែនការជម្លៀសប្រជាជនចេញទៅធ្វើការនៅតាមជនបទ ដែលពេលនោះ សួង ក៏បានទទួលបញ្ជាពីថ្នាក់លើឲ្យជម្លៀសប្រជាជននៅមុំស្ពានីយ៍រទេះភ្លើងឲ្យចាកចេញទៅតាមផ្លូវពោធិ៍ចិនតុងដែរ ។ ឆ្លៀតឱកាសនោះ សួង បានដើរស៊ើបសួររកពូរបស់គាត់ម្នាក់ឈ្មោះ សុល រស់នៅក្បែរវាំង ។

សំណាងល្អ សួង បានជួបម្ដាយមីង (ប្រពន្ធរបស់ សុល) ទើបដឹងថា ពូរបស់គាត់បានស្លាប់ហើយ ។ ក្រោយពេលត្រឡប់មកដល់អង្គភាពវិញ ប្រធាន សួង បានសួរ សួង ថា មិត្តទៅណា? ហេតុអ្វីបានជាមិនឃើញនៅអង្គភាព? សួង បានឆ្លើយតាមត្រង់ថាទៅរកពូ ។ ប្រធានកងបានសួរបញ្ជាក់ថា ពូរបស់មិត្តធ្វើអី? សួង ក៏បានឆ្លើយប្រាប់ថា «ធ្វើទាហានហ្លួង» ទើបគាត់ឈប់សួរ ។

នៅទីនោះ សួង បានឃើញទិដ្ឋភាពទីក្រុងភ្នំពេញស្ងាត់ជ្រងំ និងលែងឃើញប្រជាជនដូចមុនទៀតហើយ ។ អ្នកដែលរស់នៅក្នុងទីក្រុងភ្នំពេញមានតែកងទ័ព និងកម្មករធ្វើការនៅតាម

រោងចក្រប៉ុណ្ណោះ ។ សួង ធ្វើការនៅកងពល៣១០រហូតដល់ឆ្នាំ១៩៧៦ អង្គការបានជ្រើសរើសគាត់ឲ្យទៅរៀនបើកឡាននៅទួលគោក (អង្គភាពដដែល) ដោយមានឈ្មោះ កៅ ជនជាតិវៀតណាមជាគ្រូបង្រៀន ។ ពេលទៅដល់ទីនោះ ប្រធានកងពលបាននិយាយទៅកាន់ប្រធានកង (អ្នកជ្រើសរើស) ថា «ហេតុអ្វីបានជានាំក្មេងៗមកអីចឹង កាច់តែចង្កូតឡានមិនរួចផង» ។ ពេលនោះ សួង ភិតភ័យយ៉ាងខ្លាំង ព្រោះគាត់គិតថា អង្គការនឹងយកគាត់ទៅសម្លាប់មិនខាន ។ សួង ស្នាក់នៅទីនោះរយៈពេលមួយយប់ ទើបគាត់ឃើញប្រធានកងយកមនុស្សប្រាំពីរនាក់មកបន្ថែមទៀត រួចហើយផ្លាស់គាត់ទៅផ្នែកជួសជុលរថយន្តវិញ ។

សួង រៀនជួសជុលរថយន្តរហូតដល់ឆ្នាំ១៩៧៧ ទើបអង្គការបានបញ្ជូនគាត់ឲ្យទៅគ្រប់គ្រងទ័ពនៅមន្ទីរព១ ស្ថិតនៅក្នុងភូមិតាក្រក ឃុំរំចេក ស្រុកចម្ការលើ ខេត្តកំពង់ចាម ។ នៅឆ្នាំដដែល អង្គការចាប់ អឿន, វឿង និងកម្មាភិបាលផ្សេងទៀតយកទៅសម្លាប់ចោល រួចហើយចាត់តាំង ញ៉ី មកជំនួស និងបានប្តូរកងពល៣១០ ទៅ២០៧វិញ ។ នៅទីនោះ សួង ត្រូវបានបញ្ជាការវរសេនាតូចទី២ ឈ្មោះ ម៉េត ចាត់តាំងឲ្យធ្វើជាប្រធានអនុសេនាធំទី១ គ្រប់គ្រងកងទ័ពចំនួន១០០នាក់ ។ ប៉ុន្តែមិនយូរប៉ុន្មាន អង្គការបានបញ្ជូនកងទ័ពភូមិភាគនិរតីមកចាប់កូនទាហានរបស់គាត់យកទៅសម្លាប់ចោលដោយចោទថាខ្មែរយួន ។

ពេលទទួលបានដំណឹងនេះមុន សួង បានជិះម៉ូតូCL៩០ គេចចេញពីមន្ទីរ ។ សួង បានធ្វើដំណើររហូតដល់ភូមិជ្រៃសាន ខេត្តរតនគិរីក៏ជួបជាមួយអតីតមេបញ្ជាការរបស់គាត់ឈ្មោះ ឡេង មានតួនាទីជាប្រធានកងពល២៩០ ។ ឡេង បានអនុញ្ញាតឲ្យ សួង ស្នាក់នៅជាមួយគាត់រយៈពេលមួយអាទិត្យ ទើបឲ្យវិលត្រឡប់មកមន្ទីរវិញ ដោយមានសរសេរសំបុត្រមួយច្បាប់ភ្ជាប់មកជាមួយផង ។ ឡេង បានរំឭក សួង ថា ពេលមកដល់កន្លែងធ្វើការ ត្រូវយកសំបុត្រនេះឲ្យទៅប្រធានកងពល ។

សួង បានយកសំបុត្រទៅប្រគល់ជូនប្រធានកងពល ។ បន្ទាប់ពីអាននិងពិនិត្យរួចរាល់ហើយ ទើបអនុញ្ញាតឲ្យ សួង នៅធ្វើការនៅកន្លែងដដែល ប៉ុន្តែមិនមានតួនាទីដូចមុនទេ ។ ក្រោយមក អង្គការបានចាត់តាំងឲ្យ សួង ទៅធ្វើការខាងជួសជុលរថយន្តនៅកងពល២០៧ ដោយមានប្រធានឈ្មោះ ថន និងបញ្ជាការកងពលឈ្មោះ ញ៉ី ។ មិនយូរប៉ុន្មាន ញ៉ី ត្រូវបានចាប់ខ្លួនដោយចោទថាក្បត់ ចំណែក សួង អង្គការផ្លាស់ឲ្យទៅធ្វើជាអ្នកបើកឡានដឹកជញ្ជូនអង្ករ ប្រេង គ្រាប់កាំភ្លើង និងសម្ភារផ្សេងៗទៀតឲ្យទ័ព ។

រៀងរាល់ថ្ងៃ សួង ត្រូវទៅដឹកជញ្ជូនសម្ភារចេញពីឃ្លាំងភស្តុភារយោធារបស់មន្ទីរភូមិភាគបូព៌ា ស្ថិតនៅជិតផ្សារសួង ដោយមាន សោ ភឹម ជាអ្នកគ្រប់គ្រងទៅកាន់សមរភូមិត្រពាំងផ្លុង ។ ក្រោយមក សោ ភឹម បានធ្វើអត្តឃាតខ្លួនឯងនៅឆ្នាំ១៩៧៨ ដោយសារគាត់ដឹងថា ប៉ុល ពត បានបញ្ជាទាហានឲ្យចាប់ និងសម្លាប់គាត់ ។ សាកសពរបស់ សោ ភឹម ត្រូវយោធាខ្មែរក្រហមដង្ហែឲ្យប្រជាជនមើល ថែមទាំងបានផ្សព្វផ្សាយថាគាត់បានលក់ទឹកដីឲ្យយួន ។

បន្ទាប់មក អង្គការបានចាត់តាំង សួង ឲ្យធ្វើជាប្រធានអនុវរសេនាតូចពិសេសនៃកងពល២០៧ ស្ថិតក្រោមការគ្រប់គ្រងរបស់ ប៉ុន មេបញ្ជាការកងពល (ផ្លាស់មកពីកងពល៦០៣) និង ឈ្មោះ ប៉ុន ម្នាក់ទៀតមកប្រចាំការនៅកងពល២០៧ផ្ទាល់ ។ នៅទីនោះ សួង មានភារកិច្ច រៀបចំកងទ័ពចំនួន៧០នាក់ដើម្បីយាមការពារមន្ទីរកងពល ។ ប៉ុន្តែការដឹកនាំកម្លាំងទ័ពរបស់ ប៉ុន នៅពេលនោះមិនបានល្អប្រសើរទេ ទើបកងទ័ពជាច្រើនចាប់ផ្តើមបាក់ទឹកចិត្ត ហើយបានរត់ទៅចូលរួមជាមួយកងទ័ពវៀតណាមវិញ ។

នៅអំឡុងឆ្នាំ១៩៧៨ សួង ធ្លាក់ខ្លួនឈឺ ហើយគាត់ក៏មកសម្រាកព្យាបាលនៅមន្ទីរពេទ្យ ស្ថិតនៅជិតផ្សារសួង ។ នៅយប់មួយ សួង ឃើញយោធាខ្មែរក្រហមបណ្តើរមនុស្សប្រមាណ៣០នាក់ យកទៅសម្លាប់នៅក្បែរមន្ទីរពេទ្យដែលគាត់ស្នាក់នៅ រួចហើយទម្លាក់ចូលទៅក្នុងអណ្តូង ។ ព្រឹត្តិការណ៍នេះធ្វើឲ្យ សួង មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង និងធ្វើឲ្យគាត់ដឹងថាខ្មែរក្រហមបានសម្លាប់មនុស្ស ។

នៅឆ្នាំ១៩៨០ ទើប សួង បានវិលត្រឡប់មករកគ្រួសារនៅស្រុកចម្ការលើវិញ ។ ប៉ុន្តែ សួង មិនបានជួបប្អូនស្រីទេ ព្រោះគាត់បានស្លាប់ដោយសារជំងឺគ្រុនក្តៅចាប់តាំងពីពេលគាត់នៅធ្វើជាយោធាខ្មែរក្រហមមកម្ល៉េះ ។

**ចាន់ ផល្លា**

# អ្នកទោសគុកភ្នំទ្រយោង

ទីប សំផាត់ ត្រូវបានខ្មែរក្រហមចាប់ខ្លួន និងបញ្ជូនមកដាក់នៅគុកទ្រយោង ស្ថិតនៅក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ ការចាប់ខ្លួន ផាត់ គឺដោយសារមានលិខិតមួយច្បាប់ចុះហត្ថលេខា និងមានបោះត្រាដោយ អ៊ឹម ចែម ដែលជាលេខាស្រុកព្រះនេត្រព្រះកាលពីជំនាន់កម្ពុជាប្រជាធិបតេយ្យ ដោយចោទថា បានក្បត់បដិវត្តន៍ ។ សំបុត្រនោះបានបញ្ជាក់ថា “ផាត់ត្រូវសងឈាមបដិវត្តន៍វិញ” ។

សព្វថ្ងៃ ផាត់ មានអាយុ៥៥ឆ្នាំ មានស្រុកកំណើតនៅស្រុកព្រះនេត្រព្រះ ។ ផាត់ កើតនៅក្នុងត្រកូលកសិករមួយមានបងប្អូនប្រាំនាក់ (ស្រីពីរនាក់ និងប្រុសបីនាក់) ហើយគាត់គឺជាកូនទីបី ។ កាលពីកុមារភាព ផាត់ ធ្លាប់បានរៀនត្រឹមថ្នាក់ទី៧ ហើយក៏ឈប់វិញនៅឆ្នាំ១៩៧៤ ដើម្បីមកជួយធ្វើស្រែឪពុកម្តាយ ។ ក្រោយមក ផាត់ ត្រូវបានជ្រើសរើសឲ្យធ្វើការនៅក្នុងកងចល័តនៅឃុំគោករំចេក និង ឃុំព្រៃមាន់ ដែលមានទីតាំងនៅក្នុងស្រុក


ទីប សំផាត់

ភ្នំស្រុក (សព្វថ្ងៃខេត្តបន្ទាយមានជ័យ) ដោយមានភារកិច្ចរែកដីលើកទំនប់ ជីកប្រឡាយ និងធ្វើស្រែ ។ ធ្វើការងារនេះបានប្រហែលមួយខែ ផាត់ ក៏ត្រឡប់មកនៅភូមិដប់វ៉ារី ឃុំព្រះនេត្រព្រះវិញ ។ នៅទីនោះ ផាត់ ឃើញមានកិច្ចប្រជុំមួយដែលធ្វើឡើងនៅក្នុងវត្តដប់វ៉ារីដែលមានរយៈពេលបីថ្ងៃ ហើយពេលនោះ សមមិត្ត ម៉ោង ដែលជាគណៈស្រុក ព្រះនេត្រព្រះចាប់ពីដើមឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ មកចូលរួមជាគណៈអធិបតី ។ កិច្ចប្រជុំនោះមានការចូលរួមពីសំណាក់ប្រជាជនរាប់ពាន់នាក់ ។

ក្រោយមក នៅឆ្នាំ១៩៧៦ មានការចាប់ផ្តើមបែងចែកប្រជាជនឲ្យទៅធ្វើការនៅតាមកងចល័ត ហើយ ផាត់ ត្រូវបានបញ្ជូនឲ្យទៅនៅកងចល័តស្រុកព្រះនេត្រព្រះដើម្បីធ្វើការមួយចំនួនដូចជា លើកប្រព័ន្ធភ្លឺស្រែ និងស្ទូងស្រូវ ។ ថ្ងៃមួយ ផាត់ មានជំងឺគ្រុនក្តៅរហូតដល់សន្លប់ ហើយត្រូវបញ្ជូនមកព្យាបាលនៅមន្ទីរពេទ្យតំបន់៥ ប្រហែលដប់ថ្ងៃ ។ នៅពេលដែលត្រឡប់មកនៅផ្ទះវិញ ផាត់ ត្រូវបានជ្រើសរើសឲ្យធ្វើការនៅក្នុងកងភ្ជួរវិញ ។ បន្ទាប់មក ប្រធានភូមិឈ្មោះ ឈីវ ក៏បានជ្រើសរើសកុមារ ដែលមានអាយុចាប់ពី១៦ ដល់១៨ឆ្នាំ ឲ្យចូលជាពេទ្យឃុំខាងផ្នែកជំងឺគ្រុនចាញ់ ។ ផាត់ ក៏ត្រូវចាត់ចូលក្នុងក្រុមនេះដែរ ដោយមានគ្នាពីរនាក់ទៀតគឺ សំរាន និង សែន ។ មុននឹងធ្វើជាពេទ្យ ផាត់ ត្រូវបានបញ្ជូនឲ្យទៅរៀនវិជ្ជាជីវៈពេទ្យរយៈពេលបីខែនៅស្វាយសុីសុផុន ។

នៅចុងឆ្នាំ១៩៧៦ ក្រោយពេលរៀនចប់ ផាត់ បានត្រឡប់មកព្រះនេត្រព្រះវិញ ។ បន្ទាប់មក ផាត់ ត្រូវបានបញ្ជូនឲ្យទៅធ្វើពេទ្យនៅឃុំភ្នំលៀបដោយសារនៅទីនោះគ្មានពេទ្យខាងជំងឺគ្រុនចាញ់ ដែលមាននារី លី ជាប្រធានពេទ្យ និងប្រធានឃុំឈ្មោះ ធាង ។ នៅទីនោះមិនយូរប៉ុន្មាន ធាង ត្រូវបានចាប់ខ្លួន ។ ក្រោយមក លេខាស្រុកព្រះនេត្រព្រះឈ្មោះ ម៉ោង ក៏ត្រូវបានចាប់ខ្លួនទៀត ។ ផាត់ នៅចាំថ្ងៃនោះថា ម៉ោង ត្រូវបានចាប់ខ្លួននៅថ្ងៃ

ទី១៨ ខែមិថុនា ឆ្នាំ១៩៧៧ ហើយ អ៊ឹម ចែម ក៏មកធ្វើជាគណៈស្រុកនៅទីនេះជំនួសវិញ ។ ផាត់ និយាយថា អ៊ឹម ចែម ទើបតែផ្លាស់មកពីភូមិភាគនិរតី ហើយមកកាត់តាំងណែងជាគណៈស្រុកព្រះនេត្រព្រះ ហើយផ្ទះរបស់គាត់ស្ថិតនៅជាប់នឹងសាលាឃុំភ្នំលៀប ។ ផាត់ រៀបរាប់ថា គាត់បានស្គាល់ អ៊ឹម ចែម ដោយសារពេលទៅធ្វើពេទ្យនៅតាមភូមិ ការគ្រប់គ្រងមានការតឹងរ៉ឹង ដូច្នេះគាត់ត្រូវមានលិខិតអនុញ្ញាតពី អ៊ឹម ចែម ដើម្បីធ្វើការងារ ។ ផាត់ នៅចាំថា សំបុត្រនោះមានវាយអក្សរអង្គុលីលេខ និងនៅពីលើលិខិតនោះមានសរសេរថា "កម្ពុជាប្រជាធិបតេយ្យ" ។ ផាត់ បាន រៀបរាប់ពី អ៊ឹម ចែម ថា បើមើលពីខាងក្រៅ គាត់មិនមែនជាមនុស្សកាចសាហាវទេ តែគាត់ជាមនុស្សមានអំណាចណាស់នៅពេលនោះ ។ មិនយូរប៉ុន្មាន ផាត់ ត្រូវបានជាប់ចោទថាបានក្បត់បដិវត្តន៍តាមរយៈសំបុត្រ របស់ អ៊ឹម ចែម ដែលសរសេរទៅ ផាត់ ។

## អ្នកទោសបដិវត្តន៍

ប្រហែលជាខែសីហា ឆ្នាំ១៩៧៨ ដោយសារការរស់នៅកាន់តែពិបាក ផាត់ បាននិយាយត្អូញត្អែរជាមួយសមាជិកផ្សេងទៀតអំពីការរស់នៅ និងការហូប និងរៀបរាប់ពីភាពអយុត្តិធម៌ ព្រោះកម្មាភិបាលធំៗ បានហូបឆ្អែតឆ្អន់ ចំណែកឯគាត់ហូបមិនគ្រប់គ្រាន់ ។ រំលងបានមួយសប្តាហ៍ នៅក្នុងក្រុមពេទ្យក៏បើកការប្រជុំស្វ័យទិតៀនមួយ ។ ពេលនោះ ផាត់ បានទិតៀនអង្គការថា "ប្រធានគេស៊ីបាយមានមាន់ស្ងោរ ចំណែកយើងដែលជាកូនចៅស៊ីតែបបរ" ។ បន្ទាប់ពីប្រជុំរួច នារី លី ដែលជាប្រធានពេទ្យបានរាយការណ៍ទៅប្រាប់ អ៊ឹម ចែម ពីការទិតៀនរបស់គាត់ ។

ប្រហែលមួយខែក្រោយមក ផាត់ ត្រូវបានហៅយកទៅដាក់គុកនៅភ្នំទ្រយោងដោយមានក្រដាសមួយសន្លឹកបញ្ជាពី សឿន ជាប្រធានគុក ។ ពេលទៅដល់គុកនោះ អ្នកដែលទៅចាប់គាត់ក៏សួរគាត់ថា "មានដឹងថា ជាប់ទោសអីដែរទេ?" ផាត់ បានឆ្លើយថា "ខ្ញុំអត់ដឹងទេ ។ មិនដឹងជាទោសរឿងស្អីធំប៉ុនណា ក៏ខ្ញុំអត់ដឹងដែរ" ។ បន្ទាប់មកអ្នកចាប់ខ្លួនគាត់បានបញ្ជាក់ទៀតថា "ពិតជាមិនដឹងរឿងមែនទេ?" តែ ផាត់ នៅតែឆ្លើយថាអត់ដឹងដដែល ហើយបន្ថែមទៅវិញថា "បើសិនជាទោសនោះវាធំរហូតក្បត់បដិវត្តន៍ ទុកក៏វាខាតបាយនិងខាតបបរដែរ" ។ ពេលនោះប្រធានគុកឈ្មោះ សឿន បានយកសំបុត្រចេញពីហោប៉ៅមកឲ្យ ផាត់ មើលដោយគាត់ឃើញមានសរសេរថា "ទោសក្បត់បដិវត្តន៍" ហើយក្នុងសំបុត្រនោះមានឈ្មោះបីនាក់គឺ យ៉េត, នៅ និងរូបគាត់ផ្ទាល់ ។

ផាត់ ឃើញសំបុត្រនោះច្បាស់ណាស់ គឺមានចុះហត្ថលេខាដោយ អ៊ឹម ចែម និងមានវាយត្រាពណ៌ក្រហមផង ។ ពេលបានអានសំបុត្រនោះរួចហើយ ផាត់ បានហុចសំបុត្រទៅឲ្យ សឿន វិញ ហើយនិយាយថា "ទោសនេះធ្ងន់ណាស់ បើនិយាយពីរឿងសកម្មភាពដែលធ្វើគឺខ្ញុំអត់ដឹងទេ ហើយខ្ញុំក៏មិនដែលទៅមានគំនិតក្បត់បដិវត្តន៍អ្វីដែរ" ។ នៅពេលនោះ សឿន ក៏បានប្រាប់គាត់ថា "បើចង់រស់កុំរត់ទៅណា បើទ្រាំនៅទីនេះគឺមិនស្លាប់ទេ" ។

## គុកភ្នំទ្រយោង

គុកភ្នំទ្រយោងនោះមានលក្ខណៈជារោងមួយសម្រាប់ដាក់អ្នកដែលបានប្រព្រឹត្តខុស ដែលបានបង្កើតឡើងប្រហែលជាខែឧសភា ឬមិថុនា ឆ្នាំ១៩៧៨ ។ តាមការរៀបរាប់របស់អ្នកធ្លាប់ជាប់នៅគុកនេះបានឲ្យដឹងថា អ៊ឹម ចែម គឺជាអ្នកបង្កើតគុកនោះ ហើយគុកនោះក៏ស្ថិតនៅមិនឆ្ងាយពីផ្ទះរបស់គាត់នៅភ្នំលៀបដែរ ។ ផាត់ បានរៀបរាប់ថា ពេលដែលគាត់ទៅដល់ទីនោះ អ្នកទោសមានចំនួនប្រហែលជាមិនដល់១០០នាក់ផង ប៉ុន្តែចំនួនបានកើនឡើងយ៉ាងខ្លាំងប្រហែលមួយខែក្រោយមក គឺចំនួនអ្នកទោសកើនឡើងជិត១.០០០គ្រួសារ រួមទាំងកុមារផង ។ ក្រោយមកទៀត ខ្មែរក្រហមបានបង្កើតរោងវែងមួយទៀត ដែលអាចដាក់អ្នកទោសបានជិត១០០នាក់ សម្រាប់អ្នកទោសកម្រិតធ្ងន់ ។

អ្នកទោសទាំងអស់ត្រូវតម្រូវឲ្យធ្វើការងារនៅពេលថ្ងៃដូចជា ដាំចេក និងកាស់រំលាយដីដំបូក គាស់ឫស្សី ពង្រាបដីឲ្យស្មើជាដើម ។ នៅពេលអ្នកទោសធ្វើការ អ្នកយាមដើរមើលការពារយ៉ាងហ្មត់ចត់ ។ ការហូបចុកក៏មិនមានភាពគ្រប់គ្រាន់ដែរ ហើយ ផាត់ អះអាងថា អ្នកទោសមួយចំនួនកើតជំងឺហើម ។ ប៉ុន្តែ ផាត់ ចេះវិធីព្យាបាលបានខ្លះៗ ។ ដោយដឹងថា ផាត់ ចេះជំនាញពេទ្យ ប្រធានគុកឈ្មោះ សឿន បានសួរគាត់អំពីវិធីដែលអាចជួយអ្នកទោសកើតជំងឺហើមឲ្យជាសះស្បើយ ។

នៅទីនេះ មានអ្នកទោសមួយចំនួនបានលួចរត់ចេញពីគុក

ដោយខ្លះរត់រួច និងខ្លះទៀតត្រូវបានបាញ់សម្លាប់ចោលភ្លាមៗ ហើយសាកសពអ្នកទោសត្រូវយកទៅកប់នៅជើងភ្នំទ្រយោង ។ ផាត់ បានរៀបរាប់ឲ្យដឹងថា អ្នកទោសនៅទីនេះក្រោយមកកាន់តែតិចទៅៗពីមួយថ្ងៃទៅមួយថ្ងៃ ។ អ្នកទោសខ្លះស្លាប់ដោយសារអត់ឃ្លាន ។ ដោយសារតែការផាវ សឿន ធ្លាប់ស្គាល់គ្នាជាមួយ ផាត់ ពីមុនមកនោះ មួយរយៈក្រោយមក សឿន បានជ្រើសរើសគាត់ឲ្យទៅធ្វើការជាមួយ ចំណែកឯ នៅ និង យ៉េត ទៅធ្វើការនៅកងអាជីវកម្ម ខាងនេសាទសម្រាប់ផ្គត់ផ្គង់គុកទាំងមូល ។ សឿន បានឲ្យ ផាត់ ទៅផ្ទះ អ៊ឹម ចែម នៅឯភ្នំលៀបដើម្បីយកប្រេងម៉ាស៊ូតពីរដបទៅដាក់ឡានដឹកឈើយកទៅដាក់នៅកន្លែងគុកសម្រាប់ធ្វើផ្ទះឲ្យអ្នកទោស ។ ពេលនោះ អ៊ឹម ចែម បានសួរគាត់ទៀតថា "មិត្តឯងទៅណាមានការអី?" ហាក់ដូចជាមិនចាប់អារម្មណ៍ថា គាត់ធ្លាប់បានចេញលិខិតបញ្ជាឲ្យចាប់ខ្លួនគាត់ដោយចោទថាបានក្បត់បដិវត្តន៍នោះទេ ។

សឿន បានហៅ ផាត់ ឲ្យទៅជួយជីករណ្តៅសម្រាប់កប់សាកសពប្រហែលជាបួនទៅប្រាំជង ដែលជីករណ្តៅចុងក្រោយមានទំហំធំដែលអាចដាក់មនុស្សរហូតដល់ទៅ៩០នាក់ ។ ផាត់ បានបន្ថែមទៀតថា នៅទីនេះ គាត់ក៏បានឃើញ អ៊ឹម ចែម ទៅជួបជាមួយ សឿន ម្តង ដោយ អ៊ឹម ចែម ជិះម៉ូតូសេអិលពណ៌សមួយគ្រឿង មាននិរសាប្រុសម្នាក់ឌុប ហើយគាត់ស្លៀកសំពត់ខ្មៅ អាវខ្មៅ និងបង់កក្រមា ដែលពេលនោះ គាត់កំពុងមានផ្ទៃពោះផង ។

មុនពេលវៀតណាមជិតចូលមកដល់ ផាត់ និងសមាជិកប្រាំនាក់ទៀតបានទៅជីករណ្តៅយ៉ាងធំទំហំបីម៉ែត្របួនជ្រុងជម្រៅប្រហែលមួយម៉ែត្រកន្លះតាំងពីល្ងាចរហូតដល់ពាក់កណ្តាលយប់ ។ ពេលជីករួច សឿន បានបញ្ជាឲ្យអ្នកយាមគុកចំនួន៣០នាក់នោះសម្លាប់អ្នកទោសដោយប្រើដំបង និងចបកាប់ ។ ផាត់ បានឃើញព្រឹត្តិការណ៍សម្លាប់នេះយ៉ាងច្បាស់ព្រោះគាត់បានអង្គុយមើលនៅក្បែរនោះ ។ បន្ទាប់ពីជីករណ្តៅរួច អ្នកទោសត្រូវបញ្ជាឲ្យអង្គុយលុតជង្គង់បែរមុខទៅរកមាត់រណ្តៅ ដោយដៃមានដាប់ចំណង ។ បន្ទាប់មក អ្នកដែលវាយចាប់ផ្តើមដើរវាយពីក្រោយទម្លាក់ទៅក្នុងរណ្តៅ ។ អ្នកយាមគុកបាននាំគ្នាសើចក្អាកក្អាយក្រោយពេលសម្លាប់អ្នកទោសរួចហើយ ។ ចំណែកអ្នកទោសប្រុសៗដែលត្រូវសម្លាប់មានស្លៀកខោអាវ ចំណែកអ្នកទោសស្រីវិញត្រូវបានសម្រាតខោអាវចេញទាំងអស់ ។ ផាត់ បានបន្តឲ្យដឹងថា ក្នុងចំណោមអ្នកទោសទាំងអស់ មានតែនារីម្នាក់ប៉ុណ្ណោះដែលបានស្រែកមុនពេលស្លាប់ថា "ស្លាប់ចុះបដិវត្តន៍អើយ! យើងខ្ញុំមិនស្តាយទេ" ។ និយាយពាក្យនេះចប់ អ្នកទោសនោះក៏ស្លាប់បាត់ទៅ ។ ផាត់ ក៏មិនបានដឹងច្បាស់ថា នារីនោះជាកម្មាភិបាលខ្មែរក្រហមដែរ ឬប្រជាជនធម្មតានោះទេ ព្រោះអ្នកទោសទាំងនោះមានមកពីកងចល័តដែរ ។

នៅពេលវៀតណាមចូលមកដល់ អ្នកដែលធ្វើការនៅគុកនាំគ្នារត់ភៀសខ្លួនអស់ រួមទាំង អ៊ឹម ចែម និង សឿន ដែលកាលនោះ អ៊ឹម ចែម ទើបតែសម្រាលកូនរួច ។ ចំពោះករណី អ៊ឹម ចែម, ផាត់ បានរៀបរាប់ថា អ៊ឹម ចែម ពិតជាបានដឹងរឿងគុកភ្នំទ្រយោងនេះយ៉ាងច្បាស់ ។ រហូតមកដល់សព្វថ្ងៃនេះ ផាត់ នៅតែមិនដឹងថា សឿន រស់នៅកន្លែងណាទេ ហើយគាត់ពិតជាចង់ទៅជួប សឿន ដែរ ព្រោះ សឿន គឺជាអ្នកជួយសង្គ្រោះជីវិតគាត់ពេលដែលគាត់ត្រូវបានឃុំខ្លួននៅក្នុងគុកនោះ ។

**ឆាយ ឈុនលី**

# ដំណឹងស្វែងរកសាច់ញាតិ

នាងខ្ញុំឈ្មោះ លឹម ឃិត អាយុ៥០ឆ្នាំ សព្វថ្ងៃរស់នៅភូមិដំណាក់ចិន ឃុំរស្មី ស្រុករវៀង ខេត្តព្រះវិហារ ។ សូមប្រកាសរកបងប្រុសបង្កើត ឈ្មោះ លឹម ប៊ួន ដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមតាំងពីឆ្នាំ១៩៧៣ ។ ក្រោយពេលខ្មែរក្រហមទទួលជ័យជម្នះនៅឆ្នាំ១៩៧៥ បងប្រុសនាងខ្ញុំបានផ្លាស់ទៅធ្វើការនៅភ្នំពេញ ហើយចាប់ពីឆ្នាំ១៩៧៨ គាត់បាត់ខ្លួនរហូត ។

ប្រសិនបើបងប្អូនណាបានស្គាល់ឈ្មោះ ឬឮដំណឹងនេះ សូមមេត្តាទាក់ទងមកអាសយដ្ឋានរបស់នាងខ្ញុំដូចបានរៀបរាប់ខាងលើឬមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ឬទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ ***សូមអរគុណ***

# បាត់បង់ឪពុកក្នុងរបបខ្មែរក្រហម


ចាន់ ណារ៉ុង

ចាន់ ណារ៉ុង អាយុ៥៨ឆ្នាំ ជាគ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យានៅអនុវិទ្យាល័យជ្រៃ ខេត្តបាត់ដំបង។

ណារ៉ុង មានឪពុកឈ្មោះ ចាន់ ណាំង ជាគ្រូបង្រៀននៅសាលាបឋមសិក្សាគំរូភ្នំសំពៅ (បច្ចុប្បន្នសាលាបឋមសិក្សាភ្នំសំពៅ) នៅសម័យសង្គមរាស្ត្រនិយម។ ក្រោយមក ឪពុក ណារ៉ុង ធ្វើជាបាឡាត់ស្រុកនៅខេត្តបាត់ដំបង ចំណែកម្តាយឈ្មោះ លី ហុង លឿយ ជាមេផ្ទះ។ ណារ៉ុង ជាកូនច្បងនៅក្នុងគ្រួសារ ដែលមានបងប្អូនប្រុសប្រាំមួយនាក់ និងស្រីម្នាក់។

ក្នុងវ័យកុមារភាព ណារ៉ុង សិក្សានៅភ្នំសំពៅ (បច្ចុប្បន្នស្រុកបាណន់) ដល់កម្រិតទី២ ដែលស្មើនឹងថ្នាក់អនុវិទ្យាល័យនាពេលបច្ចុប្បន្ន។ ពេលនោះ ដោយសារការបង្រៀនមិនសូវបានជាប់លាប់ ហើយគាត់ជាសិស្សខ្សោយផងនោះ ទើបឪពុកម្តាយគាត់សម្រេចចិត្តបញ្ជូន ណារ៉ុង ឲ្យទៅរៀនសូត្រនៅភ្នំពេញ ដោយស្នាក់នៅជាមួយឪពុកមានិងម្តាយមីង។ ក្រោយមក ទើបឪពុកគាត់ផ្លាស់នៅធ្វើការងារនៅភ្នំពេញដែរ។

ដំបូង ណារ៉ុង មិនសូវស៊ាំនឹងរស់នៅភ្នំពេញទេ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏ ណារ៉ុង មិនភ្លេចការសិក្សារៀនសូត្ររបស់គាត់ដែរ។ ណារ៉ុង បានរៀនដល់ថ្នាក់ទីបញ្ចប់ (បច្ចុប្បន្ន ថ្នាក់ទី១២) ប៉ុន្តែមិនបានប្រឡងបញ្ចប់ការសិក្សានោះទេ ព្រោះពីមួយថ្ងៃទៅមួយថ្ងៃ ស្ថានការណ៍នៅទីក្រុងភ្នំពេញមានភាពវឹកវរ ដោយ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ។

ពេលនោះ ប្រជាពលរដ្ឋខ្មែរ គ្រូបង្រៀន រួមទាំងសិស្សានុសិស្សបានទាំគ្នាធ្វើបាតុកម្មតវ៉ា សម្តែងការមិនពេញចិត្តនឹងការទម្លាក់សម្តេច សីហនុ។ ការតវ៉ារបស់ប្រជាពលរដ្ឋមិនទទួលអ្វីជាលទ្ធផលនោះទេ បានត្រឹមតែធ្វើឲ្យកងកម្លាំងរបស់របបសាធារណរដ្ឋខ្មែរបង្ក្រាបធ្វើឲ្យរងរបួស និងស្លាប់បាត់បង់ជីវិតតែប៉ុណ្ណោះ។ ចំណែកប្រពន្ធ័អប់រំបានកាន់តែឱនថយ ព្រមទាំងមានការផ្លាស់ប្តូរឈ្មោះសាលារៀនមួយចំនួនដែលជាប់ពាក់ព័ន្ធទៅនឹងរាជវង្សានុវង្សទៀតផង។

ចំណែកនៅតាមបណ្តាខេត្តនៅជុំវិញទីក្រុងភ្នំពេញចាប់ផ្តើមមានចលនាតស៊ូប្រឆាំងជាមួយ លន់ នល់ ហើយកម្លាំងតស៊ូនេះកាន់តែរីកធំឡើង បន្ទាប់ពីការអំពាវនាវរបស់សម្តេច សីហនុ ឲ្យប្រជាជនកម្ពុជារត់ចូលព្រៃម៉ាគី ដើម្បីផ្តួលរំលំរបប លន់ នល់ ដែលកម្លាំងតស៊ូនេះ ត្រូវបានប្រជាជនស្គាល់ថា ជាខ្មែរក្រហម។ ណារ៉ុង បានត្រឡប់មករស់នៅខេត្តបាត់ដំបងជាមួយឪពុកម្តាយវិញ ព្រោះរដ្ឋាភិបាល លន់ នល់ តម្រូវឲ្យសិស្សដែលគ្រប់អាយុ១៧ឆ្នាំឡើងទៅត្រូវចូលហ្វឹកហាត់ទាហាន។ នៅពេលនោះ ណារ៉ុង ក៏មានឈ្មោះក្នុងបញ្ជីជ្រើសរើសទាហានដែរ ប៉ុន្តែដោយសារឪពុកគាត់ស្គាល់អ្នកធំទើបគាត់រួចផុតពីកាតព្វកិច្ចយោធានេះ។ ណារ៉ុង និងគ្រួសារត្រឡប់មកដល់ភ្នំសំពៅ ខេត្តបាត់ដំបងមិនបានប៉ុន្មានផង យោធាខ្មែរក្រហមវាយយកបាន ខេត្តនេះទាំងស្រុងនៅខែមេសា ឆ្នាំ១៩៧៥។

ក្រោយមក ខ្មែរក្រហមក៏មកស្នើឪពុករបស់ ណារ៉ុង ទៅរៀនសូត្ររយៈពេលបួនថ្ងៃ ដោយមិនមានការធ្វើបាប ឬបង្ខិតបង្ខំ។ នៅឱកាសស្វាគត់ ណារ៉ុង បានលួចទៅសួរសុខទុក្ខឪពុកដោយខណៈនោះ ឪពុកគាត់បានប្រាប់ ណារ៉ុង វិញថា “អង្គការនឹងយកគាត់ទៅរៀនសូត្របន្ថែមទៀត ព្រោះអង្គការដឹងថា គាត់ជាបាឡាត់ស្រុក” ហើយគាត់បានផ្តែផ្តាំថា សូមកូនមើលប្អូនៗផងព្រោះប្អូននៅតូច។ ណារ៉ុង ដែលពេលនោះមានអាយុ១៨ឆ្នាំ

ទៅហើយ គាត់អាចបេះគិតគូរបានខ្លះ ។ ណារ៉ុង សម្គាល់ថា ឪពុកគាត់ជាមនុស្សតឹងរ៉ឹង និងម៉ឺងម៉ាត់ណាស់ ហេតុអ្វីថ្ងៃនោះគាត់និយាយស្ងួតទន់ភ្លន់ ។ ណារ៉ុង ដឹងថាឪពុកគាត់ពិបាកចិត្ត និងអស់សង្ឃឹមហើយ ។ ណារ៉ុង បានស្ទុះទៅឱបឪពុកគាត់ និងយំខ្លាំងៗ ។

ខណៈនោះដែរ ប្រជាជនមួយចំនួនដែលខ្មែរក្រហមហៅទៅរៀនសូត្រជាមួយឪពុក ណារ៉ុង ដែរ បានលួចរត់គេចខ្លួនជាបន្តបន្ទាប់ ព្រោះដឹងថាខ្មែរក្រហមនឹងយកទៅសម្លាប់ចោលជាមិនខាន ។ ក្រោយមក មានអ្នកភូមិដែលរស់នៅជិតខាងបានមកលួចខ្សឹបប្រាប់ម្តាយ ណារ៉ុង ឲ្យទៅប្រាប់ប្តីឲ្យរត់គេចខ្លួនដែរ ព្រោះខ្មែរក្រហមនឹងមិនអត់ឱនឲ្យទេ ។ គ្រាន់តែបានដឹងរឿងនេះភ្លាម ណារ៉ុង ក៏ទៅប្រាប់ឪពុក ប៉ុន្តែឪពុកគាត់បដិសេធ ។ ចាប់ពីពេលនោះមក ឪពុក ណារ៉ុង បាត់ខ្លួនរហូត ។ ណារ៉ុង រស់នៅជាមួយម្តាយ និងបងប្អូនតូចៗបីនាក់ប៉ុណ្ណោះ ។

ខ្មែរក្រហមបានបញ្ជូនម្តាយ និងបងប្អូនរបស់ ណារ៉ុង ឲ្យទៅរស់នៅភូមិទូនរុន ស្រុកភ្នំសំពៅ ដែលជាកន្លែងសម្រាប់ឲ្យស្ត្រីមេម៉ាយរស់នៅ ។ នៅទីនោះ ណារ៉ុង ត្រូវបានអង្គការចាត់តាំងឲ្យទៅក្នុងកងចល័តភាគ ដែលមានសមាជិកសរុបជាង៣០នាក់ ធ្វើស្រែ និងក្រោយមកទៅលើកទំនប់នៅអាងកំពីងពួយ ។

ទៅដល់ទីនោះដំបូង មេកងបានប្រើ ណារ៉ុង ឲ្យដាំបាយសម្រាប់កងចល័ត ។ ជាញឹកញាប់ ណារ៉ុង ដាំបាយឆៅ ប៉ុន្តែក្រោយមកទើបគាត់បេះវិធីដាំបាយក្នុងខ្ទះត្នោត ។ ក្នុងមួយថ្ងៃ ណារ៉ុង ដាំបាយម្តៃខ្ទះត្នោត គឺព្រឹកដប់ និងល្ងាចដប់ ។ រាល់ថ្ងៃ ណារ៉ុង ត្រូវនៅជាប់នឹងកំដៅចង្ក្រាន ដូច្នេះហើយទើបគាត់សុំមេកងផ្លាស់ទៅធ្វើការលើកទំនប់វិញ ។ ណារ៉ុង ត្រូវធ្វើការងារធ្ងន់ៗដូចជា កាប់គាស់ លីសែង ហើយត្រូវធ្វើការចាប់តាំងពីម៉ោងប្រាំព្រឹករហូតដល់ម៉ោងប្រាំមួយល្ងាចទើបឈប់សម្រាក ។

អ្នកដែលធ្វើការលើកទំនប់នេះភាគច្រើនជាប្រជាជនថ្មីដែលខ្មែរក្រហមចាត់ទុកថាខ្ជិលច្រអូស និងស្តីបន្ទោសអ្នកទាំងនោះថា «ម៉េច! មិត្តឯងនៅជាប់កម្លែលចាស់! មិត្ត អត់ចង់បញ្ចេញពលកម្មបុ!» រួចហើយហៅមកប្រជុំទិតៀន ។ ទោះជាត្រូវជេរស្តីយ៉ាងណា ក៏ ណារ៉ុង មិនដែលហ៊ានតវ៉ាដែរ ហើយគាត់រឹតតែខិតខំធ្វើការងារថែមទៀត ។ ការដាក់ផែនការឲ្យលើកទំនប់ដែលមានគណៈស្រុកឈ្មោះ ឆាំ ជាអ្នកគ្រប់គ្រងនៅទីនោះ បានបណ្តាលឲ្យប្រជាជនស្លាប់យ៉ាងច្រើន ។ ណារ៉ុង ធ្វើការនៅទំនប់នេះរហូតដល់របបខ្មែរក្រហមដួលរលំ ទើបគាត់វិលត្រឡប់ទៅជួបជុំម្តាយ និងបងប្អូនវិញ ។ ប៉ុន្តែគាត់បានបាត់ប្អូនប្រុសម្នាក់ ចំណែកប្អូនប្រុសម្នាក់ទៀតបានស្លាប់ដោយសារជំងឺ ។

**ម៉ម សុវណ្ណ**



ណារ៉ុង ធ្វើបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

# ពិធីសម្ពោធពាក្យស្លោក និងចែកសៀវភៅនៅវិទ្យាល័យ











# ័យ ហ៊ុន សែន មណ្ឌលគិរី ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១












# វគ្គបណ្តុះបណ្តាលស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប







# ាធិបតេយ្យ (១៩៧៥-១៩៧៩) នៅបណ្ឌិត្យសភានគរបាលកម្ពុជា











# "ខ្ញុំដឹងពីសិទ្ធិរបស់ខ្ញុំក្នុងការនៅស្ងៀមមិនឆ្លើយតប"

កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ជនជាប់ចោទក្នុងករណី០០២ អៀង សារី បានជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងថា ខ្លួននឹងមិនធ្វើការផ្ដល់សក្ខីកម្មទេ ។ អៀង សារី បានសម្រេចចិត្តបែបនេះដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់នៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា វិធានផ្ទៃក្នុង និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។



អៀង សារី នៅក្នុងសវនាការ (រូបថត ៖ អ.វ.ត.ក)

ដោយសម្អាងលើច្បាប់ខាងលើនេះ ជនជាប់ចោទ អៀង សារី ដែលជាអតីតរដ្ឋមន្ត្រីការបរទេសកាលពីរបបកម្ពុជាប្រជាធិបតេយ្យបានសម្រេចចិត្តនៅស្ងៀមដោយមិនឆ្លើយតបអ្វីទាំងអស់ទោះបីមានគេចោទសួរលើគាត់ក៏ដោយ ។ ជនជាប់ចោទរូបនេះបានរៀបរាប់ចំនួនប្រាំបួនចំណុចដូចខាងក្រោម ៖

១) បច្ចុប្បន្ននេះ ខ្ញុំត្រូវបានតំណាងឲ្យដោយមេធាវីការពារក្ដី ។

២) ខ្ញុំត្រូវបានគេជូនដំណឹងអំពីការចោទប្រកាន់ និងយល់ពីបទចោទប្រកាន់ប្រឆាំងនឹងខ្លួនខ្ញុំ ។

៣) ខ្ញុំត្រូវបានគេជូនដំណឹងអំពីទីកន្លែង និងការជិតមកដល់នៃការជំនុំជម្រះក្ដីរបស់ខ្ញុំ ។

៤) ខ្ញុំដឹងពីសិទ្ធិរបស់ខ្ញុំក្នុងការចូលរួមការពារដោយខ្លួនឯងផ្ទាល់ ។

៥) ខ្ញុំដឹងពីសិទ្ធិរបស់ខ្ញុំក្នុងការនៅស្ងៀមមិនឆ្លើយតបនៅគ្រប់សវនាការទាំងអស់នៅ អនាគត ។

៦) ខ្ញុំដឹងពីសិទ្ធិរបស់ខ្ញុំដែលត្រូវទទួលបានការកាត់សេចក្ដីដោយមានវត្តមានរបស់ខ្ញុំ ។

៧) ខ្ញុំដឹងពីសិទ្ធិរបស់ក្នុងការសួរចម្លើយ ឬសុំឲ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឲ្យមានវត្តមានសាក្សីទាំងនោះ ក្នុងនាមរបស់ខ្ញុំ ។

៨) ខ្ញុំដឹងពីសិទ្ធិរបស់ខ្ញុំក្នុងការទទួលបាននូវពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន ។

៩) ខ្ញុំដឹងពីសិទ្ធិរបស់ខ្ញុំក្នុងការទទួលបានការជំនុំជម្រះដោយមិនពន្យារពេល ។

សវនាការអង្គជំនុំជម្រះសំណុំរឿង០០២ចាប់ផ្ដើមនៅថ្ងៃទី២១ ខែវិច្ឆិកា ហើយសវនាការដើម្បីពិនិត្យលើភស្តុតាងបានចាប់ផ្ដើមនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ កន្លងទៅនេះ ។

**ញាណ សុជាតិ**

# សវនាការអង្គបុរេជំនុំជម្រះ ៖ សំណើបឋមនៃការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងកាយសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ

ពីថ្ងៃទី១៩ ដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ កន្លងទៅនេះ អង្គបុរេជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានរៀបចំសវនាការលើសំណើបឋមនៃការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើកាយសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមជំនុំជម្រះក្តី និង លទ្ធផលនៃរបាយការណ៍របស់អ្នកជំនាញបន្ថែមទៀតទាក់ទងទៅនឹងកាយសម្បទានោះ ។

**សំណើបឋមនៃការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី កិច្ចពិភាក្សាអំពីផលប៉ះពាល់នៃវិធាន៨៩ចំពោះការបំបែកសំណុំរឿងករណី០០២ត្រូវបានបិត**

ទោះបីជាសវនាការលើអង្គសេចក្តីនៅក្នុងករណី០០២នឹងមិនចាប់ដំណើរការរហូតដល់ថ្ងៃទី២១ ខែវិច្ឆិកា ក៏ដោយ ក៏អង្គបុរេជំនុំជម្រះបានស្ទុះស្ទែងក្នុងការបើកសវនាការ "បញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណង" តាមវិធានផ្ទៃក្នុង៨០ស្ទួន(៤)(៣) ។ គោលបំណងរបស់វិធាននេះគឺដើម្បីធានាអំពីសំណងដែលបានស្នើគឺមានលក្ខណៈ "សមូហភាពនិងប្រកបដោយសីលធម៌" អនុលោមទៅតាមវិធាន២៣ស្ទួន(៥) ។

ជាកិច្ចបើកដំបូង មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញនូវភាពអស់សង្ឃឹមចំពោះការចំណាយពេលវេលាទៅលើករណី០០២ នៅពេលដែលការសម្រេចសេចក្តីខទូរណ៍របស់ករណី០០១មិនទាន់សម្រេចនៅឡើយ ហើយនៅតែមានភាពមិនច្បាស់លាស់នូវអ្វីដែលការបំបែកសំណុំរឿងករណី០០២ ដោយអង្គបុរេជំនុំជម្រះអនុលោមតាមវិធានផ្ទៃក្នុង៨៩ស្ទួនប៉ះពាល់ទៅលើសំណើសំណង និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

ភាគីដើមបណ្តឹងរដ្ឋប្បវេណីក៏បានកត់សម្គាល់ឃើញដែរថា ខ្លួនមិនអាចផ្តល់ជូនដល់អង្គជំនុំជម្រះនូវសំណើចុងក្រោយ



*អៀង ធីរិទ្ធ នៅក្នុងសវនាការ (រូបថត ៖ អ.វ.ត.ក)*

ទាំងអស់មុននឹងអង្គសវនាការចាប់ផ្តើមនោះបានទេព្រោះភាគីដើមបណ្តឹងរដ្ឋប្បវេណីកំពុងតែទាក់ទងជាមួយដើមបណ្តឹងរដ្ឋប្បវេណីដែលទើបតែដាក់បញ្ចូលថ្មីៗ ហើយខ្លួនក៏កំពុងតែរង់ចាំដោយអន្ទះសាន្ទូវលទ្ធផលនៃការវិនិច្ឆ័យបណ្តឹងឧទ្ធរណ៍របស់ករណី០០១ដែរ ដែលលទ្ធផលនោះនឹងបង្កើតនូវយុត្តិសាស្ត្រក្នុងការទាមទារសំណងក្នុងករណី០០២ ។

ក្រោយពីការកត់សម្គាល់អំពីដែនកំណត់ទាំងអស់នេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា ទោះបីជាការបកស្រាយរបស់អង្គជំនុំជម្រះដែលផ្ទុយទៅនឹងការបង្គាប់បញ្ជាដាច់ដោយឡែករបស់ខ្លួនក៏ដោយ ក៏ការបំបែកសំណុំរឿងករណី០០២ជាសវនាការដាច់ដោយឡែកពីគ្នានិងមានផលប៉ះពាល់ដោយផ្ទាល់និងយ៉ាងចាំបាច់ដល់សំណង ។ ជាពិសេស មេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឲ្យមានការបកស្រាយទាក់ទងនឹងវិធីដែលអង្គជំនុំជម្រះមានបំណងដោះស្រាយទៅនឹងតម្រូវការដោយវិធាន២៣ស្ទួន(៥) ដែលសំណើសុំសំណងត្រូវ «ថ្លែងអំពីភាពខូចខាតដែលទទួលរង» នៅក្នុងវិសាលភាពកំណត់ណាមួយនៃសវនាការ០០២ដំបូង ។

ប៉ុន្តែបញ្ហានេះមិនត្រូវបានទទួលយកដោយអង្គជំនុំជម្រះទេ ហើយប្រធានអង្គជំនុំជម្រះ និល ណុន បានកាត់ការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឲ្យនៅខ្លីដោយផ្ញើការរំឭកដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីឲ្យបញ្ចេញយោបល់មានកំណត់ណាមួយក្នុងការផ្តល់ព័ត៌មានជាក់លាក់ទាក់ទងនឹងសំណើនៃការសុំសំណងដែលកំពុងតែទាមទារ ។

ជំហររបស់អង្គជំនុំជម្រះទាក់ទងនឹងបញ្ហាសំណងនេះមិនបានដាក់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគោលជំហរមិនជាក់លាក់នោះទេ ។ នេះដោយសារតែអង្គជំនុំជម្រះមិនបានផ្តល់ព័ត៌មានជាក់លាក់ណាមួយនៅឡើយទេទាក់ទងនឹងថាតើវិសាលភាពដែលមានដែនកំណត់នៃសវនាការករណី០០២ដំបូងនឹងមិនមានកំណត់ដ៏ជាក់លាក់ណាមួយនៃវិសាលភាពរបស់សំណង ។ ឧទាហរណ៍ បើសិនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ស្វែងរកសំណងទាក់ទងនឹងទីតាំងបទឧក្រិដ្ឋជាក់លាក់ណាមួយដែលបានបញ្ចូលទៅក្នុងករណី០០២ទូទៅ តែមិនមែននៅក្នុងអង្គសវនាការដំបូង វានៅតែមានលក្ខណៈមិនច្បាស់ដដែលត្រង់ថាតើការផ្តល់សំណងបែបនេះអាច «ឆ្លើយតបទៅនឹងភាពខូចខាតដែលបានទទួលរង» ដោយជនរងគ្រោះនៃបទឧក្រិដ្ឋកម្មដែលបញ្ជាក់ដោយការវិនិច្ឆ័យចុងក្រោយនៃករណី០០២ដែរឬយ៉ាងណា ។ ការបញ្ជាក់បន្ថែមទៅលើចំណុចនេះដោយអង្គជំនុំជម្រះនឹងមានភាពចាំបាច់ក្នុងការធ្វើដំណើរទៅមុខដើម្បីឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីយល់អំពីវិសាលភាពនៃសិទ្ធិរបស់ខ្លួន និងដើម្បីរៀបចំក្នុងការទាមទារសំណងបែបណាដើម្បីស័ក្តិសមតាមស្ថានភាពជាក់ស្តែង ។ ទោះជាយ៉ាងនេះក្តី ដើមបណ្តឹងរដ្ឋប្បវេណីបានចូលដល់ចំណុចសន្និដ្ឋាននៃការទាមទារសំណងដ៏មានសារសំខាន់ដែលខ្លួនមានគម្រោងនិងស្នើសុំក្នុងករណី០០២ ។

## ទិដ្ឋភាពទូទៅនៃសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីថ្មីៗ

នៅក្នុងចំណុចនេះ ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សំណើសុំសំណងចំនួនបួនប្រភេទគឺ

១) សុំឲ្យមានទិវារំឭកនិងការចងចាំនិង

២) ការស្តារលទ្ធភាពពលកម្ម និងសេវាថែទាំសុខភាព

៣) ការចងក្រងឯកសារ និងការអប់រំ និង

៤) គម្រោងផ្សេងទៀត

ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់យ៉ាងល្អិតល្អន់ទៅលើប្រភេទទូទៅទាំងនេះដោយផ្តល់នូវទិដ្ឋភាពរួមនៃគម្រោងជាច្រើនដែលកំពុងតែត្រូវបានពិចារណាថ្មីៗនេះ ។

### ១) គម្រោងរំឭកការចងចាំ

នៅក្រោមប្រធានបទនៃគម្រោងរំឭកការចងចាំ ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ពីគម្រោងរបស់ខ្លួនដូចខាងក្រោម៖

- គម្រោងការចារឈ្មោះអ្នកដែលបានស្លាប់ដោយរបបខ្មែរក្រហម
- គម្រោងសាងសង់ចេតិយ ឬស្តូបរំឭកវិញ្ញាណក្ខន្ធ ។
- គម្រោងតស៊ូមតិដើម្បីឲ្យមានថ្ងៃរំឭកការចងចាំជាតិដើម្បីទទួលស្គាល់បទឧក្រិដ្ឋដែលជនរងគ្រោះបានទទួលរង ។
- គម្រោងសាងសង់ចេតិយឬស្តូបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះដូចជាជនរងគ្រោះដោយការរៀបការដោយបង្ខំជាដើម ។

◆ គម្រោងចូលរួមក្នុងការថែរក្សាទីតាំងឧក្រិដ្ឋកម្ម ។

### ២) គម្រោងស្តារនីតិសម្បទាឡើងវិញនិងសេវាសុខភាព

នៅក្នុងគម្រោងស្តារនីតិសម្បទានិងសេវាសុខភាព ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់នូវគម្រោងដូចខាងក្រោមៈ

◆ ការបង្កើតមជ្ឈមណ្ឌលសុខភាពជាពិសេសដើម្បីផ្តល់ជាជំនួយដល់ជនរងគ្រោះដែលមានវ័យចំណាស់

◆ ផ្តល់សេវាកម្មសុខភាពផ្លូវចិត្តដល់ជនរងគ្រោះ


*អៀង ធីរិទ្ធ នៅក្នុងសវនាការ (រូបថត : អ.វ.ត.ក)*

◆ ផ្តល់លទ្ធភាពក្នុងការទៅរកសេវាកម្មសុខភាពសម្រាប់ប្រជាជនកម្ពុជាទូទៅនិងជនរងគ្រោះដែលទទួលបានប្រាក់កម្រៃទាប និង

◆ សម្របសម្រួលឲ្យមានក្រុមជួយខ្លួនឯង ដោយផ្តោតទៅលើការនាំជនរងគ្រោះដែលទទួលរងនូវបទឧក្រិដ្ឋនានាឲ្យជួបជុំគ្នា ។

### ៣) ការចងក្រងឯកសារ និងការអប់រំ

នៅក្នុងគម្រោងការចងក្រងឯកសារ និងការអប់រំ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់នូវគម្រោងដូចខាងក្រោមៈ

◆ គម្រោងថែរក្សាឯកសាររបបខ្មែរក្រហមនិងការយកឯកសារទាំងនោះទៅបង្រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅប្រទេសកម្ពុជា ដើម្បីអប់រំក្មេងជំនាន់ក្រោយ និងដើម្បីទប់ស្កាត់ការប្រព្រឹត្តអំពើឃោរឃៅបែបនេះទៀតនៅថ្ងៃអនាគត ។

◆ បញ្ចូលបទពិសោធន៍និងការវិនិច្ឆ័យទោសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទៅក្នុងកម្មវិធីសិក្សាអំពីរបបខ្មែរក្រហមថាជាកេរ្តិ៍ដំណែលរបស់តុលាការ និង

◆ បង្កើតសារមន្ទីរនិងបណ្ណាល័យដើម្បីតម្កល់ឯកសារប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជាដែលបើកជូនសាធារណជនចូលមើលដោយឥតគិតថ្លៃ និងបង្កើតកន្លែងដើម្បីឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រនិងបង្កើតឲ្យមានការពិភាក្សា ។

### ៤) គម្រោងផ្សេងៗ

ក្រោមគម្រោងផ្សេងៗនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់នូវគម្រោងដូចខាងក្រោមៈ

◆ បង្កើតសៀវភៅប្រវត្តិសាស្ត្រមួយដើម្បីឧទ្ទិសដល់ជនរងគ្រោះជាមួយនឹងបញ្ជីឈ្មោះអ្នកដែលបានស្លាប់ ដែលធ្វើជាសៀវភៅផង និងដាក់នៅលើប្រព័ន្ធអ៊ិនធើណេតផង ។

◆ បោះពុម្ពឈ្មោះរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំង

*អស់ក្នុងករណី០០២ និង*

◆ *សកម្មភាពនានាដែលសំដៅទៅរកការជួយក្រុមជនរងគ្រោះដូចជា ជនជាតិចាម ឬជនជាតិវៀតណាមដែលត្រូវបានជម្លៀសដោយបង្ខំពីប្រទេសកម្ពុជាដោយខ្មែរក្រហម ។*

*ភាគីដើមបណ្តឹងរដ្ឋប្បវេណីក៏បានពិភាក្សាអំពីដំណើរការអនុវត្តនិងបញ្ជាក់ម្តងទៀតអំពីបំណងរបស់ខ្លួនក្នុងការឲ្យមានការបង្កើតមូលនិធិមួយដែលអាចយកថវិកាស្ម័គ្រចិត្តមួយចំនួនដើម្បីជួយដល់សកម្មភាពសំណង ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីក៏បានកត់សម្គាល់ដែរថា ខណៈពេលដែលខ្លួនទទួលស្គាល់ថា ខ្លួនមិនអាចធ្វើសំណើជាក់លាក់ណាមួយទៅរាជរដ្ឋាភិបាលកម្ពុជាសម្រាប់សំណង ភាគីដើមបណ្តឹងរដ្ឋប្បវេណីនឹងចាំបាច់បញ្ចូលរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងវិធីណាមួយអំឡុងពេលនៃការអនុវត្តសកម្មភាពក្រោយពីមានការយល់ព្រម ។ ឧទាហរណ៍ដូចជារដ្ឋាភិបាលត្រូវតែផ្តល់ការអនុញ្ញាតឲ្យមានការសាងសង់គម្រោងរំឭកការចងចាំ ។*

*ភាគីដើមបណ្តឹងរដ្ឋប្បវេណីទំនងជាធ្វើឲ្យមានភាពស្រឡាំងកាំងក្នុងបណ្តាមេធាវីជាតិជាច្រើនរបស់សាលាក្តីខ្មែរក្រហមដោយស្នើឲ្យមានគម្រោងមួយដើម្បីជួយដល់ជនជាតិវៀតណាម សញ្ជាតិកម្ពុជាដែលត្រូវបានជម្លៀសដោយបង្ខំចេញពីប្រទេសដើម្បីដាក់ពាក្យសុំយកសញ្ជាតិកម្ពុជាឡើងវិញ ។ មេធាវីជាតិជាច្រើនបានផ្តល់យោបល់អវិជ្ជមានទាក់ទងទៅនឹងសំណើនេះ ហើយយោបល់នេះធ្វើឲ្យមានការលាបពណ៌ដល់ជាតិនិយមយ៉ាងពិតប្រាកដចំពោះជនជាតិវៀតណាម ដូចដែលមេធាវីមួយចំនួនបានបញ្ជាក់ថា ជនជាតិខ្មែរគឺជាជនរងគ្រោះនៃរបបខ្មែរក្រហមភាគច្រើន ហើយគួរតែមានការបែងចែកឲ្យច្បាស់ទាក់ទងទៅនឹងជនរងគ្រោះដែលជាមនុស្សលោកដូចគ្នា ។ តែសម្រាប់ការអង្កេតនេះ មេធាវីមួយចំនួនទំនងជាចង់បញ្ជាក់អំពីលទ្ធភាពនៃជនរងគ្រោះជនជាតិភាគតិចវៀតណាមនៃរបបខ្មែរក្រហមដែលកំពុងត្រូវបានផ្តល់ការគោតសរសើរឬចំណាត់ការពិសេស ។ យោបល់ទាំងនេះបង្កឲ្យមានជាបញ្ហានាពេលក្រោយ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាក់ទងទៅនឹងបទចោទប្រកាន់អំពើប្រល័យពូជសាសន៍ដែលត្រូវបានចោទប្រកាន់ទាក់ទងនឹងចំណាត់ការជនជាតិវៀតណាម និងជនជាតិចាម ដោយសារតែតម្រូវការនៃបំណងដ៏ជាក់ជាក់នៃបទឧក្រិដ្ឋ ។ វាអាចទៅរួចត្រង់ថា ជនជាតិខ្មែរច្រើននាក់នឹងមានអារម្មណ៍ថា ការទទួលរងរបស់ខ្លួនកំពុងត្រូវបានចាត់ទុកថាមិនសូវសំខាន់ព្រោះប្រជាជនខ្មែរមិនត្រូវបានចាត់ទុកថាជាជនរងគ្រោះនៃរបបប្រល័យពូជសាសន៍ទេ តែជាជនគ្រោះនៃបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតែមួយមុខគត់ ។*

### សម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមជំនុំជម្រះក្តី

*នៅរសៀលថ្ងៃទី១៩ ខែតុលា អង្គបុរេជំនុំជម្រះបានបង្វែរមករកបញ្ហាទាក់ទងនឹងកាយសម្បទារបស់ អៀង ធីរិទ្ធ វិញក្នុងការចូលរួមជំនុំជម្រះក្តី ។ អង្គសវនាការនោះមានការចោទសួរជាសំណួរទៅកាន់អ្នកជំនាញផ្តល់ប្រឹក្សាសុខភាពផ្លូវចិត្ត និងការអះអាងតវ៉ារបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ បញ្ហានេះគឺជារឿងសំខាន់មួយនៅក្នុងប៉ុន្មានខែថ្មីៗនេះ ខណៈពេលដែលកាយសម្បទារបស់ អៀង ធីរិទ្ធ ត្រូវបានមើលឃើញថាស្ថិតនៅក្នុងស្ថានភាពធ្ងន់ធ្ងរដែលជាលទ្ធផលនៃរោគសញ្ញាវិកលចរិតរបស់គាត់ ។ តាមលំដាប់លំដោយកម្មវិធីនៅសាលាក្តីខ្មែរក្រហមនោះ អង្គជំនុំជម្រះបានរាយឈ្មោះប្រធានបទមួយចំនួនដែលអង្គជំនុំជម្រះស្វះស្វែងរកអំឡុងពេលអង្គសវនាការ ។ ក្នុងនោះរួមមានៈ*

*១) តើជនជាប់ចោទមួយរូបអាចត្រូវបានចាត់ទុកថាពុំមានសម្បទាផ្នែកបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដែរឬទេ ដោយគ្រាន់តែរកឃើញថា លក្ខណៈវិនិច្ឆ័យមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យនានាដូចដែលបានបង្ហាញនៅសំណុំរឿងស្ទ្រូហ្គា* (Strugar) *ត្រូវបានបំពេញនោះ ឬមួយក៏ត្រូវពិនិត្យលក្ខណៈវិនិច្ឆ័យទាំងអស់រួមបញ្ចូលគ្នានៅពេលធ្វើការវាយតម្លៃសម្បទាជនជាប់ចោទ?*

*២) តើការធ្លាក់ចុះខ្សោយធ្ងន់ធ្ងរផ្នែកប្រព័ន្ធប្រសាទរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែលសាស្ត្រាចារ្យ ចន ខាំបែល និងអ្នកជំនាញវិកលវិទ្យាបានរកឃើញ ធ្វើឲ្យជនជាប់ចោទរូបនេះគ្មានលទ្ធភាពអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ស្របតាមបទដ្ឋានតម្រូវចាំបាច់នៅក្នុងសំណុំរឿងស្ទ្រូហ្គា មែនឬទេ?*

*៣) តើកម្រិតនៃការធ្លាក់ចុះខ្សោយធ្ងន់ធ្ងរផ្នែកសមត្ថភាព*

របស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការឆ្លើយសំណួរណែនាំ មេធាវីផ្តល់សក្ខីកម្មយល់ពីប្រភេទនៃបទចោទ និងដំណើរការនីតិវិធី យល់លម្អិតពីភ័ស្តុតាង និងលទ្ធផលនៃកិច្ចដំណើរការនីតិវិធី បញ្ជាក់ថា ជនជាប់ចោទរូបនេះពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដែរឬទេដោយពិចារណាទៅលើកត្តាដែលថា ជនជាប់ចោទ មានមេធាវីតំណាង និងអាចអនុវត្តសិទ្ធិទាំងអស់នេះបានមួយផ្នែកតាមរយៈមេធាវីរបស់ខ្លួននោះ?

៤) ដូចដែលអ្នកជំនាញទាំងអស់បានរកឃើញថាស្ថានភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ គឺកាន់តែទ្រុឌទ្រោមទៅៗ និងអាចពន្យារពេលកិច្ចដំណើរការនីតិវិធីមិនឈប់ឈរ ដូចជាត្រូវពិនិត្យបន្ថែម ឬជាប្រចាំថ្ងៃ ឬស្ថានភាពប្រចាំថ្ងៃរបស់គាត់មិននឹងនជាដើម ។ ដោយសារកត្តាទាំងអស់នេះ អាចប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទផ្សេងទៀត ក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័ស និងអូសបន្លាយកិច្ចដំណើរការនីតិវិធីលើសំណុំរឿងលេខ០០២ទាំងមូល តើភាគីយល់ឃើញថាជាផលប្រយោជន៍នៃយុត្តិធម៌ដែរឬទេ ដែលត្រូវបំបែកជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីដំណើរការនីតិវិធីទាំងនេះ ដោយអនុលោមតាមវិធាន៨៩ស្ទួន(២) (ដូចជាជម្រើសដើម្បីបញ្ចប់កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទ អៀង ធីរិទ្ធ នៅពេលជនជាប់ចោទត្រូវបានរកឃើញថាពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ)?

៥) តើបច្ច័យអ្វីខ្លះចំពោះជនជាប់ចោទ អៀង ធីរិទ្ធ ដែលអាចកើតចេញពីការបំបែកកិច្ចដំណើរការនីតិវិធីដោយអនុលោមតាមវិធាននេះ?

ប្រធានបទនៃការជជែកដេញដោលដែលបានគ្រោងទុកបញ្ជាក់ថា អង្គបុរេជំនុំជម្រះមានមន្ទិលសង្ស័យជាខ្លាំងថា បច្ចុប្បន្ននេះ អៀង ធីរិទ្ធ មានកាយសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមជំនុំជម្រះក្តី ហើយ អៀង ធីរិទ្ធ កំពុងតែស្វះស្វែងរកវិធីដ៏ល្អបំផុតមួយដើម្បីជំរុញការងារទាំងនោះឲ្យទៅមុខ ។ ផ្នែកនៃអង្គសវនាការនេះបានបើកឡើងជាមួយនឹងការចោទជាសំណួរទៅកាន់សាក្សីជំនាញទាំងពីនាក់ដោយចៅក្រមអង្គជំនុំជម្រះ ។ ក្រោយពីចៅក្រម និល ណុន ចោទសួរពីទិដ្ឋភាពទូទៅនៃវិជ្ជាជីវៈរបស់សាក្សីជំនាញទាំងពីរដែលនឹងត្រូវធ្វើសក្ខីកម្មតាងនាមឲ្យអ្នកជំនាញបួននាក់ផ្សេងទៀត ចៅក្រម ខាត់ហ្វ្រាំយត៍ ចាប់ផ្តើមចោទសំណួរ ។ ដំណាក់កាលដំបូងនៃការចោទជាសំណួរនោះ ចៅក្រម ខាត់ហ្វ្រាំយត៍ បានរៀបរាប់ពីទិដ្ឋភាពទូទៅនៃដំណើរការក្តី ហើយក្រោយមកអ្នកជំនាញបកស្រាយពីការសន្និដ្ឋានជារួម ។ អ្នកជំនាញបានធ្វើការត្រួតពិនិត្យជនជាប់ចោទ អៀង ធីរិទ្ធ ចំនួនបីដងក្នុងខែកញ្ញា ហើយបានធ្វើការប្រឹក្សារាល់ព័ត៌មានដែលអាចយកបានទាក់ទងនឹងលក្ខខណ្ឌសុខភាពរបស់ជនជាប់ចោទ ។ នៅក្នុងកម្រិតមួយ អ្នកជំនាញបានយល់ស្រប និងអះអាងដូចជាទៅនឹងការប្រឹក្សារបស់អ្នកជំនាញ ចន ខាំប៉ែល ដែលបានប្រឹក្សាកាលពីលើកមុន ហើយអ្នកជំនាញហាក់បីដូចជាអះអាងដូចគ្នាទៅនឹងរោគសញ្ញាវិកលចរិតដូចការអះអាងរបស់ ចន ខាំប៉ែល ។

យោងតាមយោបល់រួមរបស់អ្នកជំនាញបានឲ្យដឹងថា រោគសញ្ញាចាំបាច់ទាំងអស់នៃជំងឺវង្វេងវង្វាន់ ត្រូវបានរកឃើញថាបានកើតឡើងចំពោះ អៀង ធីរិទ្ធ ។ អ្នកជំនាញបានកត់សម្គាល់ឃើញថា មានពេលមួយនោះ អៀង ធីរិទ្ធ ហាក់បីដូចជាមានអារម្មណ៍មូល និងមានសម្តតភាពច្រើនគួរសម ទោះបីជាពេលនោះ អៀង ធីរិទ្ធ ហាក់បីដូចជាឃ្លាតចាកឆ្ងាយពីប្រធានបទដែលកំពុងតែជជែកគ្នា ហើយបានធ្វើការផ្តល់យោបល់ប្រកបដោយភាពច្របូកច្របល់ ។

អ្នកជំនាញក៏បានផ្តល់យោបល់ដែរថា ការចងចាំរបស់ អៀង ធីរិទ្ធ កំពុងតែមានការធ្លាក់ចុះ ហើយថ្មីៗនេះគាត់បានការលំបាកក្នុងការរកនឹកសមាជិកក្រុមគ្រួសារជិដិតស្និទ្ធរបស់ខ្លួនដូចជាកូន ម្តាយ ប្តីឈ្មោះ អៀង សារី ដែលជាជនជាប់ចោទដូចគ្នាដែលពេលនោះ អៀង ធីរិទ្ធ និយាយថា អៀង សារី គឺជាបងប្រុសរបស់ខ្លួនទៅវិញ ។

អ្នកជំនាញបានធ្វើការសន្និដ្ឋានផងដែរថា វាជារឿង «មិនទំនងសោះ» ដែលថា អៀង ធីរិទ្ធ អាចធ្វើពុតថាមានជំងឺវង្វេងវង្វាន់នោះ ។ អ្នកជំនាញទាំងអស់នោះបានធ្វើការពន្យល់ថា ខ្លួនជឿថា អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់ព្រោះសមត្ថភាពចងចាំរបស់ អៀង ធីរិទ្ធ មានការប្រែប្រួល ហើយពេលខ្លះស្ថានភាពរបស់ជនជាប់ចោទម្នាក់នេះក៏មានលក្ខណៈប្រសើរឡើងខ្លះដែរអំឡុងពេលនៃការវិនិច្ឆ័យរោគនោះ ។ អ្នកជំនាញបានផ្តល់យោបល់ថា

ការព្យាយាមដោយចេតនាដើម្បីកំណត់ថាមានជំងឺវង្វេងវង្វាន់ អាចទាក់ទងគំរូស៊ីគ្នាទៅនឹងការសម្តែងអាកប្បកិរិយាខុសពីប្រក្រតី ទៅលើការធ្វើពិសោធន៍វាយតម្លៃ ជាជាងការធ្វើពិសោធន៍ទៅលើការប្រែប្រួល ជាពិសេសទាក់ទងទៅនឹងអំឡុងពេលដែលអាកប្បកិរិយាមានការប្រសើរឡើង ។ ប៉ុន្តែ អ្នកជំនាញបានធ្វើការកត់សម្គាល់ថា ជារឿងមិនអាចធ្វើទៅរួចទេដែលថា "ពិតមួយរយភាគរយ" ត្រង់ថា អៀង ធីរិទ្ធ មិនមានជំងឺវង្វេងវង្វាន់នោះ ។

អ្នកជំនាញក៏មានយោបល់ផងដែរថា ស្ថានភាពជំងឺវង្វេងវង្វាន់របស់ អៀង ធីរិទ្ធ ចាប់កើតមានឡើងតាំងពីឆ្នាំ២០០៩ មកម្ល៉េះ ហើយអ្នកជំនាញទាំងនោះបានផ្តល់ជាអនុសាសន៍ថា បុគ្គលិករបស់សាលាក្តីខ្មែរក្រហមដែលត្រូវថែទាំ អៀង ធីរិទ្ធ គួរតែមានចំណេះដឹងពីលទ្ធភាពនិងអារម្មណ៍ឡើងចុះ ហើយគួរតែរៀបចំជាសកម្មភាពមួយចំនួនដែលអាចធ្វើឲ្យ អៀង ធីរិទ្ធ សប្បាយចិត្ត ដូចជាទទួលបានកាសែតដើម្បីអានរាល់ថ្ងៃ និងបានជួបជាមួយអ្នកមកសួរសុខទុក្ខជាដើម ។

អ្នកជំនាញត្រូវបានសួរឲ្យពិចារណាទៅលើចំនួនប្រាំ និងធ្វើការផ្តល់យោបល់ទៅលើចំណុចទាំងប្រាំនោះតាមលំដាប់ៈ

១) តើ អៀង ធីរិទ្ធ យល់ដឹងពីលក្ខណៈនៃបទល្មើសដែលបានចោទមកលើខ្លួនដែរឬទេ?

២) អាចយល់ដឹងពីកិច្ចដំណើរការនីតិវិធីតុលាការ (សិទ្ធិផ្សេងៗ) ដែរឬទេ?

៣) អាចពន្យល់ប្រាប់មេធាវីរបស់ខ្លួនពីអង្គហេតុនិងភ័ស្តុតាងដែលអាចមាន បានដែរឬទេ?

៤) អាចផ្តល់សក្ខីកម្មបានដែរឬទេ?

៥) អាចយល់ដឹងពីផលវិបាកនិងលទ្ធផលនៃកិច្ចដំណើរការនីតិវិធីបានដែរឬទេ?

### ១) ការយល់ដឹងពីលក្ខណៈនៃបទល្មើសដែលបានចោទមកលើខ្លួន

អ្នកជំនាញបានផ្តល់មតិថា អៀង ធីរិទ្ធ មិនមានសមត្ថភាពនិងយល់ដឹងអំពីបទឧក្រិដ្ឋដែលបានចោទប្រកាន់មកលើខ្លួនទេ នៅក្នុងលក្ខណៈទូទៅនិងមានកំណត់ ។ នេះដោយសារតែតាមរយៈការធ្វើសម្ភាសន៍ជាមួយជនជាប់ចោទកន្លងមក អៀង ធីរិទ្ធ បានធ្វើការបញ្ជាក់អំពីការយល់ដឹងពីបទឧក្រិដ្ឋដែលបានចោទប្រកាន់ ។ ឧទាហរណ៍ជាក់ស្តែងដូចជា មានពេលមួយ អៀង ធីរិទ្ធ បានបញ្ជាក់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពិតជាមានលក្ខណៈធ្ងន់ធ្ងរណាស់ ។ អៀង ធីរិទ្ធ ក៏បានធ្វើការឲ្យយោបល់មួយផ្សេងទៀតអំពីការសម្លាប់ អំពើប្រល័យពូជសាសន៍ ការធ្វើទារុណកម្ម និងអំពើរុករានសាសនា ដែលជនជាប់ចោទរូប នេះបានបង្ហាញនូវការយល់ដឹងតិចតួចខ្លះៗអំពីទស្សនៈផ្លូវច្បាប់សំខាន់ៗចំពោះបទចោទប្រកាន់ដែលគាត់កំពុងតែប្រឈមមុខនាពេលថ្មីៗនេះ ។ ប៉ុន្តែ វាបានបង្ហាញឲ្យឃើញច្បាស់ថា ការយល់ដឹងផ្នែកច្បាប់ ដែល អៀង ធីរិទ្ធ មានគឺនៅមានកម្រិតតិចតួច ។

### ២) ការយល់ដឹងពីកិច្ចដំណើរការនីតិវិធីតុលាការ

ទាក់ទងទៅនឹងបញ្ហាទីពីរនេះ អ្នកជំនាញបានរកឃើញថា អៀង ធីរិទ្ធ មានការលំបាកតិចតួចមួយចំនួនទាក់ទងទៅនឹងដំណើរការនីតិវិធី និងជាពិសេសគឺបញ្ហាប្រទាំងប្រទើសគ្នា ។ អ្នកជំនាញបានផ្តល់យោបល់ថា អៀង ធីរិទ្ធ មិនអាចយល់ដឹង និងចងចាំព័ត៌មានយូរល្មម សម្តែង និងតបតភ្លាមៗបានទេ ។ ហេតុដូច្នេះ អ្នកជំនាញបានធ្វើការសន្និដ្ឋានថា បច្ចុប្បន្ននេះ អៀង ធីរិទ្ធ មិនអាចមានសមត្ថភាពយល់ដឹងពីកិច្ចដំណើរការនីតិវិធីតុលាការបានទេ ដែលប្រហែលជាអាចធ្វើឲ្យ អៀង ធីរិទ្ធ មានការលំបាកក្នុងការចូលរួមក្នុងដំណើរការសវនាការឲ្យត្រឹមត្រូវតាមបទដ្ឋានអន្តរជាតិ ដូចដែលបានបញ្ជាក់នៅក្នុងករណី ស្រ្វហ្គា ។

### ៣) ការពន្យល់ប្រាប់មេធាវីរបស់ខ្លួនពីអង្គហេតុ និងភ័ស្តុតាងដែលអាចមាន

អ្នកជំនាញរកឃើញថា តាមស្ថានភាពទូទៅ អៀង ធីរិទ្ធ អាចមានលទ្ធភាពធ្វើការសហការជាមួយមេធាវីរបស់ខ្លួនបាន ដែល អៀង ធីរិទ្ធ មានជំនឿថា មេធាវីទាំងនោះកំពុងជួយខ្លួន ។ ទោះជាយ៉ាងនេះក៏ដោយ អ្នកជំនាញបានផ្តល់យោបល់បន្ថែមទៀតថា អៀង ធីរិទ្ធ អាចមានការលំបាកក្នុងការចងចាំ និងទំនាក់ទំនងដែលជាឧបសគ្គសម្រាប់ខ្លួនគាត់ក្នុងការចូលរួមដោយសកម្មនៅក្នុងដំណើរការការពារក្តីរបស់ក្រុមរបស់ខ្លួន ។

### ៤) ការផ្តល់សក្ខីកម្ម

អ្នកជំនាញបានផ្តល់យោបល់ថា អៀង ធីរិទ្ធ អាចយល់

និងឆ្លើយសំណួរជាទូទៅបានភាគច្រើន ។ ប៉ុន្តែ អ្នកជំនាញក៏បានកត់សម្គាល់ឃើញថា នេះមិនមានន័យថា ចម្លើយដែល អៀង ធីរិទ្ធ ផ្តល់ឲ្យគឺត្រឹមត្រូវនឹងចំណុចនោះទេ ។ អៀង ធីរិទ្ធ មើលទៅប្រហែលជាអាចនឹងតាមដានដំណើរការនៃការសាកសួរបាន ប៉ុន្តែមើលទៅមិនទំនងថា អៀង ធីរិទ្ធ អាចនឹងផ្តល់ចម្លើយទៅនឹងសំណួរដែលនឹងសួរមកលើគាត់ ដែលអាចមានតម្លៃជាភ័ស្តុតាងឬក៏អត់នោះទេ ។

### ៥) ការយល់ដឹងពីផលវិបាកនិងលទ្ធផលនៃកិច្ចដំណើរការនីតិវិធី

អៀង ធីរិទ្ធ អាចនឹងធ្វើការយល់ដឹងបានពីផលលំបាកនិងលទ្ធផលនៃការយកឃើញថា "ឆ្កួត" ឧទហរណ៍ដូចជា (ភាពល្ងីល្ងើ) នៅពេលដែលបង្ហាញអត្ថបទមួយដែលបញ្ជាក់ថា គាត់មានជំងឺ *dementia* ។ ប៉ុន្តែ អៀង ធីរិទ្ធ បដិសេធមិនព្រមឆ្លើយតបឬពិភាក្សាអំពីទោសនិងលទ្ធភាពនៃការជាប់ពន្ធនាគាក្នុងរយៈពេលណាមួយ ។ អ្នកជំនាញក៏មិនអាចធ្វើការសន្និដ្ឋានច្បាស់លាស់ទេថា ការបដិសេធរបស់ អៀង ធីរិទ្ធ គឺដោយសារតែកង្វះខាតនៃការយល់ដឹងឬមកពីភាពច្របូកច្របល់នៃការភ័ន្តភាំង និងកំហឹងចំពោះអ្វីដែលបានចោទប្រកាន់មកលើខ្លួនគាត់ ។

### ការសន្និដ្ឋានរបស់អ្នកជំនាញដែលមានលក្ខណៈ "គុណភាពត្រឹមត្រូវ" ៖ អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់នឹងចូលរួមក្នុងដំណើរការសវនាការ

អ្នកជំនាញបានទាញសេចក្តីសន្និដ្ឋានថា សេចក្តីសម្រេចចិត្តរបស់តុលាការទាក់ទងនឹងសម្បទារបស់ អៀង ធីរិទ្ធ និង "មានគុណភាពត្រឹមត្រូវ" តែអ្នកជំនាញនោះក៏បានបញ្ជាក់ដែរថា ដោយឈរលើ "គុណភាពនៃភាពអាចធ្វើទៅបាន" ។ យោបល់ជាឯកច្ឆន្ទរបស់អ្នកជំនាញគឺថា អៀង ធីរិទ្ធ មានកង្វះខាតសមត្ថភាពផ្លូវចិត្តគ្រប់គ្រាន់ល្មមក្នុងការតាមដានកិច្ចដំណើរការ នៅក្នុងចំណុចនេះនាពេលអនាគត ។ អ្នកជំនាញក៏បានធ្វើការសន្និដ្ឋានបន្ថែមទៀតដែរថា ជម្រើសនៃការថែទាំដែលអាចមាន "មិនទំនងជា" ធ្វើឲ្យ អៀង ធីរិទ្ធ មានសម្បទានាពេលណាមួយនាថ្ងៃអនាគតទេ ។

ក្រោយមក ចៅក្រម ខាត់វ្រ៉ាយត៍ បានសួរសំណួរទាក់ទងទៅនឹងសេណារីយ៉ូនាថ្ងៃអនាគតដែលអាចកើតមាន ។ ទាក់ទងនឹងសំណួរនេះ អ្នកជំនាញបានផ្តល់មតិថា លក្ខខណ្ឌរបស់ អៀង ធីរិទ្ធ អាចទំនងជាមានការរំខានដល់សវនាការសំណុំរឿង ០០២ដែលគួរតែអាចរកឃើញថាមានកាយសម្បទាគ្រប់គ្រាន់ ព្រោះសមត្ថភាពនៃការយល់ដឹងប្រែប្រួល ហើយ អៀង ធីរិទ្ធ អាចនឹងត្រូវការជំនួយយូរអង្វែងពីមេធាវីការពារក្តីរបស់ខ្លួន ។

អ្នកជំនាញបានផ្តល់គំនិតបន្ថែមទៀតថា ជារឿងមានប្រយោជន៍ក្នុងការពិនិត្យមើលការយល់ ប្រហែលជារៀងរាល់បីខែម្តងដើម្បីវាយតម្លៃអំពីកម្រិតនៃការផ្លាស់ប្តូរចំពោះលក្ខខណ្ឌរបស់ខ្លួន ដែលជាហេតុធ្វើឲ្យមានការពន្យឺតដល់ដំណើរការសវនាការករណី០០២ ។

បន្ទាប់ពីចៅក្រម ខាត់វ្រ៉ាយត៍ បញ្ចប់ការសួរនាំទូទៅទៅកាន់អ្នកជំនាញ ចៅក្រមរបស់អង្គជំនុំជម្រះផ្សេងទៀតត្រូវបានផ្តល់ឱកាសដើម្បីសួរសំណួរបន្ថែមទៅកាន់អ្នកជំនាញ ។

អ្នកជំនាញត្រូវបានសួរនាំអំពីកម្រិតនៃស្ថានភាពធ្លាក់ចុះរបស់ អៀង ធីរិទ្ធ តាំងពីឆ្នាំ២០០៩មក ហើយអ្នកជំនាញក៏បានឆ្លើយថា អាចមាន "ការរីកចម្រើនខ្លះ" ប៉ុន្តែគ្មានវិធីណាមួយដែលអាចដឹងពីការពិតនៃជំហានដែលបុគ្គលម្នាក់ៗនិងធ្លាក់ចុះបានទេ ពេលដែលបុគ្គលនោះត្រូវបានយកឃើញថាមានជំងឺវង្វេងវង្វាន់ ។ អ្នកជំនាញក៏បានបញ្ជាក់ផងដែរថា មាន "ភ័ស្តុតាងនៃការធ្លាក់ចុះ" នៅក្នុងស្ថានភាពរបស់ អៀង ធីរិទ្ធ ។ អ្នកជំនាញក៏បានបញ្ជាក់ឡើងវិញថា ជំងឺបាត់បង់ស្មារតីនិងបន្តឲ្យមានការធ្លាក់ចុះទូទៅដែលសម្គាល់ដោយស្ថានភាពជំងឺមនុស្សចាស់ចេះតែកើនឡើង ហើយអ្នកជំនាញបានកត់សម្គាល់ឃើញថា ខ្លួនបានធ្វើការសាកល្បងនៃការដែលអាចត្រឡប់បាន និងលទ្ធភាពផ្សេងទៀតនៃបុព្វហេតុផ្សេងទៀតនៃជំងឺមនុស្សចាស់ ហើយអ្នកជំនាញមិនបានរកឃើញភ័ស្តុតាងដូច្នេះនៃបុព្វហេតុដែលអាចកើតមានឡើងទេ ។

អ្នកជំនាញត្រូវបានសួរឲ្យផ្តល់យោបល់អំពីរោគសញ្ញានៃសកម្មភាពឆ្កួតវង្វេងរបស់ អៀង ធីរិទ្ធ ។ អ្នកជំនាញបានបញ្ជាក់ថា ខ្លួនមិនបានរកឃើញភ័ស្តុតាងនៃភាពភាន់ភាំង ហើយអ្នកជំនាញក៏បានបកស្រាយដែរថា យោបល់ដែលផ្តល់ឡើងដោយ អៀង ធីរិទ្ធ ដែលបានបកស្រាយថាអាចមានជំងឺឆ្កួតអាចនឹង

បកស្រាយបានថាមានការឆ្លើយតបជាធម្មតា ឧទាហរណ៍ ៈ ការហៅជនដែលជាប់ចោទដូចគ្នាថាជា «ជនក្បត់» ។

ថ្ងៃទីមួយនៃសវនាការបានបញ្ចប់ដោយករណីប្រឆាំងនឹង អៀង ធីរិទ្ធ មានការសង្ស័យស្រពេចស្រពិលនៅឡើយ ។

ថ្ងៃទីពីរនៃដំណើរការសវនាការបានចាប់ផ្តើមដោយអវត្តមានរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ ក្រុមការពារក្តីរបស់ អៀង ធីរិទ្ធ បានបញ្ជាក់ថា អៀង ធីរិទ្ធ មិនអាចនឹងបង្ហាញខ្លួននៅក្នុងបន្ទប់សវនាការបានទេដោយសារបញ្ហាសុខភាពរបស់គាត់ ។ តែក្រុមការពារក្តីនោះបានបញ្ជាក់ផងដែរថា ខ្លួនមានសិទ្ធិ និងតំណាងឲ្យជនជាប់ចោទនៅក្នុងបន្ទប់សវនាការនេះ ។ អង្គជំនុំជម្រះបានកត់សម្គាល់ពីសិទ្ធិរបស់មេធាវីការពារក្តី ហើយបានផ្តល់សិទ្ធិនេះទៅក្រុមការពារក្តីដើម្បីចោទសួរ ។

អំឡុងពេលនៃការចោទសួរដោយក្រុមការពារក្តី អ្នកជំនាញបានបញ្ជាក់ថា សេចក្តីសន្និដ្ឋានរបស់ខ្លួនមានលក្ខណៈស្រដៀងគ្នាទៅនិងសេចក្តីសន្និដ្ឋានរបស់សាស្រ្តាចារ្យ ខាំប៊ែល ដែរ ។ អ្នកជំនាញក៏បានពន្យល់ថា ក្រោយពីតាមធ្វើតាមដំបូន្មានរបស់អ្នកជំនាញ ខាំប៊ែល ដោយកាត់បន្ថយចំនួនថ្នាំពេទ្យដែល អៀង ធីរិទ្ធ ត្រូវប្រើប្រាស់ មិនឃើញមានការផ្លាស់ប្តូរអ្វីមួយចំពោះតួនាទីការយល់ដឹងរបស់គាត់ទេ ។

អ្នកជំនាញក៏បានធ្វើការសង្កេតឃើញដែរថា តួនាទីការយល់ដឹងរបស់ អៀង ធីរិទ្ធ មាន «ការធ្លាក់ចុះមធ្យមតាំងពីការធ្វើពិសោធន៍ជំងឺតាំងពីតំណាក់កាលដំបូងមក» ។

អ្នកជំនាញបានបញ្ជាក់ឲ្យច្បាស់ថា ទោះបីជាខ្លួនមានជំនឿថា អៀង ធីរិទ្ធ អាចមានលទ្ធភាពល្មមក្នុងការបំពេញតម្រូវការនៃផ្នែកខ្លះរបស់ ស្រ្តហ្គា ក៏ដោយ ក៏ខ្លួននៅមានគំនិតថា អៀង ធីរិទ្ធ មិនអាចមានលទ្ធភាពយល់ដឹង និងតាមដំណើរការក្តីប្រឆាំងមកលើខ្លួននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានទេដោយសារតែការចុះខ្សោយខាងការចងចាំរបស់ខ្លួន ។

ការចោទសួរក៏បានផ្តល់ជាពន្លឺដល់អាកប្បកិរិយាចម្លែកខ្លះៗរបស់ អៀង ធីរិទ្ធ ដែលអាការនេះបាន បង្ហាញឲ្យឃើញកាលពីពេលថ្មីៗនេះ ។ អំឡុងពេលនៃការធ្វើសម្ភាសន៍ អៀង ធីរិទ្ធ បានគិតថាវេជ្ជបណ្ឌិតគឺជាសមាជិកគ្រួសាររបស់ខ្លួន ហើយ អៀង ធីរិទ្ធ បានច្រឡំនិងផ្តល់មតិដែលមានលក្ខណៈចម្លែកៗអំឡុងពេលនៃការធ្វើការវាយតម្លៃ ។

ក្រោយពីក្រុមការពារក្តីធ្វើការសួរសំណួររបស់ខ្លួន ព្រះរាជអាជ្ញាមានឱកាសនិងចោទជាសំនួរទៅកាន់អ្នកជំនាញ ។ ដូចគ្នាទៅនិងសាស្រ្តាចារ្យ ខាំប៊ែល ដែរ ព្រះរាជអាជ្ញាបានរកមើលថាតើមានកត្តាអ្វីផ្សេងទៀត ជាជាងរោគសញ្ញានៃជំងឺវង្វេងវង្វាន់ដែលធ្វើឲ្យ អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់ ។ ព្រះរាជអាជ្ញាបានចោទសួរថាតើជំងឺ «dementia» អាចធ្វើការព្យាបាលដែរឬយ៉ាងណា ។ អ្នកជំនាញបានធ្វើការពន្យល់ថា នៅក្នុងភាសាខ្មែរមិនមានពាក្យណាមួយច្បាស់លាស់សំរាប់ពាក្យ «dementia» ទេ ហើយក៏គ្មានពាក្យខ្មែរសម្រាប់ពាក្យ «insane» ហើយត្រូវប្រើពាក្យ «បញ្ហាផ្លូវចិត្ត» ជំនួសវិញ ។ ពាក្យសាមញ្ញដែលមិនមានពាក្យច្បាស់លាស់សម្រាប់ភាសាខ្មែរមួយនេះអាចបង្កឲ្យមានការភ័ន្តច្រឡំព្រោះនៅក្នុងវិស័យសុខាភិបាល dementia គឺមានន័យទូលំទូលាយដែលអាចជារោគសញ្ញានៃបុព្វហេតុផ្សេងៗទៀតជាច្រើន ។ លក្ខខណ្ឌខ្លះនៃជំងឺនេះអាចព្យាបាលបាន ប៉ុន្តែគ្មានភ័ស្តុតាងដែលជាកត្តាណាមួយទាក់ទងទៅនឹង dementia ជាជាងរោគសញ្ញាវង្វេងវង្វាន់នោះទេ ។ ការភ័ន្តច្រឡំទាក់ទងទៅនឹងបច្ចេកវិទ្យានៃពាក្យអាចបន្ថែមការមន្ទិលសង្ស័យពីសំណាក់អ្នកសង្កេតការកម្ពុជាទាក់ទងទៅនឹង អៀង សារី ថាតើជនជាប់ចោទរូបនេះពិតជាមិនអាចចូលរួមដំណើរសវនាការបានឬយ៉ាងណា ។ អ្នកជំនាញបានផ្តល់យោបល់បន្ថែមទៀតថា មានមធ្យោបាយជាច្រើនប្រសើរជាងនេះដែលអាចយកមកប្រើប្រាស់ដើម្បីធ្វើឲ្យស្ថានភាពសតិបញ្ញានិងការចងចាំរបស់ អៀង ធីរិទ្ធ កាន់តែប្រសើរឡើង តែជំហានទាំងនេះគឺមានលក្ខណៈឆ្ងាយជាងការព្យាបាលទៅទៀត ។ នេះក៏ព្រោះតែបុព្វដែលបណ្តាលឲ្យមានជំងឺវង្វេងវង្វាន់គឺនៅតែមិនដឹងនៅឡើយ ហើយជំងឺនេះបង្កឲ្យមានការខូចខាត ធ្វើឲ្យសសៃរឈាមខួរក្បាលស្លាប់ដែលជាហេតុធ្វើឲ្យមានបញ្ហាខាងការចងចាំ ។

បន្ទាប់ពីព្រះរាជអាជ្ញាសួរចប់ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានសួរជាច្រើនសំណួរ ភាគច្រើនផ្តោតទៅលើការប្រែប្រួលនៃការយល់ដឹងរបស់ អៀង ធីរិទ្ធ និងកម្រិតណាដែល អៀង ធីរិទ្ធ អាចធ្វើការទំនាក់ទំនងជាមួយមេធាវីរបស់ខ្លួនបាន ។

សំណួរបន្ទាប់មកទៀត ភាគីដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗបានបង្ហាញនូវជំហររបស់ខ្លួនចំពោះអង្គជំនុំជម្រះទាក់ទងនឹងសម្បទាទូទៅរបស់ អៀង ធីរិទ្ធ ក្រោយមកអង្គជំនុំជម្រះបានសួរសំណួរចំនួនប្រាំទៅកាន់អ្នកជំនាញ ។ ក្រុមអ្នកការពារក្តីរបស់ អៀង សារី និង នួន ជា បានបង្ហាញនូវការមន្ទិលសង្ស័យយ៉ាងខ្លាំងថា អៀង ធីរិទ្ធ អាចនឹងមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងដំណើរសវនាការ ហើយអាចនឹងគាំទ្រឲ្យ អៀង ធីរិទ្ធ ចេញពីករណី០០២ឬយ៉ាងណា ដោយបានបញ្ជាក់ពីសិទ្ធិរបស់កូនក្តីក្នុងការឲ្យសាលាក្តីចាប់ផ្តើមឲ្យបានលឿន ។ មេធាវីរបស់ នួន ជា បានស្នើថា ករណី អៀង ធីរិទ្ធ គួរតែយកចេញពីករណី០០២ ដូច្នេះសវនាការអាចធ្វើដំណើរទៅមុខយឺតៗ ដើម្បីឲ្យការដាក់កំណត់ការប្រើប្រាស់ថ្នាំរបស់ នួន ជា ។

ចំពោះគោលជំហររបស់ អៀង សារី សហមេធាវីនាំមុខជាអាណា អេលីស បានធ្វើការសង្ខេប ដោយអះអាងថា ភ័ស្តុតាងគឺ "ច្បាស់" ហើយបញ្ជាក់ថា អៀង ធីរិទ្ធ គឺមិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងដំណើរសវនាការទេ ។

ការសន្និដ្ឋានរបស់ព្រះរាជអាជ្ញាគឺមានលក្ខណៈភ្ញាក់ផ្អើលបន្តិច ។ ផ្ទុយមកវិញ ព្រះរាជអាជ្ញាបានធ្វើការអះអាងថា ភ័ស្តុតាងផ្នែកវេជ្ជសាស្ត្របានផ្តល់ឲ្យ អៀង ធីរិទ្ធ គួរតែនាំយកទៅកាន់សវនាការឬទេ តែថាតើមានឱកាសណាមួយដែលលក្ខខណ្ឌខុសភាពរបស់ អៀង ធីរិទ្ធ អាចប្រសើរឡើងវិញដែរឬទេ ។ ព្រះរាជអាជ្ញាបានធ្វើការអះអាងថា ថ្មីៗនេះ «យើងមិនដឹងថាជំងឺនេះបានរីកចម្រើនប៉ុនណានោះទេ» ហើយអះអាងទៀតថា «មើលទៅ» សមត្ថភាពយល់ដឹងនាពេលបច្ចុប្បន្នរបស់ អៀង ធីរិទ្ធ «អាចនិងដោះស្រាយបាន» ។

ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា អៀង ធីរិទ្ធ គួរតែត្រូវបានយកឃើញថាមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងដំណើរការសវនាការ ដោយពឹងផ្អែកសំខាន់ទៅលើសេចក្តីថ្លែងការណ៍ខ្លះៗដែល អៀង ធីរិទ្ធ បានធ្វើទៅកាន់អ្នកជំនាញអំឡុងពេលនៃការវាយតម្លៃរបស់ជនជាប់ចោទរូបនេះ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា អៀង ធីរិទ្ធ បានបញ្ជាក់អំពីការយល់ដឹងនៃបទចោទដែលជនជាប់ចោទរូបនេះកំពុងរងការចោទប្រកាន់ យល់ដឹងអំពីការវាយតម្លៃថ្មីៗអំពីកាយសម្បទាដែលកំពុងដំណើរការ ហើយនឹងថា អៀង ធីរិទ្ធ អាចទាក់ទងជាមួយមេធាវីរបស់ខ្លួនមានប្រសិទ្ធភាពឬយ៉ាងណា?

**សេចក្តីសន្និដ្ឋាន**

ទោះបីជាភាគីដើមបណ្តឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញាធ្វើការតវ៉ាយឺតយ៉ាវ និងហាក់បីដូចជា ព្យាយាមបញ្ឈប់ក៏ដោយក៏ចៅក្រមអង្គជំនុំជម្រះហាក់បីដូចជាយល់ដឹងច្រើនថាទាក់ទងទៅនឹងការរកឃើញនៃករណី អៀង ធីរិទ្ធ ថាមិនមានកាយសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងដំណើរការសវនាការទេ ។ សំណួរជាច្រើនផ្តោតទៅលើការបញ្ជាក់អំពីគុណវិបត្តិក្នុងការអនុវត្តចំពោះការដែលរក្សាទុក អៀង ធីរិទ្ធ ជាផ្នែកមួយនៃករណី០០២ ហើយការអះអាងផ្សេងទៀតគឺទាក់ទៅនឹងថាតើ អៀង ធីរិទ្ធ អាចនឹងចូលរួមក្នុងដំណើរការបានដែរឬទេ ។ សាលាក្តីខ្មែរក្រហមមានអង្គជំនុំជម្រះតែមួយគត់ ហើយប្រសិនបើតុលាការមានការយកចិត្តទុកដាក់ដោយដំណើរការឲ្យបានលឿន សវនាការដែលអាចទៅរួចរបស់ អៀង ធីរិទ្ធ នឹងមិនអាចកើតឡើងបានទេរហូតដល់មានការបិទសវនាការ០០២ ។ រហូតមកដល់ពេលនោះម្នាក់ៗអាចធ្វើការស្មានថា រាល់ការសង្ស័យចំពោះសម្បទារបស់ អៀង ធីរិទ្ធ អាចនឹងជ្រះស្រឡះដោយរោគសញ្ញានៃជំងឺវង្វេងវង្វាន់កាន់តែច្រើនឡើងៗ ហើយ អៀង ធីរិទ្ធ នឹងមិនមានសម្បទាក្នុងការចូលរួមក្នុងដំណើរការសវនាការបានទេ ។ ហេតុដូច្នេះតាមស្ថានភាពនេះ អង្គសវនាការអាចនឹងដក អៀង ធីរិទ្ធ ចេញពីករណី០០២ ដើម្បីធ្វើឲ្យដំណើរការនេះកាន់តែលឿនឡើងដើម្បីឲ្យដំណើរការសវនាការអាចនឹងធ្វើការក្នុងគម្រោងដែលនឹងចាប់ផ្តើមនៅថ្ងៃទី២១ ខែវិច្ឆិកា ខាងមុខនេះ ទោះបីជាអង្គជំនុំជម្រះមិនអាចឈានដល់សេចក្តីសម្រេចទាក់ទងនឹងសម្បទារបស់ អៀង ធីរិទ្ធ និងដំណោះស្រាយទៅនឹងការឃុំឃាំងរបស់ អៀង ធីរិទ្ធ ។ ចម្លើយទៅនឹងសំណួរយ៉ាងវែងគួរតែអាចផ្តល់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ព្រោះតែសាលាក្តីខ្មែរក្រហមនេះត្រូវតែដោះស្រាយបញ្ហាឲ្យបានលឿនបំផុតមុននឹងបើកការជជែកវែកញែកចំពោះករណី០០២ ។

**អ៊ែនដល ឌីហ្សាល់ក្វ**

# ការលាលែងពីតំណែងរបស់សហចៅក្រម ស៊ើបអង្កេតអន្តរជាតិ ស៊ីកហ្វ្រេដ ប្ល៊ុង

## ១) *សារៈសំខាន់នៃការិយាល័យសហចៅក្រមស៊ើបអង្កេត*

ការិយាល័យសហចៅក្រមស៊ើបអង្កេតជាអង្គភាពឯករាជ្យមួយរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការិយាល័យនេះមានភារកិច្ចស៊ើបអង្កេតដោយខានពុំបានទៅលើបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអង្គហេតុដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ។ ក្នុងករណីដែលលេចចេញនូវអង្គហេតុថ្មីនៅពេលកំពុងធ្វើការស៊ើបអង្កេតនោះ សហចៅក្រមស៊ើបអង្កេតត្រូវជូនព័ត៌មានទៅសហព្រះរាជអាជ្ញា លើកលែងតែអង្គហេតុថ្មីនោះជាស្ថានទម្ងន់នៃអង្គហេតុចាស់ ។ រហូតមកដល់ពេលបច្ចុប្បន្ននេះ ការិយាល័យសហចៅក្រមស៊ើបអង្កេតសម្រេចបានការស៊ើបអង្កេតជាស្ថាពរលើសំណុំរឿងចំនួន២គឺ សំណុំរឿង០០១ដែលពាក់ព័ន្ធទៅនឹងជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច និងសំណុំ រឿង០០២ទាក់ទិនទៅនឹងមេដឹកនាំជាន់ខ្ពស់បួនរូប រួមមាន នួន ជា, ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ ។ អនុលោមតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា សំណុំរឿង០០១ និង ០០២ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ការិយាល័យសហចៅក្រមស៊ើបអង្កេតកំពុងបន្តស៊ើបអង្កេតលើសំណុំរឿង០០៣ និង០០៤ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី០៧ ខែកញ្ញា ២០០៩ ។ បន្ទាប់ពីការស៊ើបអង្កេតលើសំណុំរឿងនីមួយៗត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាដំណោះស្រាយមួយ ។ ដីកាដំណោះស្រាយនោះជាសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការសម្រេចចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ។ សមាសភាពនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតរួមមានសហចៅក្រមស៊ើបអង្កេតខ្មែរ និងបរទេស និងមន្ត្រីជំនួយតាមការចាំបាច់ ដូចជាមន្ត្រីនគរបាលយុត្តិធម៌ អ្នកស៊ើបអង្កេត និងក្រឡាបញ្ជី ។ មន្ត្រីនគរបាលយុត្តិធម៌ និងអ្នកស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញអាចអនុវត្តកាតព្វកិច្ចស៊ើបសួរទាំងឡាយណាដែលអាចមានប្រយោជន៍ដល់ការស៊ើបសួរតាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេត ។

## ២) *សារៈសំខាន់នៃការលាលែងពីតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ*

ចាប់តាំងពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានដំណើរការក្នុងខែកុម្ភៈ ឆ្នាំ២០០៦ រហូតមកទល់ពេលបច្ចុប្បន្ននេះ គឺមានសហចៅក្រមបរទេសពីររូបហើយដែលធ្វើការលាលែងពីមុខតំណែងរបស់ខ្លួន ។ លោកចៅក្រម ម៉ាកសែល ឡឺម៉ុង គឺជាអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិដំបូងនៅក្នុងជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយបានទទួលតំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលា ការកម្ពុជាតាំងពីឆ្នាំ ២០០៦ រហូតដល់គាត់លាលែងនៅថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០១០ ។ ម៉ាកសែល ឡឺម៉ុង បានទទួលខុសត្រូវដឹកនាំការស៊ើបសួរនៅក្នុងសំណុំរឿងចំនួនពីរ គឺសំណុំរឿង០០១ និង សំណុំរឿង០០២ដោយជោគជ័យ ។ មុនពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាកសែល ឡឺម៉ុង បានលាលែងចេញពីតំណែង មានបញ្ហាមួយចំនួនកើតឡើងចំពោះការិយាល័យស៊ើបអង្កេត ។ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ សហមេធាវីការពារក្តីបានឲ្យជនត្រូវចោទ អៀង សារី ដាក់ពាក្យបណ្តឹងជំទាស់ (បណ្តឹងសុំផ្លាស់ប្តូរ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លោក ម៉ាកសែល ឡឺម៉ុង ។ ការសុំប្តឹងជំទាស់នេះ សហមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានលើកឡើងពីសម្តីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិរូបនេះដែលបាននិយាយ

នៅក្នុងកិច្ចប្រជុំមួយជាមួយនឹងបុគ្គលិកមួយចំនួន នៃការិយាល័យសហចៅក្រមស៊ើបអង្កេតកាលពីខែសីហា ឆ្នាំ២០០៩ ។ ការចោទប្រកាន់ធ្វើឡើងដោយផ្អែកលើសម្តីរបស់ចៅក្រមស៊ើបអង្កេត ម៉ាកសែល ឡឺម៉ុង ដែលបាននិយាយក្នុងកិច្ចប្រជុំជាឯកជនថា “ខ្ញុំចង់ឲ្យមានការស្វែងរកភ័ស្តុតាងដាក់បន្ទុកឲ្យបានច្រើនជាងភ័ស្តុតាងដោះបន្ទុក” ។ ពាក្យសម្តីទាំងអស់នេះត្រូវបានរកឃើញនៅក្នុងសេចក្តីថ្លែងការណ៍ចំនួនបីទំព័ររបស់លោក វ៉េយនេ បាស៊ីន ដែលជាអតីតប្រធានអង្គភាពផ្នែកស៊ើបការណ៍ និងផ្នែកវិភាគនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សហមេធាវីការពារក្តីបានលើកឡើងថា ពាក្យសម្តីរបស់ចៅក្រម ម៉ាកសែល ឡឺម៉ុង បានបង្ហាញពីភាពលម្អៀងជាក់ស្តែងរបស់ចៅក្រម និងភាពទំនងថា មានភាពលម្អៀងផងដែរ ។ សំណើដែលលើកឡើងដោយសហមេធាវីការពារក្តីរបស់


សហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង និងអន្តរជាតិ ស៊ីកហ្វ្រេដ ប៊្លុង
(រូបថត : អ.វ.ត.ក)

ជនជាប់ចោទ អៀង សារី ត្រូវបានបដិសេធចោលដោយមតិជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះ ។ ក្រៅពីនេះ មានលេចចេញនូវបញ្ហាផ្សេងទៀត ដូចជានៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីប្រកាសព័ត៌មានសូមធ្វើការកែតម្រូវសេចក្តីរាយការណ៍ព័ត៌មានដែលមានលក្ខណៈខុសឆ្គង និងកន្ត្រប្រឡំមួយចំនួន ក្នុងសេចក្តីថា “សាលាក្តីខ្មែរក្រហមចាប់ផ្តើមស៊ើបអង្កេតជនសង្ស័យថ្មីប្រាំនាក់ទៀត” (ឌឹ ខែមបូឌា ដេលី ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ២០១០) និង “ចៅក្រមសាលាក្តីខ្មែរក្រហមមិនបានចុះហត្ថលេខាឲ្យមានការស៊ើបអង្កេតថ្មីទេ” (ឌឹ ខែមបូឌា ដេលី ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០) ដោយសហចៅក្រមស៊ើបអង្កេតបានប្រកាសថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិចាត់ទុកថាមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ដែលទាំងពីរពាក់ព័ន្ធនឹងបញ្ហាពេលវេលាសមស្របនៃចំណាត់ការលើការស៊ើបសួរក្នុងសំណុំរឿង០០៣ និង០០៤ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិនឹងបន្តដំណើរការងារនេះតែម្នាក់ឯង ។ លោកសហចៅក្រមស៊ើបអង្កេត ម៉ាកសែល ឡឺម៉ុង បានលើកឡើងនូវពាក្យចុងក្រោយរបស់គាត់ដោយការឆ្លើយតបសរសេរទៅកាន់កាសែតភ្នំពេញប៉ុស្តិ៍ថា “តុលាការត្រូវតែមានឯករាជ្យ និងអព្យាក្រឹត” ហើយបានបន្ថែមទៀតថា “ឯករាជ្យពីរដ្ឋាភិបាលកម្ពុជា និងឯករាជ្យពីសាព័ត៌មាន និងអង្គការក្រៅរដ្ឋាភិបាលនានាផងដែរ” ។

ក្រោយពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាកសែល ឡឺម៉ុង លាលែងពីតំណែង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានតែងតាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិម្នាក់ទៀតដើម្បីដំណើរការនីតិវិធីសំណុំរឿងបន្តទៀត ។ ការតែងតាំងនេះធ្វើឡើងដោយព្រះមហាក្សត្រនរោត្តម សីហមុនី បានឡាយព្រះហត្ថលេខាតែងតាំងលោក ស៊ីកហ្វ្រេដ ប៊្លុង ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១០ ។ សហចៅក្រមអន្តរជាតិ ស៊ីកហ្វ្រេដ ប៊្លុង ជនជាតិអាល្លឺម៉ង់ បានបញ្ចប់ការសិក្សាផ្នែកច្បាប់នៅសកលវិទ្យាល័យ មុយនិច និងបានសរសេរនិក្ខេបបទបញ្ចប់ថ្នាក់បណ្ឌិតស្តីពីច្បាប់អន្តរជាតិ ។ លោក ស៊ីកហ្វ្រេដ ប៊្លុង

ត្រូវបានតែងតាំងជាព្រះរាជអាជ្ញាតាំងពីឆ្នាំ១៩៧២ ហើយនៅក្នុងឆ្នាំ១៩៧៧ លោកបានទទួលការតែងតាំងជាចៅក្រម ដោយទទួលខុសត្រូវទាំងរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីព្រហ្មទណ្ឌក្នុងរយៈពេល២៦ឆ្នាំបន្ទាប់ទៀត ។ ចាប់ពីឆ្នាំ២០០៣ ដល់២០០៥ លោកចៅក្រម ស៊ីកហ្វ្រេដ ប៊្លុង មានតួនាទីជាចៅក្រមអន្តរជាតិនៅក្នុងតុលាការកូនកាត់មួយដែលត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិសំរាប់ប្រទេសទីមរ័ខាងកើត ។ លោកត្រូវបានតែងតាំងជាចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាំងពីឆ្នាំ២០០៨ ហើយរហូតមកដល់ឆ្នាំ២០១០ លោកបានទទួលការតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ។ ក្រោយពេលទទួលបានការតែងតាំងជាសហចៅក្រមស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លោក ស៊ីកហ្វ្រេដ ប៊្លុង បានបន្តការស៊ើបអង្កេតលើសំណុំរឿង ០០៣ និង ០០៤ ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស៊ីកហ្វ្រេដ ប៊្លុង បានប្រកាសលាលែងពីមុខនាទីរបស់ខ្លួន នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១១ ដោយបានផ្ញើលិខិតលាលែងទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន ។ ការលាលែងនេះធ្វើឡើងបន្ទាប់ពីមានការរិះគន់ពីអង្គការសង្គមស៊ីវិលជាច្រើន ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិបានរិះគន់ថា សហចៅក្រមស៊ើបអង្កេតមិនបានធ្វើការដោយអព្យាក្រឹតក្នុងសំណុំរឿង០០៣និង០០៤ឡើយ ។ នៅពេលលាលែងពីតំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ លោក ស៊ីកហ្វ្រេដ ប៊្លុង បានធ្វើសេចក្តីថ្លែងការណ៍ដោយបានលើកឡើងពីសម្តីរបស់សម្តេចនាយករដ្ឋមន្ត្រីកម្ពុជា ដែលជម្រាបជូនទៅលោក បាន គីមូន ថា «នឹងមិនអនុញ្ញាតឲ្យមានសំណុំរឿងទាំងពីរនេះឡើយ» ។ មិនតែប៉ុណ្ណោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិរូបនេះបានលើកឡើងបន្ថែមទៀតពីសម្តីរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មានថា «ប្រសិនបើពួកគេចង់បន្តដំណើរការរឿងក្តី០០៣ និង០០៤ ពួកគេគួរតែរៀបចំអីវ៉ាន់ ហើយចាកចេញ» ។ លោកបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រីក្រសួងការបរទេសថា «ការចាប់ខ្លួនអតីតមេដឹកនាំខ្មែរក្រហមបន្ថែមទៀត គឺជារឿងរបស់កម្ពុជា ។ រឿងនេះ ត្រូវតែសម្រេចដោយកម្ពុជា (ឌឹ ខេមបូឌា ដេលី ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០១១)» ។ ចុងបញ្ចប់នៃសេចក្តីថ្លែងការណ៍នោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស៊ីកហ្វ្រេដ ប៊្លុង បានលើកឡើងថា «ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនដាក់ខ្លួនឲ្យស្ថិតនៅក្រោមឥទ្ធិពលនៃការលើកឡើងខាងលើក៏ដោយ ក៏នៅតែមានមន្ទិលសង្ស័យទៅលើលទ្ធភាពរបស់លោកក្នុងការទ្រាំទ្រនិងសម្ពាធរបស់រដ្ឋាភិបាល និងលទ្ធភាពក្នុងការបំពេញការងារដោយឯករាជ្យ ហើយក៏បង្កឲ្យមានមន្ទិលសង្ស័យចំពោះសុចរិតភាពនៃដំណើរការទាំងមូលរបស់តុលាការនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដែរ» ។

### ១) ទស្សនៈជុំវិញការលាលែងពីតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស៊ីកហ្វ្រេដ ប៊្លុង

#### ក) ប្រតិកម្មពីសំណាក់អង្គការក្រៅរដ្ឋាភិបាល

ឆ្លើយតបនឹងការលាលែងពីតួនាទីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលោក ស៊ីកហ្វ្រេដ ប៊្លុង បណ្តាអង្គការអន្តរជាតិនានាបានបញ្ចេញនូវទស្សនៈមួយចំនួនជុំវិញការលាលែងនេះ ។

នៅថ្ងៃអង្គារ ទី១១ ខែតុលា ឆ្នាំ២០១១ អង្គការលើកលែងទោសអន្តរជាតិ បានអំពាវនាវឲ្យអង្គការសហប្រជាជាតិរារាំងកម្ពុជាកុំឲ្យលូកដៃចូលកិច្ចការតុលាការខ្មែរក្រហម ខណៈពេលដែលរដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាពន្យល់ថា រដ្ឋាភិបាលកម្ពុជាត្រូវទទួលខុសត្រូវចំពោះអស្ថិរភាព ឬអសន្តិសុខសង្គម ។ លោកនាយកអង្គការលើកលែងទោសអន្តរជាតិប្រចាំអាស៊ីប៉ាស៊ីហ្វិច ស៊ែម ហ្សារីហ្វាយ បានថ្លែងថា វាជាការចំបាច់ដែលអង្គការសហប្រជាជាតិត្រូវមានវិធានការដើម្បីធានាអនាគតរបស់សាលាក្តី និងធានាថា ដំណើរការសាលាក្តីនេះនឹងទទួលបានស្តង់ដារនៃការកាត់ក្តីដ៏យុត្តិធម៌ ដោយឯករាជ្យ និងអព្យាក្រឹត ។

ទន្ទឹមនឹងនេះ លោកស្រី ក្លែ ដាហ្វហ៊ី អ្នកឃ្លាំមើលសាលាក្តីខ្មែរក្រហមនៃអង្គការច្បាប់របស់សហរដ្ឋអាមេរិកមួយមានឈ្មោះថា អង្គការផ្តួចផ្តើមយុត្តិធម៌សង្គមបើកចំហ បានថ្លែងថា ការលាឈប់ពីតំណែង និងការជំនួសអ្នកថ្មីមិនមែនជាដំណោះស្រាយទេ ។ រឿងនេះអង្គការសហប្រជាជាតិ និងប្រទេសកម្ពុជាត្រូវដោះស្រាយឲ្យបានប្រញាប់ ។ លោកស្រីបានលើកឡើងថា «ខ្ញុំជឿជាក់ខ្លាំងណាស់ថារឿងនេះមិនមែនជាអ្វីដែលនឹងអាចដោះស្រាយបាន

ទេ ។ ជាការពិត យើងនឹងឃើញបញ្ហាដូចគ្នានេះបង្ហាញនៅពេលលើកទីបីជាមួយនឹងចៅក្រមស៊ើបអង្កេតអន្តរជាតិទីបីនៅក្នុងមុខតំណែងនេះ ។ ជារឿងចាំបាច់ រដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិត្រូវតែអង្គុយប្រជុំនៅតុជាមួយគ្នា ដើម្បីពិភាក្សាដោយស្មោះត្រង់អំពីគោលបំណងណាមួយដែលពួកគេចង់ឃើញ ហើយថាតើកេរ្តិ៍ឈ្មោះយ៉ាងម៉េចដែលគេចង់ឃើញនៅទីបញ្ចប់នៃតុលាការនេះ» ។

### ខ) ការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជា

ដោយមានការលើកឡើងជាច្រើនពាក់ព័ន្ធទៅនឹងការលាលែងពីតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លោក ស៊ីកហ្វ្រេដ ប៊្លុង រដ្ឋាភិបាលកម្ពុជាបានបង្ហាញអំពីគោលជំហររបស់ខ្លួននៅក្នុងការលើកឡើងពីការជ្រៀតជ្រែកសាលាក្តីខ្មែរក្រហម ។ នៅថ្ងៃអង្គារ ទី១១ ខែតុលា ឆ្នាំ២០១១ ឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសមានប្រសាសន៍ប្រាប់អ្នកយកព័ត៌មានថា កម្ពុជាគាំទ្រសេចក្តីសម្រេចជាក់លាក់ទាំងឡាយរបស់សាលាក្តីខ្មែរក្រហម ។ លោកបានលើកឡើងថា «ដល់សរុបមកជាសិទ្ធិរបស់តុលាការ ។ ប្រសិនក្នុងនាមជាអ្នកដឹកនាំប្រទេសជាតិ ទទួលខុសត្រូវលើជោគវាសនារបស់ប្រទេសជាតិ និងប្រជាជន យើងមានយោបល់ដូច្នេះ អ៊ីៗស្រេចតែលើតុលាការ ។ សូមអរគុណ» ។ ឯកឧត្តម ហោ ណាំហុង បានបកស្រាយថា មានការបកស្រាយខុសទៅលើសេចក្តីថ្លែងការណ៍របស់លោក ក៏ប៉ុន្តែលោកក៏បានបញ្ជាក់ថា រដ្ឋាភិបាលមានបុព្វសិទ្ធិអំពីការចោទសួរទៅលើចំណោទ ដែលអាចកើតឡើងពីចំណាត់ការរបស់តុលាការ «យើងដឹងច្បាស់ការស្រាវជ្រាវរកសំណុំរឿងទី៣ និងទី៤ ជាសិទ្ធិរបស់តុលាការ ។ ក្នុងឋានៈជារដ្ឋាភិបាលទទួលខុសត្រូវជោគវាសនារបស់ជាតិ បើសិនជាតុលាការកូនកាត់នេះ ធ្វើអ៊ីមួយដែលនាំឲ្យមានអសន្តិសុខ គឺសង្គ្រាមនៅកម្ពុជា ។ តើអ្នកណាទទួលខុសត្រូវ?» ។

ជាមួយគ្នានេះដែរ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ បានសរសេរលិខិតបំភ្លឺមួយទៅកាន់កាសែតបាងកកប៉ុស្តិ៍របស់ថៃ ចំពោះអត្ថបទដែលមានចំណងជើងថា «ចៅក្រមលាលែង ដោយសារតែការជ្រៀតជ្រែករបស់រដ្ឋាភិបាល» ។ ក្នុងលិខិតចុះថ្ងៃពុធ ទី១២ ខែតុលា ឆ្នាំ២០១១ លោកស្រី យូ អយ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ បានលើកឡើងថា រដ្ឋាភិបាលកម្ពុជាយល់ច្បាស់ថាវាជាបុព្វសិទ្ធិរបស់សាលាក្តីចម្រុះកាត់ទោសមេខ្មែរក្រហម ដែលបង្កើតឡើងដោយអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចចិត្តចោទប្រកាន់បុគ្គលណាម្នាក់នៅពីក្រោយបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអំឡុងរបបខ្មែរក្រហម ។ លោកស្រីឯកអគ្គរាជទូត បានបញ្ជាក់ទៅកាន់កាសែតបាងកកប៉ុស្តិ៍ថា ចាប់តាំងពីពេលបង្កើតសាលាក្តីចម្រុះនោះមកដល់សព្វថ្ងៃ រដ្ឋាភិបាលកម្ពុជាបានប្រកាន់ខ្ជាប់នូវការគោរពដោយពេញលេញលើឯករាជ្យភាពនៃដំណើរការកាត់ទោសមេខ្មែរក្រហម និងមិនដែលជ្រៀតជ្រែកចំពោះដំណើរការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះខ្មែរឡើយ ។ លោកស្រីក៏បានបញ្ជាក់ទៀតថា រដ្ឋាភិបាលកម្ពុជាចង់ឲ្យតុលាការកូនកាត់បំពេញបេសកកម្មរបស់ខ្លួនឲ្យបានឆាប់រហ័សតាមដែលអាចធ្វើបានពីព្រោះអតីតមេខ្មែរក្រហមទាំងបួនរូបដែលកំពុងជាប់ឃុំឃាំងនៅក្នុងសំណុំរឿង០០២កាន់តែមានវ័យចំណាស់ និងមានជំងឺ ហើយអាចនឹងស្លាប់នៅពេលណាមួយ ។ ដូច្នេះសាលាក្តីចម្រុះអាចនឹងប្រឈមមុខក្នុងការមិនបានកាត់ទោសមេដឹកនាំខ្មែរក្រហមណាម្នាក់ ប្រសិនបើដំណើរការកាត់ទោសត្រូវអូសបន្លាយ ។ មិនតែប៉ុណ្ណោះ លោកស្រីបានបញ្ជាក់បន្ថែមថា នៅក្នុងរឿងសាលាក្តីខ្មែរក្រហម រដ្ឋាភិបាលកម្ពុជាគ្រាន់តែបង្ហាញនូវក្តីបារម្ភរបស់ខ្លួនចំពោះការផ្សះផ្សាជាតិ សន្តិភាព សន្តិសុខ និងការអភិវឌ្ឍជាតិ បើសិនមានការចោទប្រកាន់បន្ថែមលើអតីតមេខ្មែរក្រហម ។

### គ) ប្រតិកម្មពីអង្គការសហប្រជាជាតិ

នៅក្នុងសប្តាហ៍បន្ទាប់នៃការលាលែងពីមុខនាទីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លោក ស៊ីកហ្វ្រេដ ប៊្លុង អង្គការសហប្រជាជាតិបានបញ្ជូនអគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកកិច្ចការច្បាប់ មកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាដើម្បីស្វែងរកដំណោះស្រាយមួយចំពោះរឿងសាលាក្តីខ្មែរក្រហម ។ កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ ២០១១ លោកស្រី ប៉ាទ្រីស្យា អូប្រាយអិន ដែលជាអគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកកិច្ចការច្បាប់បានជួបពិភាក្សាការងារ

ជាមួយឧបនាយករដ្ឋមន្ត្រី សុខ អាន នៅទីក្រុងភ្នំពេញ ។ ការជួបពិភាក្សាការងាររបស់លោកស្រី ប៉ា្រទីស្យា អូប្រាយអិន និងឧបនាយករដ្ឋមន្ត្រី សុខ អាន គឺដើម្បីពិភាក្សាលើកង្វល់របស់អង្គការសហប្រជាជាតិអំពីការវិវឌ្ឍថ្មីៗនៅសាលាក្តីខ្មែរក្រហម បន្ទាប់ពីការលាឈប់របស់លោក ស៊ីកហ្វ្រេដ ប៊្លុង សហចៅក្រមស៊ើបអង្កេតភាគីខាងអង្គការសហប្រជាជាតិកាលពីសប្តាហ៍មុន ។ លោកស្រីបានបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍ថា លោកស្រីបានជំរុញយ៉ាងខ្លាំងឲ្យរាជរដ្ឋាភិបាលកម្ពុជាឈប់ចេញសេចក្តីថ្លែងការណ៍ទាំងឡាយដែលប្រឆាំងនឹងការរីកចម្រើននៃសំណុំរឿងលេខ០០៣ និង០០៤ ហើយឲ្យឈប់ជ្រៀតជ្រែកតាមវិធីណាក៏ដោយក្នុងដំណើរការវិនិច្ឆ័យ ។

**ឃ) ប្រតិកម្មរបស់មេធាវីការពារសិទ្ធិរបស់ជនជាប់ចោទចំពោះការលាលែងពីតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

ក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា ដែលរួមមានលោកមេធាវីអន្តរជាតិ ម៉ៃឃើល ផេសមែន និងលោក អេនឌ្រូ អ៊ីនុហ្វុ បានដាក់ពាក្យប្តឹងទៅកាន់តុលាការក្រុងភ្នំពេញ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ ។ នៅក្នុងពាក្យបណ្តឹងនេះ មេធាវីទាំងពីបានប្តឹងសម្តេច ជា ស៊ីម, សម្តេច ហេង សំរិន, ឯកឧត្តម ហោណាំហុង, ឯកឧត្តម គាត ឈន់, ឯកឧត្តម អ៊ុក ប៊ុនឈឿន, ឯកឧត្តម ស៊ីម កា, ឯកឧត្តម ខៀវ សុភ័គ, សម្តេច ហ៊ុន សែន, ឯកឧត្តម ខៀវ កាញារិទ្ធ, ឯកឧត្តម ជៃ ស៊ីផាន និង ឯកឧត្តម គង់ សំអុល ដោយផ្អែកលើមាត្រា ៤៣ និង ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។ លោកមេធាវីបានលើកឡើងថា "ពាក្យបណ្តឹងប្តឹងថា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាមួយចំនួន ដោយជារូបវន្តបុគ្គល និងតាមរយៈការចូលរួមរបស់រដ្ឋាភិបាលដែលជាចេតនាទុច្ចរិតទូទៅត្រូវមានពិរុទ្ធភាពពីបទជ្រៀតជ្រែកចូលវិស័យតុលាការ និងសិទ្ធិរបស់ជនជាប់ចោទក្នុងទទួលបានការកាត់ក្តីដោយត្រឹមត្រូវ និងយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

**ង) សហចៅក្រមអន្តរជាតិនៅអង្គបុរេជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើកឡើងពីបញ្ហារបស់សហចៅក្រមស៊ើបអង្កេត**

មិនតែប៉ុណ្ណោះ ក្រោយពេលមានការលាលែងចេញពីមុខនាទីនេះ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណាមួយទាក់ទងទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោក រ៉ូប៊ឺត ហាមិល ។



សហចៅក្រមអន្តរជាតិ រ៉ូវ៉ាន់ ដននីង និង កាត់ទីនកា ឡាហ្គីស មានការខ្វែងយោបល់គ្នាជាមួយសហការីដែលជាចៅក្រមជាតិទាំងបីរូបលើការចេញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដោយរកឃើញថាសហចៅក្រមស៊ើបអង្កេត ស៊ីកហ្វ្រេដ ប៊្លុង និង យូ ប៊ុនឡេង បានប្រព្រឹត្តខុសប្រក្រតីនៃនីតិវិធីដោយរួមបញ្ចូលទាំងការចុះកាលបរិច្ឆេទថយក្រោយលើឯកសារ ការកែប្រែឯកសាដោយសម្ងាត់ និងខកខានក្នុងការជូនដំណឹងឲ្យបានត្រឹមត្រូវទៅកាន់មេធាវី ។

ឆ្លើយតបនឹងការលើកឡើងរបស់សហចៅក្រមអន្តរជាតិ

ទាំងពីរ នៅអង្គបុរេជំនុំជម្រះដែលបានលើកឡើងថា សហចៅក្រមស៊ើបអង្កេត ស៊ីកហ្វ្រែដ ប៊្លុង និង យូ ប៊ុនឡេង បានប្រព្រឹត្តខុសប្រក្រតីនៃនីតិវិធីសហចៅក្រមស៊ើបអង្កេតបានធ្វើការប្រកាសព័ត៌មានជាសាធារណៈកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០១១ ថា ព័ត៌មានមួយចំនួនត្រូវបានចុះនៅក្នុងបណ្ដាញសាព័ត៌មានទាក់ទងនឹងសហចៅក្រមស៊ើបអង្កេតជាពិសេសទាក់ទិននិងការដែល "...សហចៅក្រមស៊ើបអង្កេតទាំងពីរបានចុះកាលបរិច្ឆេទថយក្រោយ និងបានកែប្រែជាសម្ងាត់នូវឯកសារដែលបានដាក់ចូល


សិស្សចូលរួមសវនាការក្នុងខែតុលា ឆ្នាំ២០១១

ក្នុងសំណុំរឿង០០៣..." ។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា ការចោទប្រកាន់ត្រូវបានធ្វើឡើងដោយយោងទៅលើសហចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះទាក់ទងទៅនឹងបណ្ដឹងឧទ្ធរណ៍របស់អ្នកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ ។ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា ខ្លួនបានធ្វើទៅតាមនីតិវិធីទាំងការកែប្រែឯកសារ និងការជូនដំណឹងទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ។ សហចៅក្រមស៊ើបអង្កេតក៏បានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមិនបានធ្វើការកែប្រែលើកាលបរិច្ឆេទនៃដីកាចេញសេចក្ដីសម្រេចរបស់ខ្លួននោះទេ ហើយចំពោះនីតិវិធីជូនដំណឹងទៅកាន់អ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីគឺបានអនុវត្តទៅតាមធម្មតា ។

ចំពោះការលេចឡើងនូវព័ត៌មានពាក់ព័ន្ធទៅនឹងភាពខ្វះចន្លោះរបស់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ សហមេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា បានធ្វើសំណើបញ្ជីសម្ភារៈដែលជិតដាមនឹងរឿង០០២ និងស្នើសុំឲ្យលាឈប់ពីការងារ ។ សហមេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា រួមមានលោក ជេសមែន និងលោក វិកទ័រ គូបេ និងលោក អេនឌ្រូ អ៊ីនុហ្សី និងលោក ហ្សាស៊ីរ ជ៉ៅ បានធ្វើសំណើសុំតាមរយៈសារអេឡិចត្រូនិច ដើម្បីសុំពិនិត្យឯកសារ និងភ័ស្តុតាងនានា ហើយបានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតជាតិ លោក យូ ប៊ុនឡេង ធ្វើការលាលែងពីតំណែង ។ ឆ្លើយតបចំពោះការលាលែងនេះដែរសហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង មិនបានបញ្ចេញទស្សនៈអ្វីច្រើននេះទេ ដោយលោកបានលើកឡើងថា ការលាលែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនេះ គឺជារឿងមួយដែលភ្ញាក់ផ្អើលបំផុតសម្រាប់រូបលោក ។ លោកបានបញ្ជាក់ទៀតថា នាពេលកន្លងមកនេះ ទំនាក់ទំនងការងាររវាងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងរូបលោកដែលជាសហចៅក្រមស៊ើបអង្កេតជាតិបានដំណើរការទៅយ៉ាងរលូនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងឈរលើគោលការណ៍ច្បាប់ និងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាមូលដ្ឋាន បើទោះជាមានការចោទប្រកាន់តាមរយៈការបំផ្លើសព័ត៌មានប្រាសចាកការពិតពីមជ្ឈដ្ឋានខាងក្រៅមួយចំនួនក៏ដោយ ។

ថ្វីដ្បិតតែការលាលែងពីមុខតំណែងរបស់សហចៅក្រមស៊ើបអង្កេតគឺជាសិទ្ធិរបស់ចៅក្រមស៊ើបអង្កេតក៏ដោយ ក៏ប៉ុន្តែតាមរយៈសេចក្ដីថ្លែងការណ៍របស់លោកបានបង្កើតឲ្យមានការដេញដោល និងការពិភាក្សាជាច្រើនទៅលើបញ្ហាអព្យាក្រឹតយុត្តិធម៌ និងតម្លាភាពរបស់សាលាជម្រះក្ដីមេដឹកនាំខ្មែរក្រហម ពិសេស គឺឯករាជ្យភាពរបស់តុលាការខ្មែរក្រហម ។

**គឹម ម៉ារីយ៉ាន**

# ចៅក្រមស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ៖ បន្ទុកក្នុងរដ្ឋបាល ឬបន្ទុកហុចជាប្រយោជន៍

ខុសពីតុលាការអន្តរជាតិភាគច្រើនដែលផ្អែកលើមូលដ្ឋានច្បាប់ ខុំមិនឡូ (common law) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានស្គាល់ថាដើរតាមទំនៀមទម្លាប់ច្បាប់ស៊ីវិលឡូ (civil law) ដែលខាងទ្វីបអឺរ៉ុបអនុវត្ត ។ នេះគឺដោយសារតែប្រព័ន្ធច្បាប់ក្នុងស្រុករបស់កម្ពុជាត្រូវបានបន្សល់ទុកឲ្យដោយប្រទេសបារាំងដែលបានដាក់អាណានិគមអស់រយៈពេលយ៉ាងយូរនៅក្នុងប្រទេសកម្ពុជា ។ ដូច្នេះ តុលាការខ្មែរក្រហមក៏ដើរតួនាទីផ្លូវច្បាប់តាមទំនៀមទម្លាប់ច្បាប់នេះទៅ ។ ដោយសារហេតុផលនេះ តុលាការខ្មែរក្រហមបានក្លាយជាតុលាការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរមុនដំបូងគេដែលផ្តល់តួនាទី និងយន្តការសំខាន់ដល់ចៅក្រមស៊ើបអង្កេតដោយផ្អែកតាមទំនៀមទម្លាប់ច្បាប់ ស៊ីវិលឡូ ។ តាមរយៈការវិភាគវែកញែកពីនីតិវិធីនេះ នោះឯតុលាការខ្មែរក្រហមអត្ថបទមួយនេះនឹងពិនិត្យពិច័យថាតើតុលាការខ្មែរក្រហមនឹងហុចជាប្រយោជន៍ដល់តុលាការព្រហ្មទណ្ឌអន្តរជាតិដែរឬទេ ឬថាតើតុលាការខ្មែរក្រហមប្រឈមមុខនឹងកត្តាប្រឈមជាក់លាក់អ្វីខ្លះដើម្បីសម្រេចគោលដៅរបស់ខ្លួន ។

## នីតិវិធីព្រហ្មទណ្ឌពីរ

ប្រព័ន្ធនីតិវិធីច្បាប់ព្រហ្មទណ្ឌត្រូវបានបែងចែកជាពីរផ្នែកធំៗ ៖ ទីមួយគឺ ប្រព័ន្ធច្បាប់ អេដវឺសារៀល (adversarial system) និងប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល (inquisitorial system) ។ ប្រព័ន្ធទីមួយមានប្រភពដើមមកពីប្រទេសអង់គ្លេស ហើយត្រូវបានយកទៅអនុវត្តដោយប្រព័ន្ធច្បាប់ ខុំមិនឡូ ។ ចំណែកឯប្រព័ន្ធទីពីរមានប្រភពដើមមកពីប្រទេសបារាំង និងប្រទេសអាល្លឺម៉ង់ដែលជាមូលដ្ឋាននីតិព្រហ្មទណ្ឌក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ ។ ប្រព័ន្ធច្បាប់ទាំងពីរមានលក្ខណៈខុសគ្នាទាំងក្នុងដំណើរការកាត់ទោសស៊ើបអង្កេត និងអង្គជំនុំជម្រះ ។ ប្រព័ន្ធ អេដវឺសារៀល ដំណើរការទៅដោយមានភាគីពីរធ្វើការតតាំងគ្នានៅចំពោះមុខចៅក្រម ដោយដើរតួជាអ្នកចេញសេចក្តីសម្រេចដោយអព្យាក្រឹត និងអសកម្ម ឬក៏ជា "អ្នកកាត់សេចក្តី" ចំណែកប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល ផ្តល់ការទទួលខុសត្រូវខាងស៊ើបអង្កេតទៅឲ្យអាជ្ញាធររដ្ឋឯករាជ្យមួយ ជាឧទាហរណ៍គឺចៅក្រមស៊ើបអង្កេត ដើម្បីប្រមូលភស្តុតាងដែលជាប់ពាក់ព័ន្ធទាំងអស់ ។ កិច្ចការរបស់ចៅក្រមនៃអង្គជំនុំជម្រះគឺទាញយកការពិត និងចេញសេចក្តីសម្រេចកាត់ទោសដ៏ត្រឹមត្រូវនិងសមហេតុផលមួយដោយផ្អែកលើមូលដ្ឋាននៃប្រព័ន្ធច្បាប់នេះ ។ នៅក្នុងប្រព័ន្ធច្បាប់នេះ ភាគីទាំងអស់មិនសូវមានអំណាចមានការទទួលខុសត្រូវ ឬសកម្មប៉ុន្មានទេ ដោយសារភារកិច្ចភាគច្រើនត្រូវបានចៅក្រមអង្គជំនុំជម្រះផ្តួចផ្តើមឡើង ។

ប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល រួមទាំងប្រព័ន្ធច្បាប់អេដវឺសារៀល មានទាំងគុណសម្បត្តិ និង គុណវិបត្តិក្នុងការគ្រប់គ្រងដំណើរការនីតិវិធីនៅក្នុងតុលាការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ ប្រព័ន្ធច្បាប់ ទាំងពីរនេះមិនត្រូវបានតាក់តែងឡើងដើម្បីដោះស្រាយរឿងក្តីស្មុគស្មាញមួយចំនួនដោយមានការចូលរួមពីសាក្សីចំនួនច្រើនទេ ហើយក៏មិនបំពេញទៅតាមវិសាលភាពទូលំទូលាយរបស់តុលាការអន្តរជាតិដែរ បើប្រៀបធៀបទៅនឹងតុលាការព្រហ្មទណ្ឌក្នុងស្រុកដែលផ្តល់ជាយុត្តិធម៌តាមរយៈការនាំជនដៃដល់មកផ្តន្ទាទោស ។ ប្រវត្តិរបស់តុលាការខ្មែរក្រហមបង្ហាញឲ្យឃើញពីគោលបំណងរបស់ខ្លួនក្នុងការលើកស្ទួយដំណើរការផ្សះផ្សាជាតិ និងដើម្បីជះឥទ្ធិពលដល់ប្រព័ន្ធច្បាប់កម្ពុជាតាមរយៈ បុគ្គលិកកម្ពុជា និងអ្នកមានអំណាចជាគំរូ ។

## លើកកម្ពស់ដំណើរការផ្សះផ្សាតាមរយៈការស្វែងរកការពិត

សម្រាប់ដំណើរការស្វែងរកការពិត ការយល់ដឹងពីការពិតគឺជាផ្នែកមួយដ៏សំខាន់ ហើយសមត្ថភាពរបស់តុលាការកាត់ទោស

ខក្រិដ្ឋកម្មធ្ងន់ធ្ងរក្នុងការស្វែងរកការពិតក៏សំខាន់ដែរ ។ ការវិភាគពីតួនាទីរបស់ចៅក្រមស៊ើបអង្កេតរបស់តុលាការខ្មែរក្រហមបង្ហាញឲ្យឃើញពីផលប្រយោជន៍គួរឲ្យកត់សម្គាល់នៅក្នុងដំណើរការផ្សះផ្សានេះ ។ នៅក្នុងប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល គោលដៅចម្បង គឺដើម្បីស្វែងរកការពិតដ៏គួរឲ្យជឿជាក់ នៅពេលដែលសិទ្ធិក្នុងការស៊ើបអង្កេតត្រូវបានផ្តល់ឲ្យអាជ្ញាធររដ្ឋឯករាជ្យមួយ ។ «ការពិត» ត្រូវបានយល់ឃើញថាជាទស្សនៈដាច់ខាតមួយដែលអាជ្ញាធររដ្ឋត្រូវតែព្យាយាមបង្ហាញនូវការពិតនោះ បើទោះបីជាព្រះរាជអាជ្ញា និងមេធាវីការពារក្តីយល់ស្រប ឬជំទាស់ក៏ដោយទាក់ទងនឹងលំដាប់លំដោយនៃព្រឹត្តិការណ៍ ។ ដូច្នេះ ចៅក្រមស៊ើបអង្កេតត្រូវតែដាក់បញ្ចូលរាល់ភស្តុតាងពាក់ព័ន្ធទាំងអស់ ទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ។ ផ្អែកលើមូលដ្ឋាននេះ ចៅក្រមអង្គជំនុំជម្រះអាចធ្វើការពិចារណាគ្រប់កត្តាទាំងអស់នៅពេលដែលចៅក្រមព្យាយាមកំណត់យកការពិតដោយអនុវត្តច្បាប់ពាក់ព័ន្ធ និងចេញសេចក្តីសន្និដ្ឋានផ្នែកច្បាប់ដ៏ត្រឹមត្រូវមួយ ។ កត្តាពិចារណាដើម្បីចេញសេចក្តីសម្រេចសាលក្រម គឺជាបទចោទប្រកាន់ផ្ទាល់ខ្លួនរបស់ចៅក្រមក្រោយពេលដែលចៅក្រមទទួលបានភស្តុតាងពាក់ព័ន្ធទាំងអស់នៅក្នុងអំឡុងអង្គជំនុំជម្រះក្តី ។ គោលការណ៍នេះត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនូវកង្វះខាតនៃភាពព្រមព្រៀងគ្នានៅក្នុងនីតិវិធីព្រហ្មទណ្ឌច្បាប់ស៊ីវិលឡ ដោយសារតែការពិតមិនអាចចរចា ឬសម្របសម្រួលបានឡើយ ។

ការផ្តោតទៅលើការស្វែងរកការពិត គឺពិតជាដំណើរការដ៏មានតម្លៃសម្រាប់សង្គមមួយដែលព្យាយាមស្វែងយល់ពីអតីតកាលរបស់ខ្លួនដោយគ្មានគណៈកម្មការស្វែងរកការពិត ឬគណៈកម្មការអ៊ីផ្សេងនោះ ។ ដូចគ្នានេះ គោលការណ៍ផ្ទេរការទទួលខុសត្រូវក្នុងការស្វែងរកការពិតទៅឲ្យអាជ្ញាធររដ្ឋ ត្រូវបានចាត់ទុកថាជាការធានាមួយសម្រាប់លទ្ធផលដ៏ត្រឹមត្រូវ និងយុត្តិធម៌ ពីព្រោះលទ្ធផលនេះគឺជាមធ្យោបាយឯករាជ្យមួយដែលជនជាប់ចោទ និងមេធាវីការពារក្តីជនជាប់ចោទអាចយកទៅអនុវត្តបាន ។ យ៉ាងណាមិញ ការព្រួយបារម្ភមួយចំនួនក៏កើតមានឡើងនៅក្នុងបរិបទតុលាការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ ក្រុមមេធាវីការពារក្តីនៅឯតុលាការខ្មែរក្រហមតែងតែចោទសួរពីសមត្ថភាពនៃប្រព័ន្ធច្បាប់អ៊ិនហ្គីស៊ីថូរៀល ដើម្បីធានាឲ្យបាននូវសិទ្ធិរបស់ជនជាប់ចោទពីព្រោះកិច្ចការនេះស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ចៅក្រមស៊ើបអង្កេតលើជនជាប់ចោទខ្លួនឯងផ្ទាល់ ។

## ការធានាការពារសិទ្ធិរបស់ជនជាប់ចោទ

គោលការណ៍សំខាន់មួយសម្រាប់អង្គជំនុំជម្រះព្រហ្មទណ្ឌដែលត្រឹមត្រូវ និងយុត្តិធម៌គឺសំដៅលើ «សមភាពរវាងភាគីទាំងអស់» ។ នេះសំដៅទៅលើសិទ្ធិក្នុងការទទួលការចូលរួមដោយស្មើភាព ដូច្នេះភាគីទាំងអស់នៃដំណើរការនីតិវិធីរបស់តុលាការត្រូវតែទទួលបានឱកាសសមរម្យមួយដើម្បីធ្វើជាតំណាងឲ្យករណីរបស់ខ្លួនទៅកាន់ចៅក្រមនៅក្រោមលក្ខខណ្ឌដែលមិនមានផលអវិជ្ជមានដល់គូបដិបក្សរបស់ខ្លួន ។ ប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល ជាទូទៅតែងតែទទួលរងការរិះគន់ថា មិនដើរតាមគោលការណ៍របស់ខ្លួនឲ្យបានពេញលេញ ជាពិសេសនៅក្នុងដំណាក់កាលស៊ើបអង្កេតដែលមេធាវីការពារជនជាប់ចោទមិនមានឱកាសច្រើនប៉ុន្មានក្នុងការធ្វើជាតំណាងឲ្យរឿងក្តីរបស់ខ្លួន ។ ឯព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតមានតួនាទីដឹកនាំ និងដាក់កម្រិតលើរឿងក្តី ។ នៅឯតុលាការខ្មែរក្រហមវិញ សហចៅក្រមស៊ើបអង្កេតបានចេញលិខិតទៅឲ្យមេធាវីការពារក្តីរបស់ នួន ជា ដែលធ្វើការហាមឃាត់មេធាវីការពារក្តីមិនឲ្យធ្វើការស៊ើបអង្កេតដោយខ្លួនឯងលើដំណើរការស៊ើបអង្កេតរបស់តុលាការឡើយ ។ បញ្ហានេះបានធ្វើឲ្យក្រុមមេធាវីការពារក្តីរបស់ អៀង សារី អះអាងថា ក្រុមមេធាវីការពារក្តីកំពុងតែទទួលរងនូវតួនាទីមិនស្មើភាពគ្នានឹងសហព្រះរាជអាជ្ញា ដោយសម្អាងលើការស៊ើបអង្កេតបឋមដែលសហព្រះរាជអាជ្ញាបានធ្វើឡើងសម្រាប់សំណុំរឿង០០២ ដែលចំណាយពេលអស់ជិតមួយឆ្នាំ ។ ការព្រួយបារម្ភគឺនៅត្រង់ថា ប្រព័ន្ធច្បាប់បែបនេះនឹងផ្តល់សារៈសំខាន់តែលើភស្តុតាងដាក់បន្ទុកដែលបណ្តាលឲ្យមានការស៊ើបអង្កេតដែលមិនមានតុល្យភាព ។ ទោះជាយ៉ាងណាក្តី វាពិតជាមានសារៈសំខាន់ក្នុងការចងចាំថា យោងតាមប្រព័ន្ធច្បាប់អ៊ិនហ្គីស៊ីថូរៀល សហព្រះរាជអាជ្ញាមានកាតព្វកិច្ចក្នុងការដាក់បញ្ចូលរាល់ភស្តុតាងទាំងអស់ដោយដឹងថា ភស្តុតាងទាំងនោះអាចជាភស្តុតាងដោះបន្ទុកចូលទៅក្នុងសេចក្តីសន្និដ្ឋានបឋមរបស់ខ្លួន ហើយបង្ហាញរាល់ព័ត៌មានដែលអាចគូសបញ្ជាក់ពីភាពស្អាតស្អំ

ឬសម្រាលទោសរបស់ជនសង្ស័យ ឬជនជាប់ចោទ ឬព័ត៌មានដែលប៉ះពាល់ដល់ភាពជឿជាក់លើភស្តុតាងរបស់ព្រះរាជអាជ្ញាទៅកាន់សហចៅក្រមស៊ើបអង្កេត ។ ប៉ុន្តែ ខុសពីសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញាមិនទាន់មានកាតព្វកិច្ចច្បាស់លាស់ណាមួយក្នុងការស្វែងរកភស្តុតាងដោះបន្ទុកនោះទេ ។ បើទោះបីជាវាគួរឲ្យឆ្ងល់ថាតើប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល នេះផ្ដោតតែមកលើភស្តុតាងដាក់បន្ទុកក៏ដោយ ក៏បញ្ហាអស់នេះអាចនឹងកើតឡើងនៅក្នុងរឿងក្ដីរបស់តុលាការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរជាជាងនៅក្នុងតុលាការព្រហ្មទណ្ឌធម្មតាដែរ ។

ជាទូទៅ ដោយសារតែតុលាការព្រហ្មទណ្ឌក្នុងប្រទេសដោះស្រាយតែសំណុំរឿងមួយក្នុងពេលតែមួយនោះ ភាពស្មុគស្មាញ និងការរីករាលដាលកាន់តែធំនៃឧក្រិដ្ឋកម្មសង្គ្រាមអាចបង្កជាឧបសគ្គមួយដល់ដំណើរការស៊ើបអង្កេត ។ សំណុំរឿង ០០២មានជនជាប់ចោទបួននាក់ដែលបានប្រព្រឹត្តអំពើសាហាវឃោរឃៅព្រៃផ្សៃនៅក្នុងអំឡុងពេលគ្រប់គ្រងរយៈពេលជិតបួនឆ្នាំរបស់ខ្លួនកាលពីសាមសិបប្រាំមួយឆ្នាំមុន ។ ទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្មមាននៅគ្រប់ទីកន្លែងនៃប្រទេសកម្ពុជា ហើយចំនួនជនរងគ្រោះវិញគឺរាប់មិនអស់ ។ ដោយគិតពីទំហំសំណុំរឿងដ៏ធំនេះ សហចៅក្រមស៊ើបអង្កេតមិនអាចរំពឹងថានឹងដំណើរការស៊ើបអង្កេតឲ្យបានទូលំទូលាយ ដោយពិចារណាទាំងករណីរបស់មេធាវីការពារក្ដី និងព្រះរាជអាជ្ញាបានឡើយ ។ ការស៊ើបអង្កេតមិនបានទូលំទូលាយបែបនេះអាចនាំមកនូវគ្រោះថ្នាក់មួយដែលថាលទ្ធផលដែលទទួលបានមានលក្ខណៈជាអត្តនោម័ត ជាងលទ្ធផលនៃរឿងក្ដីរបស់តុលាការព្រហ្មទណ្ឌធម្មតាដែលបានធ្វើការស៊ើបអង្កេតពេញលេញ ។ ឧទាហរណ៍នៃបញ្ហានេះ អាចជាជម្លោះលើឯកសារអេឡិចត្រូនិកដែលគេហៅថា «អេសអឹមឌី» ។ នៅខែមេសា ឆ្នាំ២០០៩ មេធាវីការពារជនជាប់ចោទបានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតស្វែងរកនូវភស្តុតាងដោះបន្ទុកនៅក្នុងសំណុំឯកសារ អេឡិចត្រូនិកនោះ ។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតបានបដិសេធច្រានចោលសំណើនេះ ដោយសម្អាងថាសហចៅក្រមគ្មានលទ្ធភាពក្នុងការរៀបចំភស្តុតាងទាំងអស់នោះទៅតាមផ្នែករបស់វាឡើយ ។ បន្ថែមលើនេះ យោងតាមសហចៅក្រមស៊ើបអង្កេត ការពេញចិត្តរវាងភាគីទាំងអស់អាចនឹងសម្រេចបាននៅពេលដែលការស៊ើបអង្កេតរបស់តុលាការបានកំណត់យកភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ជនជាប់ចោទ ហើយបានផ្ដល់ជាហេតុផលមួយដោយមានអំណះអំណាងពីសិទ្ធិរបស់ជនជាប់ចោទក្នុងការចូលខ្លួនមកកាត់ទោសតាមពេលវេលាសមរម្យមួយ ។ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការច្រានចោលសំណើរបស់មេធាវីការពារក្ដីត្រូវបានប្ដឹងឧទ្ធរណ៍ដែលអង្គបុរេជំនុំជម្រះរកឃើញថា តាមរយៈការលើកឡើងនូវហេតុផលដែលថា ចៅក្រមស៊ើបអង្កេតអាចបញ្ចប់ការស៊ើបអង្កេតបាន នៅពេលដែលចៅក្រមបានកំណត់ថាមានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ជនជាប់ចោទនោះ សហចៅក្រមស៊ើបអង្កេតបានបំភ្លេចចោលនូវកាតព្វកិច្ចបឋមរបស់ខ្លួនក្នុងការបញ្ចប់ការស៊ើបអង្កេតមុនពេលវាយតម្លៃថាតើរឿងក្ដីនោះគួរតែត្រូវបាននាំទៅជំនុំជម្រះក្ដីឬយ៉ាងណា ។

ដោយយល់ឃើញដូច្នេះ ប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល អាចទាញយកប្រយោជន៍ចេញពីមេធាវីការពារជនជាប់ចោទដែលមានសកម្មភាពក្នុងការដាក់សម្ពាធលើសហចៅក្រមស៊ើបអង្កេត ដោយធានាឲ្យបាននូវសំណុំរឿងក្ដីដែលមានតុល្យភាពដែលមិនពឹងផ្អែកលើសហចៅក្រមស៊ើបអង្កេតតែម្ខាង ហើយអាចធ្វើការឆ្លើយតបនឹងការរិះគន់ទាក់ទងនឹងការធានាការពារសិទ្ធិរបស់ជនជាប់ចោទ ជាពិសេសទាក់ទងនឹងតុលាការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដោយធ្វើការដោះស្រាយសំណុំរឿងស្មុគស្មាញបំផុតដែលនាំមកនូវភាពអត្តនោម័តជាក់លាក់មួយ ។

## ឯករាជ្យភាពរបស់ចៅក្រម

បើទោះបីជាវាគួរឲ្យកត់សម្គាល់ដែលថា កាលណាចៅក្រមស៊ើបអង្កេតកាន់តែមានគុណសម្បត្តិខ្ពស់ នោះចៅក្រមកាន់តែមានសមត្ថភាពធ្វើការងាររបស់ខ្លួនដោយឯករាជ្យ និងឥតលម្អៀង ក៏មេធាវីការពារក្ដីដែលមិនមានសកម្មភាពសកម្មប៉ុន្មាននោះអាចដើរតួយ៉ាងសំខាន់ក្នុងការធានាឲ្យបាននូវតុល្យភាពដែលត្រឹមត្រូវ និងយុត្តិធម៌ដែរ ។ មូលដ្ឋាននៃច្បាប់ស៊ីវិលឡូ គឺជាដំណើរការស៊ើបអង្កេតដែលដើរតួនាទីបានយ៉ាងល្អ ។ ការស៊ើបអង្កេតដែលធ្វើឡើងដោយចៅក្រមស៊ើបអង្កេតដែលមានទេពកោសល្យ

គឺជាការធានាដ៏ប្រសើរមួយនូវសិទ្ធិរបស់ជនជាប់ចោទ ។ ការផ្តល់អំណាចធំធេងមួយដល់អាជ្ញាធររដ្ឋអាចមានប្រយោជន៍ ហើយក៏អាចបង្កជាបញ្ហាពីព្រោះថា អំណាចភាគច្រើនអាស្រ័យលើការយល់ឃើញរបស់ចៅក្រមស៊ើបអង្កេត និងប្រព័ន្ធច្បាប់ដែលចៅក្រមស៊ើបអង្កេតអនុវត្ត ។ បញ្ហាប៉ះពាល់ដល់ប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល គឺជាការមិនជឿទុកចិត្ត និងការសង្ស័យថាមានភាពលម្អៀង និងការជ្រៀតជ្រែកផ្នែកនយោបាយ ។ ប្រព័ន្ធច្បាប់នេះមិនអាចដំណើរការទៅបានទេ ប្រសិនបើគ្មានការជឿទុកចិត្តលើប្រព័ន្ធច្បាប់ និងលើអ្នកបំពេញតួនាទីនោះ ។

តុលាការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរតែងតែត្រូវបានគេយល់ឃើញថា ប្រឈមមុខនឹងការជ្រៀតជ្រែក និងបម្រើផលប្រយោជន៍នយោបាយ ហើយតុលាការខ្មែរក្រហមក៏ដូច្នោះដែរ ។ ប្រវត្តិរបស់តុលាការខ្មែរក្រហមបង្ហាញឲ្យឃើញថារដ្ឋាភិបាលកម្ពុជាមិនចង់ឲ្យចំនួនចៅក្រមជាតិមានតិច ។ ដូច្នេះ នីតិវិធីបែករំលែកការងារដែលតម្រូវឲ្យមាន "សហ" ចៅក្រមស៊ើបអង្កេត ឬ "សហ" ព្រះរាជអាជ្ញាគឺជាដំណោះស្រាយរវាងភាគីពីរ គឺភាគីកម្ពុជា និងអង្គការសហប្រជាជាតិ ដែលភាគីទាំងពីរនេះមានបំណងចង់បានអំណាចគ្រប់គ្រងធំធេង ។ នៅក្នុងដំណាក់កាលចរចាអង្គការសហប្រជាជាតិបានបង្ហាញនូវភាពមិនជឿទុកចិត្តលើប្រព័ន្ធច្បាប់កម្ពុជា ដោយធ្វើការយល់ព្រមដោយស្ទាក់ស្ទើរ ហើយទស្សនៈបែបនេះវាមិនមែនជារឿងដែលកើតមានឡើងចំពោះតែអង្គការសហប្រជាជាតិនោះទេ ។ វិទ្យាស្ថានសង្គមយុត្តិធម៌បើកចំហបានរៀបរាប់នៅក្នុងរបាយការណ៍ ឆ្នាំ២០១០របស់ខ្លួនស្តីពីការជ្រៀកជ្រែកផ្នែកនយោបាយនៅតុលាការខ្មែរក្រហមដែលជាសេចក្តីព្រួយបារម្ភធំមួយសម្រាប់ចៅក្រមជាតិដែលត្រូវបានជ្រើសចេញពីប្រព័ន្ធច្បាប់កម្ពុជា ដែលត្រូវបានចាត់ទុកថាទទួលឥទ្ធិពលគ្រប់គ្រងពីផ្នែកនយោបាយមកបំពេញការងារនៅតុលាការខ្មែរក្រហម ។ វាគ្មានអ្វីគួរឲ្យសង្ស័យទេដែលថាច្បាប់កម្ពុជាប្រឈមមុខនឹងបញ្ហាសម្ពាធពីផ្នែកនយោបាយ ហើយការដែលមានសហចៅក្រមស៊ើបអង្កេតពីរនាក់ ដែលម្នាក់ជាចៅក្រមជាតិ និងម្នាក់ទៀតជាចៅក្រមអន្តរជាតិត្រូវបានរៀបចំឡើងដើម្បីជួយធានាឲ្យបាននូវការស៊ើបអង្កេតដែលប្រកបដោយភាពសុចរិត ។ ប៉ុន្តែ សូម្បីតែសហចៅក្រមអន្តរជាតិដែលជាអ្នកធានាឲ្យបាននូវការស៊ើបអង្កេតដែលត្រឹមត្រូវតាមផ្លូវច្បាប់ក៏មិនអាចឆ្លងកាត់ការធ្វើបញ្ហានេះ ឬ ដោះស្រាយបញ្ហាដុំវិញខ្លួនដោយភាពជឿជាក់ដែរ ។ ស្ទីវ ហេឌើ ដែលជាប្រវត្តិវិទូស្រាវជ្រាវពីប្រវត្តិសាស្ត្រខ្មែរក្រហមដ៏គួរឲ្យគោរព និងជាអតីតបុគ្គលិកបម្រើការឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតដែលទើបតែលាលែងពីតំណែងបាននិយាយថា ចៅក្រមបានបញ្ចប់ដំណើរការស៊ើបអង្កេតលើសំណុំរឿង០០៣ទៅ "យ៉ាងមានប្រសិទ្ធភាពដោយគ្មានការស៊ើបអង្កេតអ្វីសោះ" ដូច្នេះហើយលោក ហេឌើ និងអ្នកផ្សេងទៀតបាត់បង់នូវភាពជឿជាក់លើភាពដឹកនាំរបស់សហចៅក្រមស៊ើបអង្កេតដែលជាអ្នកបង្កនូវ "ភាពមិនជឿជាក់គ្នាទៅវិញទៅមក" នៅក្នុង "ការិយាល័យចៅក្រមស៊ើបអង្កេតដែលបច្ចុប្បន្នត្រូវបានចាត់ទុកថាជាការិយាល័យមិនដំណើរការតាមវិជ្ជាជីវៈរបស់ខ្លួន" ។ ចុងបញ្ចប់ ភាពមិនជឿទុកចិត្តគ្នានេះកាន់តែប៉ះពាល់ខ្លាំងដល់ប្រព័ន្ធច្បាប់ដែលតុលាការខ្មែរក្រហមអនុវត្ត ហើយប៉ះពាល់ដល់អ្នកដែលបំពេញតួនាទីនៅទីនោះ ។

ស្របពេលដែលវាមានភាពងឿងឆ្ងល់ថាតើប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល អាចធានាសិទ្ធិជនជាប់ចោទបានដល់កម្រិតណានោះទេ នៅពេលដែលប្រព័ន្ធច្បាប់នេះត្រូវបានយកមកអនុវត្តនៅក្នុងតុលាការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរ នោះយើងគួរតែពិចារណាថា ការបំពេញតួនាទីរបស់សហចៅក្រមស៊ើបអង្កេតបានបង្កឲ្យមានការព្រួយបារម្ភមួយចំនួន ។ ហើយការមិនជឿទុកចិត្តលើចៅក្រមស៊ើបអង្កេតមិនត្រូវមកលាយឡំជាមួយនឹងការមិនជឿទុកចិត្តលើប្រព័ន្ធច្បាប់ដែលយកមកអនុវត្តនោះទេ ។ ជាចុងក្រោយ ផលប្រយោជន៍នៃគំរូប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល អាចត្រូវសម្រេចបានប្រសិនបើការស៊ើបអង្កេតត្រូវបានធ្វើឡើងដោយមានប្រសិទ្ធភាព ។ ការធានានូវសិទ្ធិជនជាប់ចោទនៅក្នុងប្រព័ន្ធច្បាប់ ស៊ីវិលឡូ គឺពឹងផ្អែកទៅលើសមត្ថភាពរបស់សហចៅក្រម ។ ហើយឥរិយាបថផ្ទាល់ខ្លួនរបស់ចៅក្រមស៊ើបអង្កេត គឺពិតជាមានសារសំខាន់ដល់ដំណើរការនីតិវិធីព្រហ្មទណ្ឌបែប អ៊ិនហ្គីស៊ីថូរៀល ។ កាលណាមានការផ្តល់ការទទួលខុសត្រូវច្រើនទៅឲ្យតែស្ថាប័នមួយ ដូចដែលបានអនុវត្តប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល វា

ពិតជាមានគ្រោះថ្នាក់ក្នុងការដែលយើងចង់ស្ថាបនាស្ថាប័ននេះឡើង ដើម្បីកុំឲ្យជំរុញភាគីពាក់ព័ន្ធទាំងអស់ឲ្យមានការជឿជាក់ខ្ពស់ ។

**ប្រសិទ្ធភាព និង តម្លាភាព**

ជាចុងក្រោយ ចំណុចសំខាន់គឺការពិភាក្សាវែកញែកពីប្រសិទ្ធភាព និងតម្លាភាពដែលជាធាតុផ្សំដ៏សំខាន់នៅក្នុងតុលាការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ យោងតាមមាត្រា៩(២) នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជនជាប់ចោទមានសិទ្ធិទទួលបានការជំនុំជម្រះក្តីក្នុងរយៈពេលសមរម្យមួយ ។ នៅឯតុលាការខ្មែរក្រហម នៅមិនទាន់មានហេតុផលណាមួយដើម្បីដំណើរការអង្គជំនុំជម្រះក្តីឲ្យបានឆាប់រហ័សទាន់ពេលនៅឡើយទេ ។ ជនជាប់ចោទមានវ័យកាន់តែចាស់ ហើយមិនអាចរង់ចាំដល់ថ្ងៃចេញសាលក្រមកាត់ទោសរបស់ខ្លួនក៏ថាបាន ប្រសិនបើអង្គជំនុំជម្រះក្តីស៊ីពេលយូរ ហើយត្រូវបានពន្យារពេលជាបន្តបន្ទាប់ ។

ក្នុងស្ថានភាពបែបនេះ ប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល មានសក្តានុពលភាពខ្លាំង ។ ក្រោយពីការស៊ើបអង្កេតល្អិតល្អន់មកដំណាក់កាលអង្គជំនុំជម្រះក្តីជាក់ស្តែងដែលអនុវត្តតាមប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល អាចស៊ីពេលខ្លីតែប៉ុណ្ណោះ ។ យោងតាមទ្រឹស្តីនេះ អង្គជំនុំជម្រះក្តីអាចបញ្ចប់ទៅបានដោយផ្អែកទៅលើសំណុំឯកសារតែប៉ុណ្ណោះ ។ ហើយដោយសារតែសំណុំឯកសារនេះ ចៅក្រមទទួលបានសេចក្តីសង្ខេបរបស់សំណុំឯកសារនេះ ហើយអាចមានលទ្ធភាពគ្រប់គ្រងដំណើរការជំនុំជម្រះក្តីដោយមានប្រសិទ្ធភាព ។ ខុសពីអង្គជំនុំជម្រះក្តីរបស់ប្រព័ន្ធច្បាប់ អេដវឺសារៀល ដែលចាប់ផ្តើមឡើងដោយបើកអង្គសវនាការស្តីពីភ័ស្តុតាងមុនដំបូងគេ អង្គជំនុំជម្រះក្តីនៅក្នុងប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល ដើរតួជាមធ្យោបាយមួយក្នុងការគូសបញ្ជាក់លើព័ត៌មានលម្អិតដែលត្រូវរកឃើញនៅក្នុងអំឡុងដំណើរការស៊ើបអង្កេត ។ តុលាការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរប្រឈមមុខនឹងបញ្ហាពិសេសមួយទាក់ទងនឹងបញ្ហាខាងលើនេះ ។ លទ្ធផលនៃការដោះស្រាយបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដោយផ្អែកលើសំណុំឯកសារមានភាពស្មុគស្មាញកាន់តែខ្លាំងឡើង ជាងការដោះស្រាយសំណុំរឿងរបស់តុលាការព្រហ្មទណ្ឌធម្មតា ។ សម្រាប់ចៅក្រមអង្គជំនុំជម្រះក្តី វាគឺជាកិច្ចការដែលមិនអាចសម្រេចបានទេក្នុងការស្វែងរកឬសគល់នៃរឿងក្តីនោះ ។ ប៉ុន្តែ អង្គសវនាការតាមប្រព័ន្ធច្បាប់ អេដវឺសារៀល ក្នុងតុលាការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរអាចដើរតួលើសពី "ការគូសបញ្ជាក់" លើព័ត៌មានដែលរកឃើញដោយចៅក្រមស៊ើបអង្កេតទៅទៀត ។ ជាក់ស្តែង ការចូលរួមរបស់ភាគីផ្សេងៗគឺពិតជាមានសារសំខាន់ជាងនៅក្នុងរឿងក្តីព្រហ្មទណ្ឌតាមច្បាប់ស៊ីវិលឡូក្នុងស្រុក ដោយសារតែចៅក្រមអង្គជំនុំជម្រះអាចដើរតាមគោលជំហរស្រដៀងគ្នាដោយមិនចាំបាច់ធ្វើការយល់ដឹងទាំងស្រុងលើសំណុំរឿងក៏បានដែរ ។

យ៉ាងណាមិញ ដោយសារតែការស៊ើបអង្កេតមានលក្ខណៈសម្ងាត់ ប្រសិទ្ធភាពរបស់អង្គជំនុំជម្រះសាធារណៈអាចសម្រេចបានលុះត្រាតែមានតម្លៃនៃតម្លាភាព ។ បើទោះបីជាតម្លាភាពមិនមែនជាធាតុផ្សំនៃអង្គជំនុំជម្រះព្រហ្មទណ្ឌធម្មតាក៏ដោយ ក៏វាមានសារសំខាន់នៅក្នុងតុលាការកាត់ទោស ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ តុលាការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលមានចំនួនជនត្រូវចោទតិចមិនអាចបម្រើប្រយោជន៍ដល់យុត្តិធម៌សម្រាប់ការប្រព្រឹត្តអំពើសាហាវឃោរឃៅទ្រង់ទ្រាយធំបានទេ ។ ភាគីដែលជាប់ពាក់ព័ន្ធទាំងអស់ត្រូវតែចូលរួមនៅក្នុងដំណើរការជំនុំជម្រះក្តីនេះ ដើម្បីទទួលបានផលប្រយោជន៍សមរម្យពីអង្គជំនុំជម្រះនេះ ។ បន្ថែមលើនេះ តម្លាភាពនៅក្នុងតុលាការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរគឺជាមធ្យោបាយមួយដ៏សំខាន់ដើម្បីយកឈ្នះលើការជ្រៀតជ្រែកផ្នែកនយោបាយ ហើយវាកាន់តែមានសារសំខាន់សម្រាប់តុលាការ "កូនកាត់" ដែលតស៊ូទទួលបានការជឿទុកចិត្តលើភាពយុត្តិធម៌ដែលខ្លួនរំពឹងថានឹងអាចផ្តល់ឲ្យនោះ ។ គំរូនៃប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល ដែលដំណើរការអង្គសវនាការមានរយៈពេលខ្លី ហើយទទួលបានការគូសបញ្ជាក់លើព័ត៌មានដែលទទួលបានពីសហចៅក្រមស៊ើបអង្កេតនោះមិនបម្រើប្រយោជន៍អ្វីដល់តុលាការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរទេ ។ ភាពចាំបាច់នូវតម្លាភាពពិតជាសារសំខាន់ ។

ពេលដែលមានតម្លាភាព ប្រព័ន្ធច្បាប់អ៊ិនហ្គីស៊ីថូរៀល នាំមកនូវនីតិវិធីបំពេញកិច្ចការចំនួនពីរ និងប្រព័ន្ធប្រាំដែលមួយដែលពោរពេញទៅដោយការស៊ើបអង្កេតលាក់ការណ៍សម្ងាត់ស្មុគស្មាញ និងដំណើរការអង្គជំនុំជម្រះប្រាំដែលដែលស៊ីពេល

យូរ ។ ដោយមើលឃើញនូវភាពស្មុគស្មាញនៃរឿងក្តីនៅក្នុងតុលាការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរបែបនេះ នីតិវិធីច្បាប់ស៊ីវិលឡ ដែលទទួលរងនូវបញ្ហាលទ្ធិប្រជាធិបតេយ្យនេះគឺជានីតិវិធីដែលស៊ីពេលយូរ ហើយច្រំដែល ។ មានអ្នកអង្កេតការណ៍និងអ្នកចូលរួមជាច្រើនបានយល់ឃើញថា ប្រព័ន្ធច្បាប់ស៊ីវិលឡដែលត្រូវបានតុលាការខ្មែរក្រហមយកមកអនុវត្តនោះគឺជាបញ្ហារដ្ឋបាល ដែលនាំមកនូវភាពគ្មានប្រសិទ្ធភាព អង្គជំនុំជម្រះក្តីដែលស៊ីពេលយូរ និងការពន្យារពេលមិនសមហេតុផល ។ ប៉ុន្តែវាមានសារសំខាន់ក្នុងការពិចារណាស្វែងរកប្រព័ន្ធច្បាប់ជាក់លាក់មួយដែលធ្វើការគ្រប់គ្រងដំណើរការនីតិវិធីរបស់តុលាការខ្មែរក្រហមដែលមិនមែនស្ថិតនៅក្នុងសណ្ឋានជាច្បាប់ស៊ីវិលឡ ។ ដំណោះស្រាយផ្នែកនយោបាយដែលបណ្តាលមកពីការបែងចែងការងាររវាងសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត និងតម្រូវការចាំបាច់នូវយន្តការដោះស្រាយ គឺជាប្រសិទ្ធភាពមួយដ៏ចាំបាច់ ។ នៅក្នុងរឿងក្តីដែលពិបាក និងស្មុគស្មាញ រចនាសម្ព័ន្ធពីរដ៏ស្មុគស្មាញរួមផ្សំនឹងអង្គជំនុំជម្រះផ្សេងទៀតអាចនឹងធ្វើឲ្យមានការពន្យារដំណើរការអង្គជំនុំជម្រះក្តី ។

**សេចក្តីសន្និដ្ឋាន**

បើទោះបីជាចៅក្រមស៊ើបអង្កេតមានសក្តានុពលភាពធំធេងក្នុងការលើកកម្ពស់យុត្តិធម៌ផ្សះផ្សាតាមរយៈតុលាការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរក៏ដោយ ក៏ប្រព័ន្ធច្បាប់នេះប្រឈមនឹងបញ្ហាធ្ងន់ធ្ងរជាច្រើននៅក្នុងដំណើរការជាក់ស្តែងរបស់ខ្លួនក្នុងការដោះស្រាយរឿងក្តីស្មុគស្មាញ និងសំណុំរឿងធំៗដែរ ។ ប្រសិទ្ធភាពនៃប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល នៅមានកម្រិត បើយើងនិយាយពីរឿងតម្លាភាព ។ ដូច្នេះ នីតិវិធីថ្មីមួយត្រូវតែតាក់តែងឡើងដើម្បីពង្រឹកប្រព័ន្ធច្បាប់នេះដោយធានាកត្តាតម្លាភាព និងប្រសិទ្ធភាព ។ ចុងក្រោយ ប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីថូរៀល អាចមានការជឿជាក់ខ្លាំង និងមិនមានការជឿជាក់ខ្លាំង ដូច្នេះប្រព័ន្ធច្បាប់នេះមិនអាចហុចជាប្រយោជន៍ដល់ប្រព័ន្ធច្បាប់ ដែលធ្វើការដោះស្រាយនឹងអង្គជំនុំជម្រះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដោយធ្វើការជាមួយនឹងតុលាការដែលមិនគួរឲ្យជឿទុកចិត្ត និងទទួលរងការជ្រៀតជ្រែកពីផ្នែកនយោបាយបានឡើយ ។ ក្នុងបរិបទបែបនេះ សិទ្ធិរបស់ជនជាប់ចោទមិនអាចត្រូវបានការពារបានទេ លុះត្រាតែតួនាទីរបស់មេធាវីការពារក្តីនៅតែមានកម្រិត ។

**លីស រ៉ូស ម៉ូហ្វ**



# ការពិនិត្យមើលសារឡើងវិញលើការចរចារឆ្ពោះទៅរកការ បង្កើតយុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## *សេចក្តីផ្តើម*

*ក្នុងខែតុលា ឆ្នាំ២០០៤ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមានបទបញ្ញត្តិចែងទាក់ទងនឹងការបកស្រាយភាសាទេ ។ ទោះជាយ៉ាងណាក្តី កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្តីពីសន្ធិសញ្ញាអន្តរជាតិដែលណែនាំនិងប្រាប់នៅក្នុងកំណែទម្រង់ចុងក្រោយនៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងមានចែងក្នុងមាត្រា២ថា កិច្ចព្រមព្រៀងអនុលោមតាមអនុសញ្ញាទីក្រុងវៀនស្តីពីច្បាប់សន្ធិសញ្ញា ។*

*អនុសញ្ញាទីក្រុងវៀនពិចារណាយ៉ាងល្អិតល្អន់ពីក្រមនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិទៅលើកម្មវត្ថុនៃការបកស្រាយសន្ធិសញ្ញា ។ មាត្រា៣១នៃអនុសញ្ញាចែងថា សន្ធិសញ្ញាជាទូទៅគួរតែត្រូវបានបកប្រែឲ្យមាន «សច្ចភាពត្រឹមត្រូវទៅតាមអត្ថន័យដែលចែងនៅក្នុងសន្ធិសញ្ញា នៅក្នុងបរិបទរបស់សន្ធិសញ្ញានោះ និងនៅក្នុងកម្មវត្ថុនិងគោលបំណងរបស់សន្ធិសញ្ញា» ។*

*មាត្រា១នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា ៖ «ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានទៅនឹងក្រមព្រហ្មទណ្ឌច្បាប់មនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ មករា ឆ្នាំ១៩៧៩ ។»*

*មាត្រា១នៃកិច្ចព្រមព្រៀងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាចែងថា ៖ គោលបំណងរបស់កិច្ចព្រមព្រៀងនេះគឺ «កំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា» នៅក្នុងដំណើរការកាត់ទោសខ្មែរក្រហមដែលមានចែងជាអត្ថបទនៅក្នុងមាត្រា១នៃច្បាប់បង្កើតសាលាក្តីខ្មែរក្រហមដែលកំណត់អត្ថន័យដូចគ្នា ។*

*នៅក្នុងករណីជាពិសេសដែលធ្វើការកំណត់ថាជនណាខ្លះស្ថិតនៅក្រោមយុត្តាធិការបុគ្គលដែលត្រូវតែ «ទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្ម និងការរំលោភបំពានធ្ងន់ធ្ងរ...» អង្គភាពច្បាប់នៃយុត្តាធិការមិនគ្រាន់តែមើលលើអត្ថន័យសាមញ្ញនៃពាក្យទាំងនោះប៉ុណ្ណោះទេ ប៉ុន្តែក៏ក្រឡេកមើលលើបរិបទកម្មវត្ថុនិងគោលបំណងនៃកិច្ចព្រមព្រៀងដែរ ។ នៅក្នុងករណីនេះដដែលវាលេចចេញច្បាស់លាស់ថាទម្រង់ផ្នែកនៃច្បាប់សាលាក្តីខ្មែរក្រហមនៅក្នុងបរិបទនៃកិច្ចព្រមព្រៀងដែលអនុលោមតាមមាត្រា៣១(២)នៃអនុសញ្ញាទីក្រុងវៀនស្តីពី «អនុស្សរណៈយោគយល់ដែលបង្កើតឡើងដោយភាគីម្ខាង ឬភាគីច្រើនដែលមានចែងនៅក្នុងការចុះហត្ថលេខាលើសន្ធិសញ្ញា» ។*

*លើសពីនេះទៅទៀត យោងទៅតាមមាត្រា៣២នៃអនុសញ្ញាទីក្រុងវៀនអនុញ្ញាតឲ្យមានបណ្តឹងសើរើទៅលើ «ការដែលបកស្រាយមិនច្បាស់លាស់ទាក់ទងនឹងពាក្យថា «ទំនួលខុសត្រូវខ្ពស់បំផុត» ទៅនឹងសេចក្តីព្រាងពីមុននៃកិច្ចព្រមព្រៀងអង្គការសហប្រជាជាតិនិងកាលៈទេសៈនៃការចុះហត្ថលេខា ។ ជាការពិតនៅក្នុងករណីនេះ កាលៈទេសៈនោះត្រូវបានចងភ្ជាប់ទៅនឹងប្រវត្តិចរចានៃច្បាប់សាលាក្តីខ្មែរក្រហមផ្ទាល់ ។*

*យោងទៅតាមប្រវត្តិសាស្ត្រនៃការវិភាគកន្លងមកទៅលើការចរចារយៈពេលវែងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាដែលភាគច្រើនមានការចូលរួមលូកដៃពីសំណាក់សហរដ្ឋអាមេរិកដែលធ្វើឲ្យព្រួយបារម្ភទៅលើយុត្តាធិការបុគ្គលរបស់សាលាក្តីខ្មែរក្រហម ដែលផ្តោះទៅរកការរាប់បញ្ចូលនៃពាក្យ*

ថា "ទំនួលខុសត្រូវខ្ពស់បំផុត" ទាំងនៅក្នុងច្បាប់សាលាក្តីខ្មែរក្រហម កម្ពុជា និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជាគឺជាចំណាប់អារម្មណ៍ខ្លាំងបំផុត និងភាពម៉ឺងម៉ាត់ទៅនឹងបច្ចុប្បន្នភាពនៃការត្រិះរិះពិចារណាលើប្រព័ន្ធយុត្តាធិការសាលាក្តីខ្មែរក្រហមដែលរួមមានដំណោះស្រាយវិវាទដែលកំពុងតែកើតមាន ហើយដែលជាការព្រួយបារម្ភពីការកើនឡើងនៃការស៊ើបអង្កេតនៅសាលាក្តីខ្មែរក្រហម ។

## សាធារណរដ្ឋប្រជាមានិតកម្ពុជា

ការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានៅខែធ្នូ ឆ្នាំ១៩៧៨ បានផ្តល់ឲ្យមានការកកើតគោលនយោបាយ និងគោលការណ៍ច្បាប់នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ សាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានប្រកាសនៅក្នុងខែមករា ឆ្នាំ១៩៧៩ បន្ទាប់ពីការរលំរលាយនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជានិងការភៀសខ្លួនរបស់កម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ដែលដឹកនាំដោយលេខាបក្ស ប៉ុល ពត ទៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ជាទីតាំងដែលខ្មែរក្រហមនៅសេសសល់ទាំងនោះបង្កើតជាសង្គ្រាមឈ្លបប្រឆាំងនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងអ្នកគាំទ្រប្រទេសវៀតណាម ។ នៅក្នុងចំណោមសមាជិកដំបូងនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានេះគឺជាអតីតកម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជាដែលរត់គេចទៅកាន់ប្រទេសវៀតណាមនាពាក់កណ្តាលឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ អំឡុងពេលនៃការធ្វើបន្សុទ្ធកម្មក្នុងជួរបក្សកុម្មុយនីស្តកម្ពុជាមានដូចជា ហេង សំរិន, ជា ស៊ីម និង ហ៊ុន សែន ។ អ្នកទាំងបីនេះគឺជាមន្រ្តីរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលមាន ហេង សំរិន ជាប្រមុខរដ្ឋ ជា ស៊ីម ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ហ៊ុន សែន ជានាយករដ្ឋមន្ត្រី ។

សេចក្តីថ្លែងការណ៍របស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានបែងចែកអតីតកម្មាភិបាលជាន់ខ្ពស់ផ្នែកនយោបាយ និងយោធារបស់បក្សកុម្មុយនីស្តកម្ពុជាជាបីថ្នាក់ ។ នៅជាន់ខ្ពស់បំផុតគឺក្រុមមនុស្សទាំងឡាយដែលត្រូវចាត់ទុកថាជា "មេដឹកនាំ" កម្ពុជាប្រជាធិបតេយ្យ ។ ថ្នាក់ទីពីរគឺក្រុមមនុស្សដែលហៅថា "កម្មាភិបាល" ផ្នែករដ្ឋបាល និង "មន្ត្រី" យោធា ។ ថ្នាក់ក្រោមបំផុតគឺជាអ្នកដែលត្រូវបានចាត់ទុកថា "កងកម្លាំង" យោធា ។ ដោយសម្អាងទៅលើអំពើឃោរឃៅដែលប្រព្រឹត្តឡើងអំឡុងពេលនៃការកាន់អំណាចរបស់របបកម្ពុជាប្រជាធិបតេយ្យ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបង្កើតថ្មី "ដើម្បីដាក់ទណ្ឌកម្មយ៉ាងឃោរឃៅដល់មេដឹកនាំដែលជាជនក្បត់គ្រោះថ្នាក់ដល់ប្រទេសជាតិធ្លាប់ប្រឆាំងនឹងប្រជាជន និងជិពាក់បំណុលឈាមប្រជាជន ដែលទាំងនេះសំដៅទៅលើការប្រព្រឹត្តបទល្មើសដែលសាហាវឃោរឃៅខណៈពេលដែលបក្សកម្មុយនីស្តកម្ពុជានៅកាន់កាប់អំណាច" ។ ទោះជាយ៉ាងណាក្តី របបថ្មីនេះសន្យាថា "ការអត់ឱនទៅលើនរណាដែលមានភាពស្មោះត្រង់ និងអ្នកដែលកែប្រែកំហុសរបស់ខ្លួន" និង "សរសើរ និងលើកទឹកចិត្តនរណាដែលបង្ហាញពីសមិទ្ធផលដ៏ក្លាហាននៅក្នុងនាមបដិវត្តន៍" ឧទាហរណ៍ដល់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាជាដើម ។ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាប្រកាសថា ខ្លួនត្រៀមរួចជាស្រេចដើម្បី "ស្វាគមន៍យ៉ាងកក់ក្តៅ និងបង្កើតឲ្យមានស្ថានភាពផាសុខភាពសម្រាប់អតីតកម្មាភិបាល និងយោធា" នៅក្នុងកងកម្លាំងបក្សកម្មុយនីស្តកម្ពុជា និង "សម្រាប់កម្មាភិបាល និងបុគ្គលិកដែលក្បត់នឹងកម្ពុជាប្រជាធិបតេយ្យ ហើយត្រឡប់ទៅពួតដៃជាមួយប្រជាជនវិញ" ។

នៅខែមេសា ឆ្នាំ១៩៧៩ សាធារណរដ្ឋប្រជាមានិតកម្ពុជាបានធ្វើការស៊ើបសួរពីជនទាំងឡាយណាដែល "សម្លាប់រង្គាល" ប្រជាជននៅក្រោមបក្សកុម្មុយនីស្ត ប៉ុន្តែនិយាយថា សាធារណរដ្ឋប្រជាមានិតកម្ពុជាលើកលែងបុគ្គលច្រើនរូបគឺ ប៉ុល ពត និងរដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ និងសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្ស អៀង សារី និងជនទាំងឡាយណាដែល "បម្រើផលប្រយោជន៍" នៃបដិវត្តន៍ថ្មីដែលត្រូវបានទទួលការលើកលែងទោសចោទប្រកាន់ ។ វិធីព្យាបាទដ៏ឃោរឃៅគឺកំណត់ទៅលើជនទាំងឡាយណាដែល "ចចេសរឹងរូស" ប្រឆាំងនឹងសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលមិនគិតពីអ្វីដែលអ្នកទាំងនោះបានធ្វើពីមុនមក ឬក៏មិនបានប្រព្រឹត្តពីមុនឡើយ ។ តុលាការប្រជាជនបដិវត្តន៍ដែលត្រូវបានបង្កើតឡើងដើម្បីកាត់ទោស និង "ដាក់ទោសយ៉ាងធ្ងន់ធ្ងរ" ដល់អ្នកទាំងឡាយណាដែលជាសត្រូវនៃរបបថ្មី ។

នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៩ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាប្រកាសឲ្យប្រើប្រាស់ក្រឹត្យដែលអនុម័តថា «តុលាការប្រជាជនបដិវត្តន៍វិនិច្ឆ័យទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើក្រុមប៉ុល ពត និង អៀង សារី» ។ ប្រធានតុលាការប្រជាជនបដិវត្តន៍ កែវ ចិន្តា ប្រើប្រាស់ពាក្យថា «មេដឹកនាំ» ដើម្បីកំណត់ពី ប៉ុល ពត និង អៀង សារី នៅពេលដែលប្រធានតុលាការរូបនេះពន្យល់ថា តុលាការប្រជាជនបដិវត្តន៍បានសម្រេចថា ខ្លួនវិនិច្ឆ័យទោស ប៉ុល ពត និង អៀង សារី ពីបទ «ប្រព្រឹត្តឧក្រិដ្ឋកម្មនានាជាច្រើន» ដែលធ្វើឲ្យអ្នកទាំងពីរនេះត្រូវបានកំណត់និយមន័យជាមេដឹកនាំ ។ សម្រាប់ជនដទៃទៀតដែលអនុក្រឹត្យច្បាប់គឺសំដៅទៅរក «រណសិរ្សកុម្មុយនីស្ត និងដែលបន្ត «គោលនយោបាយមេត្តាធម៌ និងភាពប្រកបដោយមេត្តាធម៌យោងទៅតាមជនណាដែលបានចូលរួមកងកម្លាំង ឬរដ្ឋអំណាចរបស់ ប៉ុល ពត និង អៀង សារី» មិនថាយ៉ាងណាទេ ឲ្យតែអ្នកទាំងនោះ «កែខ្លួនដោយស្មោះត្រង់» ។ តុលាការប្រជាជនបដិវត្តន៍នឹងផ្តល់រង្វាន់ចំពោះនរណាដែលសាងសមិទ្ធផលដល់បដិវត្តន៍ថ្មីក្នុងភាពអង់អាចក្លាហានក្នុងនាមបដិវត្តន៍» ។ នៅខែសីហា ឆ្នាំ១៩៧៩ តុលាការរកឃើញថា ប៉ុល ពត និង អៀង សារី មានកំហុសលើ «ការសម្លាប់រង្គាលជាប្រព័ន្ធទៅលើប្រជាជនគ្រប់ជាន់ថ្នាក់យ៉ាងសាហាវឃោរឃៅបំផុត» ។ សាលក្រមលើកឡើងថា «ជនទាំងនោះគួរតែត្រូវ «ទទួលខុសត្រូវសម្រាប់ការបង្គាប់បញ្ជា និងគម្រោងការជាចារីនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍» និងទំនួលខុសត្រូវជាបុគ្គលសម្រាប់អំពើរបស់ខ្លួនពីព្រោះ «ប៉ុល ពត...ងារជាមន្ត្រីជាន់ខ្ពស់របស់ការិយាល័យជាន់ខ្ពស់បំផុត» និង អៀង សារី «មេដឹកនាំជាន់ខ្ពស់ដែលមានអំណាចពិតប្រាកដ និងបែងចែកអំណាចជាមួយ ប៉ុល ពត» ដែលពិនិត្យពិច័យយ៉ាងច្បាស់ថាជាមេដឹកនាំ ។ សាលក្រមកំណត់ថា ប៉ុល ពត បាន «រៀបចំផែនការ និងខ្សែបន្ទាត់គោលការណ៍បរទេស និងនយោបាយជាច្រើន និងកិច្ចប្រតិបត្តិការផ្ទាល់» ហើយ អៀង សារី ដែលជារដ្ឋមន្ត្រីក្រសួងការបរទេសគឺ «ទទួលខុសត្រូវដោយផ្ទាល់លើការសម្លាប់បញ្ញវន្ត និងនិស្សិតដែលកំពុងរស់នៅក្នុងប្រទេសឬត្រឡប់មកពីបរទេសវិញ ។»

ដូច្នេះ ខណៈដែលគោលនយោបាយរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាចង្អុលបង្ហាញពីរបបកម្ពុជាប្រជាធិបតេយ្យដែលរួមមានបីកម្រិតនៃថ្នាក់ដឹកនាំ និងរៀបចំការកាត់ទោសមេដឹកនាំជាន់ខ្ពស់ដែលជាគោលនយោបាយ ដោយសេចក្តីព្រមព្រៀងដោយចែងថា ក្រៅពី ប៉ុល ពត និង អៀង សារី ចំពោះអ្នកផ្សេងទៀតដែលរត់ចោលរបបកម្ពុជាប្រជាធិបតេយ្យមុននឹងបង្កើតសាធារណរដ្ឋប្រជាមានិតកម្ពុជានឹងរួចផុតពីការកាត់ទោសឬដាក់គុក ។ ទោះបីជាមានការលើកលែងមួយចំនួននៅក្នុងច្បាប់នេះក្តី ក៏អតីតកម្មាភិបាលបក្សកុម្មុយនីស្តដែលផ្តាច់ខ្លួននៅរវាងឆ្នាំ១៩៧៧ ដល់១៩៧៩ត្រូវបានរួមបញ្ចូលទៅក្នុងរដ្ឋបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរចនាសម្ព័ន្ធយោធានៅគ្រប់ជាន់ថ្នាក់ទាំងអស់ និងជនទាំងឡាយដែលចាកចេញពីបក្សនៅឆ្នាំបន្ទាប់មកទៀតត្រូវបានរួចខ្លួនដោយពុំមានទោសអ្វីទាំងអស់ ។ យោងតាមរបាយការណ៍ផ្ទៃក្នុងចែងថា នៅក្នុងចំណោមជនទាំងឡាយណាដែលក្លាយទៅជាកម្មាភិបាលរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែល «មួយចំនួនជំពាក់ឈាមប្រជាជនដែលបានធ្វើការកាប់សម្លាប់ដោយផ្ទាល់ ឬចេញពីបញ្ជាដោយផ្ទាល់ឲ្យសម្លាប់...ឬជនទាំងឡាយណាដែលរាយការណ៍ឈ្មោះទៅថ្នាក់លើដើម្បីសម្លាប់» ។ ទោះជាយ៉ាងណាក្តី ទំនួលខុសត្រូវរបស់កម្មាភិបាលទាំងនោះគឺ «ពិនិត្យនិងពិចារណាបញ្ហានៃការជំពាក់បំណុលឈាមពីព្រោះនៅក្រោមរបបខ្មែរក្រហមកម្មាភិបាលមួយចំនួន ធ្វើសកម្មភាពដោយផ្ទាល់និងមនុស្សមួយចំនួនធ្វើសកម្មភាពដោយប្រយោលពីចម្ងាយ និងកម្មាភិបាលមួយចំនួនបានជំពាក់ឈាមច្រើន ហើយខ្លះមានជំពាក់ឈាមតិច ។ កម្មាភិបាលខ្លះត្រូវបានបង្ខំឲ្យធ្វើការសម្លាប់ ហើយខ្លះទៀតធ្វើការសម្លាប់ដោយខ្លួនឯងដោយគ្មាននរណាបង្ខំឡើយ ។ ទោះបីជាយ៉ាងក៏ដោយ សម្រាប់អ្នកដែលធ្លាប់ឈឺចាប់ផ្ទាល់ដោយសារស្នាដៃរបស់ ប៉ុល ពត ហើយបានក្រោកឡើងប្រឆាំងនឹង ប៉ុល ពត មិនត្រូវបានចាត់ទុកថាជាការជំពាក់បំណុលឈាមឡើយ ។ ដំណោះស្រាយល្អបំផុតគឺដាក់អ្នកនោះឲ្យរស់នៅឆ្ងាយពីកន្លែងដែលប្រជាជនដែលធ្លាប់ដឹងឮពីការសម្លាប់របស់កម្មាភិបាលនោះរស់នៅ ។

សម្រាប់អតីតកម្មាភិបាលរបស់បក្សកុម្មុយនីស្តដែលត្រឡប់មកមាតុប្រទេសវិញនាអំឡុងពេលមួយទសវត្សរ៍កន្លងមក

អ្នកទាំងនោះត្រូវបានដាក់ឈ្មោះថាជាជន “វង្វេងផ្លូវ” ហើយអ្នកទាំងនោះត្រូវបានផ្តល់គោលនយោបាយ “ត្រឡប់មកលំនៅដ្ឋានវិញដើម្បីជួបជុំគ្រួសារ និងប្រទេសជាតិ” ក្រោយពីទទួលបានការអប់រំមួយរយៈមក ។ សមាជិកមួយចំនួនដែលល្អៗក្នុងចំណោមអ្នកទាំងអស់នេះត្រូវបានបញ្ចូលជាសមាជិករដ្ឋាភិបាលថ្មីរបស់ជាតិ ។ ខណៈពេលដែលថ្នាក់ដឹកនាំមួយក្តាប់តូចរបស់ខ្មែរក្រហមថ្នាក់ទាបត្រូវបានកាត់ទោសដោយសារតែអ្នកនោះនៅតែបន្តការប្រឆាំងនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា របបនេះចាប់ផ្តើមនៅឆ្នាំ១៩៨១ ដើម្បីធ្វើការកាត់ទោសតែថ្នាក់ដឹកនាំពីរនាក់ប៉ុណ្ណោះគឺ ប៉ុល ពត និង អៀង សារី ពីបទឧក្រិដ្ឋកម្មនានាដែលបង្កឡើងដោយបក្សកុម្មុយនីស្តកម្ពុជាពីឆ្នាំ១៩៧៥ដល់១៩៧៨ ។ នៅឆ្នាំ១៩៨១ បក្សកុម្មុយនីស្តកម្ពុជាប្រកាសថាខ្លួនរំលាយបក្ស ប៉ុន្តែការដឹកនាំពីមុននៅតែបន្តតួនាទីនៅក្រោមគណៈអចិន្ត្រៃយ៍មជ្ឈិមបក្សដែលរួមបញ្ចូលសមាជិកមុនឆ្នាំ១៩៧៩ ដែលនៅសេសសល់ដូចជា ប៉ុល ពត, នួន ជា, តាម៉ុក, អៀង សារី និង សុន សេន និងសមាជិកថ្មីដែលមានឋានន្តរសក្តិដូចជា ខៀវ សំផន និង កែ ពក ដែលអ្នកទាំងពីរនេះជាអតីតសមាជិកមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ។ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានបំផុសឲ្យមានការបះបោរដើម្បីទម្លាក់អាវុធ ហើយ “មេដឹកនាំ” និងអាចត្រូវបាននាំខ្លួនទៅកាន់តុលាការអន្តរជាតិដូចគ្នាទៅនឹងរបបណាហ្ស៊ីរបស់អាឡឺម៉ង់ដែលត្រូវបានកាត់ទោសនៅនូរ៉េមប៊ឺកដែរ” ។ ជាច្រើនឆ្នាំបន្ទាប់មកទៀត មិនមានរាយឈ្មោះច្បាស់លាស់ជាសាធារណៈថា ជនណានឹងអាចរាប់បញ្ចូលនៅក្នុងចំណោម “មេដឹកនាំ” ខ្មែរក្រហមដែលត្រូវយកមកកាត់ទោសទេប៉ុន្តែក្រៅពីប៉ុល ពត និង អៀង សារី និងអាចលើកឡើងពីខៀវ សំផន និង សុន សេន ដែរនៅក្នុងបរិបទដែលស្នើឡើងថាអ្នកទាំងពីរនេះគឺផ្នែកមួយនៃនយោបាយ ឬមេដឹកនាំយោធា ហើយ នេះជាអ្វីដែលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាហៅថា “ក្រុមបក្សពួកខ្មែរក្រហម” ឬ “ជើងកាង ប៉ុល ពត” ។ សេចក្តីសម្គាល់នេះកំពុងតែដើរស្របគ្នាទៅនឹងតម្រូវការមួយថា “ចាំបាច់ត្រូវតែបំបាត់ចោលទាំងផ្នែកនយោបាយ និងយោធា” របស់ខ្មែរក្រហម និងលើកឡើងថា “បុគ្គលម្នាក់ៗ ឬក្រុមនីមួយៗ” ដែលចាកចេញពី ប៉ុល ពត អាចចូលរួមនៅក្នុងជីវិតនយោបាយនៅក្នុងប្រទេស ។ នៅឆ្នាំ១៩៨៦ បន្ទាប់ពីរដ្ឋមន្ត្រីក្រសួងការបរទេសអូស្ត្រាលីលោក បៀល ហេឌិន យល់ព្រមទៅនឹងសំណើរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងការបង្កើតឲ្យមានតុលាការអន្តរជាតិ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានលើកឡើងថា “ប៉ុល ពត និងក្រុមបក្សពួក” ត្រូវតែទទួលទោស ។ ទាំងនេះមានន័យថា សាលក្រមនៅឆ្នាំ១៩៧៩ ដែលបានដាក់ទោសមេដឹកនាំខ្មែរក្រហម ប៉ុល ពត និង អៀង សារី គួរតែកាត់ទោសនៅក្នុងតុលាការអន្តរជាតិបន្ថែមទៀត ។ ពីឆ្នាំ១៩៨៧ដល់ឆ្នាំ១៩៨៨ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាទទូចឲ្យមានការបង្កើតយុត្តាធិការតុលាការមួយ ។ ប្រមុខរដ្ឋនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ហេង សំរិន កំណត់ថា “អំពើប្រល័យពូជសាសន៍បង្កឡើងដោយ ប៉ុល ពត និងក្រុមរបស់គាត់” ដែលរួមមាន ប៉ុល ពត ផ្ទាល់ និងភរិយា ខៀវ ប៉ុណ្ណារី, អៀង សារី និងភរិយាឈ្មោះ អៀង ធីរិទ្ធ និង នួន ជា ។ ហេង សំរិន ចាត់ទុកអ្នកទាំងនេះថា “មិនអាចលើកលែងទោសបាន” ឡើយ ហើយថាជនទាំងនេះគឺជាឧក្រិដ្ឋជនដែលនឹងត្រូវយកមកកាត់ទោស ។

នាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្តល់នូវបញ្ជីឈ្មោះបេក្ខជនដែលចាត់ទុកថាជា “មេដឹកនាំខ្មែរក្រហម” ដោយលើកឡើងថាអ្នកទាំងនេះត្រូវតែដកចេញពីជីវិតនយោបាយកម្ពុជា ។ អ្នកទាំងនោះគឺ ប៉ុល ពត, អៀង សារី, អៀង ធីរិទ្ធ, ខៀវ សំផន, សុន សេន, ម៉ុក, នួន ជា, និង កែ ពក ។ អ្នកទាំងអស់នេះមានឈ្មោះនៅក្នុងបញ្ជីដែលនាយករដ្ឋមន្ត្រី ហ៊ុន សែន ចោទប្រកាន់នៅពេលដែលគាត់សរសេរលិខិតទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានអះអាងថា “ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៃរបបខ្មែរក្រហម” គួរតែត្រូវបាន “នាំខ្លួនទៅវិនិច្ឆ័យទោស” ។ នៅពេលនោះដែរ ថ្នាក់ដឹកនាំកំពូលរបស់ខ្មែរក្រហមត្រូវបានផ្លាស់ប្តូរទម្រង់ ហើយក្នុងនោះក៏រាប់បញ្ចូល ប៉ុល ពត, នួន ជា, ម៉ុក, អៀង សារី, សុន សេន, ខៀវ សំផន និងសមាជិកថ្មីដូចជា សំ ប៊ិត និង មាស មុត ។ កែ ពក ត្រូវបានដកតំណែងទាំងអស់ ហើយគាត់បានចូលនិវត្តន៍ ។ អៀង ធីរិទ្ធ ដែលជារដ្ឋមន្ត្រីសង្គមកិច្ចរបស់របបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែមិនមែនជាសមាជិករបស

គណៈកម្មាធិការអចិន្ត្រៃយ៍បក្សនៅពេលដែលបក្សកុម្មុយនីស្ត កម្ពុជាកំពុងកាន់អំណាចដែលត្រូវបានបញ្ចុះស័ក្តិទៅជាលេខាធិការ របស់ក្រសួងការបរទេសក្រោយឆ្នាំ១៩៧៩ ។

## រដ្ឋកម្ពុជានិងកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១

នាយករដ្ឋមន្ត្រី ហ៊ុន សែន រំពឹងទុកការវិនិច្ឆ័យទោសលើ បេក្ខជនទាំងប្រាំបីរូបសម្រាប់គាត់ទោសដែលជាផ្នែកមួយនៃការ ព្រមព្រៀងនយោបាយនៃជម្លោះប្រដាប់អាវុធរវាងរបប សាធារណរដ្ឋប្រជាមានិតកម្ពុជា និងភាគីម្ខាងទៀតគឺខ្មែរក្រហម និងក្រុមកងកម្លាំងប្រឆាំងដែលជាសម្ព័ន្ធមិត្តជាមួយខ្មែរក្រហមគឺ ហ្វុនស៊ិនប៉ិច ក្រោមការដឹកនាំរបស់ព្រះមហាក្សត្រនរោត្តម សីហនុ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ទទួចថា ដំណោះស្រាយទាំង នោះតម្រូវឲ្យរំសាយកងកម្លាំងប្រដាប់អាវុធរបស់ ប៉ុល ពត ប៉ុន្តែអាចអនុញ្ញាតឲ្យមានការចូលរួមផ្នែកនយោបាយនៅក្នុងការ បោះឆ្នោតក្រោយជម្លោះដោយខ្មែរក្រហមដទៃទៀតជាជាងអ្នក ទាំងឡាយណាដែលមាននៅក្នុងបញ្ជីឈ្មោះរបស់គាត់ ។ អ្វីដែល ត្រូវបានបង្ហាញឲ្យឃើញពីការបែងចែកយ៉ាងដាច់ស្រឡះ ហ៊ុន សែន បង្ហាញជាពិសេសថា គាត់ចង់ឃើញការនាំខ្លួន «ទៅរកការ វិនិច្ឆ័យទោសចំពោះការទទួលខុសត្រូវពីសំណាក់មេដឹកនាំ ប៉ុល ពត នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍» ដែលចង្អុលបង្ហាញដោយ ប្រយោលទៅលើជនទាំងប្រាំបីរូបផ្សេងទៀតដែរ ។ ស្រដៀងគ្នា នេះដែរ អ្នកទាំងនោះរួមមាន «ក្រុមបក្សពួក ប៉ុល ពត» ដែល រដ្ឋាភិបាល ហ៊ុន សែន នៅខណៈពេលដែលប្តូរឈ្មោះជាថ្មីថា ជារដ្ឋកម្ពុជាលើកឡើងថា «ត្រូវតែនាំខ្លួនទៅវិនិច្ឆ័យទោសដោយ តុលាការអន្តរជាតិ» និងកាត់ទោស «អនុលោមតាមអនុសញ្ញា អង្គការសហប្រជាជាតិស្តីពីការការពារនិងការដាក់ទណ្ឌកម្មលើ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍» ។ ទំនួលខុសត្រូវនៃយុត្តាធិការ ដែលត្រូវបានកំណត់ដោយតួនាទីនៃការចរចារបស់របបរដ្ឋកម្ពុជា ដែលអាស្រ័យទៅនឹងការសម្របសម្រួលនយោបាយដែលជាវិធី ដ៏មានប្រសិទ្ធភាពដើម្បីការពារភាពផ្ទួនៗនៃ «នយោបាយប្រល័យ ពូជសាសន៍និងការអនុវត្តរបស់របប ប៉ុល ពត» និងនៅឆ្នាំ១៩៩០ របបរដ្ឋកម្ពុជាបានអំពាវនាវឲ្យអង្គការសហប្រជាជាតិ «បង្កើត តុលាការអន្តរជាតិនៅក្រោមខ្សែបន្ទាត់នៃតុលាការទូរ៉េមប៊ឺកដើម្បី កាត់ទោសឧក្រិដ្ឋកម្មនានារបស់ ប៉ុល ពត» ។

តម្រូវការទាំងអស់របស់របបរដ្ឋកម្ពុជាត្រូវបានជំទាស់ មិនត្រឹមតែជំទាស់ពីខ្មែរក្រហម និងភាគីកម្ពុជាដែលជាសម្ព័ន្ធមិត្ត របស់ខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវបានជំទាស់ភាគច្រើន ដោយរដ្ឋាភិបាលបរទេសដែលបានចូលរួមធ្វើការសម្របសម្រួល ជម្លោះនយោបាយនៅប្រទេសកម្ពុជាដែរ ។ នៅពេលដែល រដ្ឋាភិបាលកម្ពុជានិងប្រតិភូបរទេសជួបគ្នាដើម្បីធ្វើការចរចានៅ ក្នុងទីក្រុងប៉ារីសក្នុងឆ្នាំ១៩៨៩ ប្រទេសចិនជំទាស់យ៉ាងខ្លាំង ទៅលើការរារាំងត្រឡប់ទៅរកឧក្រិដ្ឋកម្មបក្សកុម្មុយនីស្តកម្ពុជា និងមានសមាជិកជាច្រើនទៀតនៃសមាគមប្រជាជាតិអាស៊ី អាគ្នេយ៍ (អាស៊ាន) ក៏ជំទាស់ដែរ ។ រដ្ឋាភិបាលបស្ចិមប្រទេសមួយ ចំនួនរួមមាន សហរដ្ឋអាមេរិកផង បានប្រកាសពីជំហរគាំទ្រដល់ សេចក្តីប្រាថ្នារបស់អាស៊ានដែរ ។ ប្រទេសមួយចំនួនដែលមាន ទំនោរទៅរកគោលជំហរនេះបានលើកឡើងពីស្ថានភាពលំបាក ផ្នែកបច្ចេកទេសលើការអនុវត្តទៅលើអនុសញ្ញាប្រល័យពូជសាសន៍ ទៅនឹងស្ថានភាពប្រទេសកម្ពុជា ។ នេះឆ្លុះបញ្ចាំងឲ្យឃើញកាន់តែ ច្បាស់ថា ស្ថានភាពនយោបាយមិនត្រឹមតែធ្វើឲ្យខកខានសវនាការ នោះទេ តែវាស្តែងចេញឲ្យឃើញពីលទ្ធផលនៅក្នុងការរាប់បញ្ចូល ខៀវ សំផន និង សុន សេន ដែលជាមេដឹកនាំរបបកម្ពុជាប្រជា ធិបតេយ្យដែរ ។ ឧត្តមក្រុមប្រឹក្សាជាតិកំណត់និមិត្តសញ្ញាណ នៃបូរណភាពទឹកដីកម្ពុជាខណៈដែលអង្គការសហប្រជាជាតិមើល ឃើញពីការបញ្ចេញកំណែនកងទ័ពខ្មែរក្រហម និងកងកម្លាំង យោធាដទៃផ្សេងទៀត និងការរៀបចំបោះឆ្នោតដែលមានវត្តមាន ខ្មែរក្រហមចូលរួម ។ បេក្ខជនទាំងពីរ ខៀវ សំផន និង សុន សេន ត្រូវបានកំណត់ឈ្មោះក្នុងសមាជិកឧត្តមក្រុមប្រឹក្សាជាតិនៅក្នុង ខែកញ្ញា ឆ្នាំ១៩៩០ ដែលអង្គុយនៅក្បែរនាយករដ្ឋមន្ត្រី ហ៊ុន សែន និងអ្នកនយោបាយដទៃទៀតដែល «តំណាងបុគ្គលម្នាក់ៗ ដែលមានឥទ្ធិពលនៅក្នុងចំណោមប្រជាជនកម្ពុជា» ។ ការចរចា កំពុងតែមានភាពតឹងតែងពីការសម្របសម្រួលនយោបាយបន្តឲ្យ មានកាន់តែច្បាស់ ។ រដ្ឋាភិបាលនៃរបបរដ្ឋកម្ពុជាមិនបោះបង់ ចោលការទទូចថា «គ្រប់ជនដែលសង្គមមិនត្រូវការទាំងប្រាំបីរូប» ដែលរួមមាន ខៀវ សំផន និង សុន សេន «ត្រូវតែធ្វើការបំបាត់

បោល» ប៉ុន្តែពេលនេះក្តីស្រមើស្រមៃពីអនាគតដែលកើតបន្ទាប់ពីការបោះឆ្នោតអង្គការសហប្រជាជាតិបានសន្មតថាមានសេរីភាព និងតម្លាភាពក្នុងការបោះឆ្នោត ហើយប្រជាជនដេញខ្មែរក្រហមចេញពីអំណាច ។ នៅក្នុងបរិបទនេះ រដ្ឋកម្ពុជានៅតែបន្តដើម្បីឲ្យមានការកាត់ទោសក្រុមមេដឹកនាំនៃរបប ប៉ុល ពត ថាជា «វិធានការចាំបាច់ដែលមានបំណងទប់ស្កាត់ការវិលមកវិញនៃរបបប្រល័យពូជសាសន៍» ។

ក្នុងអំឡុងពេលចរចាបន្ទាប់មកទៀតក្នុងឆ្នាំ១៩៩១ ដែលជាសេចក្តីសម្រេចចុងក្រោយនាំឲ្យមានការចុះហត្ថលេខានៅសន្និសីទលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសក្នុងខែតុលា ដែល ហ៊ុន សែន និងមន្ត្រីរបស់របបរដ្ឋកម្ពុជាដទៃទៀតត្រូវចូលរួមនៅក្នុងកិច្ចប្រជុំជាមួយនឹង ខៀវ សំផន និង សុន សេន (តំណាងរបបប្រល័យពូជសាសន៍ខ្មែរក្រហម) ដែលរបបរដ្ឋកម្ពុជាលើកលែងទោសចោទប្រកាន់ជាបណាសមាជិកភាពរបស់អ្នកទាំងពីរនៅក្នុងឧត្តមក្រុមប្រឹក្សាជាតិអាចរួមចំណែកនៅក្នុងការដោះស្រាយបញ្ហាសង្គ្រាមដែលអូសបន្លាយជាយូរមកហើយ ។ ប៉ុន្តែ របបរដ្ឋកម្ពុជានៅតែបន្តការព្យាយាមកាត់ទោស «មេដឹកនាំខ្មែរក្រហមនានា...នៅពេលវេលាសមស្របណាមួយ» ដោយរដ្ឋាភិបាលក្រោយបោះឆ្នោតនៅពេលដែលខ្មែរក្រហមទទួលបរាជ័យហើយ តុលាការនោះគឺជាតុលាការអន្តរជាតិ ។ មានការបន្ថែលទៀតថា ក្រៅពីកាត់ទោស«មេដឹកនាំជាន់ខ្ពស់បំផុត» ក៏នឹងមានការកាត់ទោសមេដឹកនាំ «មេដឹកនាំដទៃទៀតត្រូវបានពិចារណា» ដែរទៅលើគោលការណ៍មួងមួយករណីៗដែលនិយាយថា «ប្រជាជនកម្ពុជាចង់ឃើញមេដឹកនាំខ្មែរក្រហមត្រូវបាននាំខ្លួនទៅវិនិច្ឆ័យទោស» ។ ក្នុងស្ថានភាពនេះ រដ្ឋកម្ពុជាបានទទូចឲ្យបែងចែកឲ្យដាច់រវាង «ថ្នាក់ដឹកនាំនៅក្នុងរដ្ឋាភិបាលរដ្ឋកម្ពុជាដែលជាអ្នកដែលមិនបានប្រព្រឹត្តបទឧក្រិដ្ឋ» នានា ប៉ុន្តែជាជនរងគ្រោះនិង «ក្រុមប៉ុល ពត, អៀង សារី, ខៀវ សំផន និងសមាជិកជិតដិតដទៃផ្សេងទៀតដែលនៅក្រោមបង្គាប់...ដែលបានប្រព្រឹត្តបទល្មើសអំពើប្រល័យពូជសាសន៍» ។ ចំណុចនេះត្រូវផាកទៅរកប្រវត្តិសាស្ត្រដើមវិញដែលថា អ្នកបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាក្នុងខែធ្នូ ឆ្នាំ១៩៧៨ ដែលរួមមានអតីតកម្មាភិបាលខ្មែរក្រហមដូចជានាយករដ្ឋមន្ត្រី ហ៊ុន សែន, ជា ស៊ីម និង ហេង សំរិន ដែលត្រូវបានជឿថា «ជាអ្នកផ្តួលរលំរបបប្រល័យពូជសាសន៍» ។

នៅក្នុងការចរចាចុងក្រោយ រដ្ឋកម្ពុជាមិនបានសម្អាងឲ្យច្បាស់ទៅនឹងតុលាការ ឬបញ្ហាប្រល័យពូជសាសន៍ដែលបានសរសេរជាលាយលក្ខណ៍អក្សរនៃកិច្ចព្រមព្រៀងទេ ។ ទោះជាយ៉ាងណាក្តី អវត្តមាននៃកិច្ចព្រមព្រៀងនេះត្រូវបានសងមកវិញដោយបានដាក់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសចំពោះការដែលបាននិយាយពីអំពើឃោរឃៅរបស់របបខ្មែរក្រហម និងការទាមទាររបបរដ្ឋកម្ពុជាដើម្បីឲ្យមានការទទួលខុសត្រូវតាមផ្លូវច្បាប់ ។ ចំណុចនេះត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀង «ដែលតម្រូវថា គោលនយោបាយនិងការប្រព្រឹត្តកាលពីអតីតកាលនឹងមិនអាចត្រឡប់មកវិញឡើយ» និងតម្រូវថា ប្រទេសដែលជាហត្ថលេខីទាំងអស់ «ត្រូវធានាអះអាងថានឹងមិនឲ្យមានការវិលត្រឡប់មកវិញទេចំពោះគោលនយោបាយ និងការអនុវត្តនៃរបបនេះ ។ សេចក្តីថ្លែងនេះឆ្លុះបញ្ចាំងឲ្យឃើញពីការបង្រួបបង្រួមគ្នារវាងសេចក្តីស្នើដោយរដ្ឋកម្ពុជានិងគណៈប្រតិភូសហរដ្ឋអាមេរិកថា កិច្ចព្រមព្រៀងចុងក្រោយគឺធ្វើឡើងក្នុងក្របខណ្ឌអនុសញ្ញាអំពើប្រល័យពូជសាសន៍និងការប្រឆាំងក្នុងការវិលត្រឡប់វិញនូវរបបនេះដោយបក្សកម្មុយនីស្តកម្ពុជា និងក្នុងចំណោមសមាជិកដទៃទៀត ។ ភាសាត្រូវបានរៀបចំទុកដើម្បីសំដៅទៅលើអំពើប្រល័យពូជសាសន៍នៃកម្ពុជាប្រជាធិបតេយ្យ និងការពិតដែលថា ប្រទេសកម្ពុជាគឺជារដ្ឋនៃអនុសញ្ញាប្រល័យពូជសាសន៍ និងបង្ហាញពីការផ្លាស់ប្តូរនៃផ្នត់នយោបាយរបស់សហរដ្ឋអាមេរិក ។ នៅក្នុងសេចក្តីថ្លែងការណ៍ទៅកាន់សន្និសីទនោះ រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក លោក ចេមស៍ ប៊េកឃើ បានបកស្រាយពីរបត់សំខាន់ៗរបស់សហរដ្ឋអាមេរិក និងបង្ហាញឲ្យច្បាស់ថា ៖

> តើករណីណាដែលធ្វើឲ្យប្រទេសកម្ពុជាជារឿងពិសេសនោះ និងការទាមទាររបស់កម្ពុជាដើម្បីឲ្យមានការគាំទ្រពីអន្តរជាតិដែលមានលក្ខណៈបង្ខិតបង្ខំគឺជាទំហំនៃការឈឺចាប់ដែលប្រជាជនធ្វើការអត់ទ្រាំ ។ ខ្មែរក្រហមមិនមែនជាជនគាបសង្កត់

ធម្មតានោះទេ ។ ដើម្បីបដិវត្តន៍របស់ខ្លួន ខ្មែរក្រហម បានប្រើប្រាស់អំពើហិង្សាប្រឆាំងនឹងប្រជាជនខ្លួនឯងនៅក្នុងវិធីដែលមានតិចតួចនៅក្នុងប្រវត្តិសាស្ត្រ ។ យើងផ្ដន្ទាទោសគោលនយោបាយទាំងនោះ និងការអនុវត្តរបស់ខ្មែរក្រហមដែលជាអំពើគួរឲ្យស្អប់ខ្ពើមទៅនឹងមនុស្សជាតិហើយនឹងមិនអនុញ្ញាតឲ្យកើតមានជាថ្មីម្ដងទៀតទេ ។ ដើម្បីទប់ស្កាត់របបនោះមិនឲ្យកើតមានម្ដងទៀត យើងលើកទឹកចិត្តឲ្យមានកិច្ចសហប្រតិបត្តិការនៃការការពារសិទ្ធិមនុស្សដែលធានានៅក្នុងការសម្របសម្រួលកិច្ចព្រមព្រៀងនេះ ហើយខ្ញុំធានាអះអាងថា... ប្រជាពលរដ្ឋកម្ពុជា... យើងនឹងជួយគាំទ្រការខិតខំប្រឹងប្រែងរបស់យើងដើម្បីអះអាងថា សិទ្ធិរបស់ប្រជាជនកម្ពុជាត្រូវបានគាំទ្រដោយសហគមន៍អន្តរជាតិ ។ ប្រទេសកម្ពុជានឹងសហរដ្ឋអាមេរិកចុះហត្ថលេខាទៅលើអនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ ហើយយើងនឹងជួយគាំទ្រកិច្ចខិតខំប្រឹងប្រែងនាំខ្លួនដើម្បីទទួលបានការវិនិច្ឆ័យអ្នកដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍ក្នុងទសវត្សរ៍៧០ឲ្យប្រឈមមុខនឹងតុលាការ ប្រសិនជារដ្ឋាភិបាលកម្ពុជាជ្រើសរើសវិធីដោះស្រាយតាមមាគ៌ានេះ ។

គោលជំហររបស់អាមេរិកដូចជាមិនច្បាស់លាស់ទាក់ទងទៅលើការកាត់ទោសនិងនិយាយពីគោលការណ៍បញ្ជូនទៅ "តុលាការចំពោះជនដែលទទួលខុសត្រូវក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍" ។ គោលជំហរសហរដ្ឋអាមេរិកចាប់ផ្ដើមច្បាស់លាស់បន្តិចនៅពេលដែលព្រឹទ្ធសភាបានអនុម័ត "ច្បាប់ស្ដីអំពីយុត្តិធម៌ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍កម្ពុជា" ។ ច្បាប់នេះចែងថាជាគោលការណ៍របស់សហរដ្ឋអាមេរិក "ដើម្បីនាំទៅរកយុត្តិធម៌ចំពោះមេដឹកនាំនយោបាយ និងយោធាខ្មែរក្រហម" និង "ដើម្បីលើកទឹកចិត្តបង្កើតតុលាការជាតិនិងតុលាការយុត្តិធម៌អន្តរជាតិមួយដើម្បីកាត់ទោសអ្នកដែលត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ។

នាយករដ្ឋមន្ត្រី ហ៊ុន សែន បានអះអាងថា កិច្ចព្រមព្រៀងនៅប៉ារីសពុំមានឥទ្ធិពលទៅលើ "មោឃភាព" សាលក្រមកាលពីខែសីហា ឆ្នាំ១៩៧៩ ដែលកាត់ទោសប្រឆាំងទៅលើ ប៉ុល ពត និង អៀង សារី ទេ ហើយនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានអះអាងដែរថា គោលជំហរនេះត្រូវបានគាំទ្រដោយសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស ។ ទោះយ៉ាងណាក្ដី នាយករដ្ឋមន្ត្រី ហ៊ុន សែន បានបង្ហាញថា ការកាត់ក្ដីផ្សេងទៀតអាចយកមកថ្កោលទោសបន្ថែមទៀត ប៉ុន្តែបញ្ហាទាំងអស់នោះត្រូវបានសម្រេចចិត្តដោយរាជរដ្ឋាភិបាលថ្មីនេះ" ។ សម្ដេច សីហនុ គាំទ្រទៅលើគោលជំហររបស់សហរដ្ឋអាមេរិកនិងរដ្ឋកម្ពុជា ដោយបានប្រកាសថា ទ្រង់គាំទ្រការបង្កើត "តុលាការអន្តរជាតិមួយដើម្បីកាត់ទោសអ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅដែលបញ្ជាក់ច្បាស់លាស់ដូចជា ប៉ុល ពត, អៀង សារី និង តាម៉ុក ។ ក្នុងអំឡុងមហាបាតុកម្មមួយដែលប្រហែលជារៀបចំឡើងដោយរបបរដ្ឋកម្ពុជាក្នុងខែវិច្ឆិកា ឆ្នាំ១៩៩១ ប្រឆាំងទៅនឹងវត្តមានរបស់ សុន សេន និង ខៀវ សំផន នៅក្នុងទីក្រុងភ្នំពេញ ដែលជាសមាជិកឧត្តមក្រុមប្រឹក្សាជាតិបានបង្ហាញឲ្យឃើញថា រដ្ឋកម្ពុជាចាត់ទុក "អ្នកទាំងពីរជាអតីតមេឃាតករសម្លាប់ប្រជាជន" ដែលអ្នកទាំងពីរនេះដូចគ្នានឹងមេដឹកនាំប្រល័យពូជសាសន៍ដទៃទៀតដែរ ដែលជា "ក្រុមពាលរបស់បនប្រល័យពូជសាសន៍ ប៉ុល ពត" ដែលត្រូវតែកាត់ក្ដីដោយអង្គការសហប្រជាជាតិក្នុងតុលាការអន្តរជាតិ ។ របបរដ្ឋកម្ពុជាបានអះអាងម្ដងទៀតថា ការកាត់ទោស "ក្រុមមេខ្លោង ប៉ុល ពត" គឺជាលទ្ធផលនៃការបោះឆ្នោតដែលឆ្លុះបញ្ចាំងពីឆន្ទៈរបស់ប្រជាជន ។ សម្ដេចសីហនុ ក៏គិតពីសេណារីយ៉ូនេះដែរ ។ ប៉ុន្តែក្រោយពីការវាយប្រហារទៅលើ សុន សេន និង ខៀវ សំផន របបរដ្ឋកម្ពុជាបានអះអាងថា ខ្លួននឹងបន្តអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងគោរពពីការចូលរួមរបស់អ្នកទាំងពីរក្នុងការសម្របសម្រួលនយោបាយនៅប្រទេសកម្ពុជា ។ របបរដ្ឋកម្ពុជាប្រកាន់គោលជំហរនេះពេញមួយឆ្នាំ១៩៩២ ។

ក្នុងខែមករា ឆ្នាំ១៩៩៣ យោងទៅលើការរំលោភរបស់គណបក្សកម្ពុជាប្រជាធិបតេយ្យចំពោះកិច្ចព្រមព្រៀងទីក្រុងប៉ារីស

ដែលរួមមានទាំងការវាយប្រហារផ្នែកយោធានិងការធ្វើពហិការក្នុងការមិនចូលរួមការរៀបចំការបោះឆ្នោតដែលរៀបចំដោយអង្គការសហប្រជាជាតិប្រព្រឹត្តឡើងក្នុងខែឧសភាខាងមុខ រដ្ឋាភិបាលរបស់របបរដ្ឋកម្ពុជាបានប្រកាសថា គណបក្សកម្ពុជាប្រជាធិបតេយ្យបានបាត់បង់សិទ្ធិក្នុងការធ្វើជាសមាជិកភាពរបស់ឧត្តមក្រុមប្រឹក្សាជាតិ និងទាមទារថា «ខ្មែរក្រហមត្រូវបានបណ្តេញចេញពីនីតិវិធីសន្តិភាព...និងប្រកាសឲ្យមានការរុករានខ្មែរក្រហម និងដាក់ឲ្យនៅក្រៅច្បាប់» ។

ប្រសិនបើមិនអាចធ្វើមុនបោះឆ្នោតទេ នឹងធ្វើក្រោយការបោះឆ្នោត ។ នៅក្នុងខែមីនា របបរដ្ឋកម្ពុជាស្នើសុំឲ្យមានការរៀបចំតុលាការអន្តរជាតិជាមួយនឹងការចរចាដោយអង្គការសហប្រជាជាតិសម្រាប់យូហ្គោស្លាវី ដើម្បីកាត់ទោសខ្មែរក្រហមដែលបាន «សម្លាប់ជាប្រព័ន្ធ» ទៅលើប្រជាជនវៀតណាម «ដោយសារតែការប្រកាន់ពូជសាសន៍» ដែលបង្ហាញពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែពុំបានបញ្ជាក់ពីឧក្រិដ្ឋកម្មដែលបានធ្វើនៅក្នុងឆ្នាំ១៩៧៥ ដល់១៩៧៩ទេ ។ កិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សាជាតិ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៣ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានអះអាងច្បាស់ថា អំពើសម្លាប់ថ្មីៗដែលបង្កឡើងដោយគណបក្សកម្ពុជាប្រជាធិបតេយ្យទៅលើប្រជាជនកម្ពុជា ជនជាតិវៀតណាម និងបុគ្គលិករបស់អង្គការសហប្រជាជាតិគឺជាបទប្រល័យពូជសាសន៍ចំពោះប្រជាជនកម្ពុជា និងជនជាតិវៀតណាម ហើយអំពើទាំងអស់នោះគឺមានបំណងចង់បញ្ឈប់ ឬបំផ្លាញគម្រោងការបោះឆ្នោត ។ ក្នុងព្រឹត្តិការណ៍នេះ នាយករដ្ឋមន្ត្រី ហ៊ុន សែន ទាមទារឲ្យអង្គការសហប្រជាជាតិចាប់ ប៉ុល ពត, អៀង សារី, តាម៉ុក, ខៀវ សំផន និងមេដឹកនាំផ្សេងៗទៀតនាំខ្លួនទៅវិនិច្ឆ័យទោសដោយតុលាការរបស់របបរដ្ឋកម្ពុជាដែលស្ថិតនៅក្រោមការត្រួតពិនិត្យពីអង្គការសហប្រជាជាតិសម្រាប់កាត់ក្តីអំពើប្រល័យពូជសាសន៍ ឬក៏តុលាការរបស់រដ្ឋកម្ពុជាចេញដីកាចាប់ខ្លួនដើម្បីចាប់ផ្តើមដំណើរការកាត់ក្តី ។ ក្នុងរយៈពេលបីថ្ងៃក្រោយមក នាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្នើសុំអគ្គលេខាធិការអង្គការសហប្រជាជាតិ ប៊ូត្រូស ហ្គាលី នូវជម្រើសមួយទៀតថា «មេដឹកនាំខ្មែរក្រហមត្រូវនាំមកកាត់ទោសក្នុងតុលាការអន្តរជាតិ» ពីបទល្មើសដែលបានប្រព្រឹត្តនិងពីបទរយៈកាលដែលមេដឹកនាំទាំងនោះកាន់កាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ព្រមទាំងអំពើឃាតកម្មដែលកើតឡើងក្នុងពេលថ្មីនេះ ។ នៅក្នុងយុទ្ធនាការបោះឆ្នោតរបស់គណបក្សប្រជាជនកម្ពុជា នាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងនៅលើវេទិកាថា «មេខ្លោងនៃអំពើប្រល័យពូជសាសន៍» ដូចជា ប៉ុល ពត, អៀង សារី, តាម៉ុក, និង ខៀវ សំផន គួរតែត្រូវបានកាត់ទោសដោយអនុលោមទៅតាមការផ្តល់ជាអនុសញ្ញានៃអំពើប្រល័យពូជសាសន៍ និងក៏បង្កើតឡើងក្រោយការបោះឆ្នោត ។

## រាជរដ្ឋាភិបាលកម្ពុជា

លទ្ធផលនៃការការបោះឆ្នោតឧសភា ឆ្នាំ១៩៩៣ គណបក្សហ៊្វុនស៊ិនប៉ិចក្រោមការដឹកនាំរបស់ព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ បានឈ្នះឆ្នោត ។ តែលទ្ធផលគឺការបង្កើតរដ្ឋាភិបាលចម្រុះរវាងគណបក្សហ៊្វុនស៊ិនប៉ិចនិងគណបក្សប្រជាជនកម្ពុជា ដោយមានព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ជានាយករដ្ឋមន្ត្រីទីមួយ និង ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទីពីរ ។ សម្តេចសីហនុបានក្លាយជាស្តេចគ្រងរាជ្យ ប៉ុន្តែទ្រង់មិនកាន់អំណាចដឹកនាំរាជរដ្ឋាភិបាលកម្ពុជាទេ ។ បន្ទាប់ពីការបង្កើតរាជរដ្ឋាភិបាលចម្រុះនិងស្ថានការណ៍ប្រយុទ្ធគ្នាបង្កឡើងដោយខ្មែរក្រហមកំពុងតែបន្ត មន្ត្រីមួយចំនួននៃរាជរដ្ឋាភិបាលកម្ពុជាបានអះអាងថា «មេដឹកនាំខ្មែរក្រហមជាពិសេស ប៉ុល ពត និង អៀង សារី គួរតែយកទៅវិនិច្ឆ័យទោសទោះបីជាវេទិកាចម្រុះផ្លូវការមិនបានបញ្ជាក់ពីភាពអាចទៅរួចនៃការវិនិច្ឆ័យនោះ ដោយគ្រាន់តែប្រកាសថា «សមាជិកណាក៏ដោយនៃក្រុមខ្មែរក្រហម» នឹងត្រូវស្វាគមន៍ឲ្យ «ត្រឡប់ចូលសហគមន៍ជាតិវិញ» រួមមានទាំង «តំណាងនៃក្រុមខ្មែរក្រហម» ដែលអាចត្រូវបានតែងតាំងតួនាទីជា «ទីប្រឹក្សារដ្ឋាភិបាល» ផង ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលដែលមានឋានៈខ្ពស់បំផុតដែលបានធ្វើការចុះចូលក្លាមគឺ ម៉ែន កែវ ជាសមាជិកនៃមេដឹកនាំយោធាខ្មែរក្រហម នៅភាគឧត្តរនៃប្រទេសកម្ពុជា ។ ហើយនៅត្រឹមខែមិថុនា ១៩៩៤ ខណៈពេលដែលទ័ពព្រៃខ្មែរក្រហមកំពុងតែវាយប្រហារតំបន់មួយចំនួនរបស់កម្ពុជា នាយករដ្ឋមន្ត្រី ហ៊ុន សែន បានបន្តការទាមទារជាសាធារណៈឲ្យមានការកាត់ទោសអ្នកដែលទទួលខុសត្រូវសម្រាប់ «ឧក្រិដ្ឋកម្មសង្គ្រាមរបស់ខ្មែរក្រហម»

នៅខែកក្កដា ឆ្នាំ១៩៩៤ រដ្ឋាភិបាលចម្រុះបានស្នើទៅអង្គនីតិបញ្ញត្តិនូវ "ច្បាប់ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់" ដែលត្រូវផ្តន្ទាទោសតាមច្បាប់ដែលមានជាធរមាន បន្ថែមលើបទបញ្ញត្តិថ្មីដើម្បីផ្តន្ទាទោសលើបទឧក្រិដ្ឋនិងផ្តល់នូវចរិតលក្ខណៈផ្នែកនយោបាយ និងច្បាប់ទូទៅនៃឋានានុក្រម និងរចនាសម្ព័ន្ធនៃបក្សកុម្មុយនីស្តកម្ពុជា ។ ដោយសំដៅតែទៅលើពីរថ្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យ "មេដឹកនាំ" និង "សមាជិក" ច្បាប់កំណត់និយមន័យ "ក្រុមកម្ពុជាប្រជាធិបតេយ្យ" ថាមានអត្តិភាពដូចគ្នាទៅនឹងការដែលកាន់អំណាចនៅខែមេសា ១៩៧៥ និងបានប្រព្រឹត្តបទល្មើសរវាងឆ្នាំ១៩៧៥ដល់១៩៧៩ ដែលនិយាយថា នេះជាការរួមបញ្ចូលនូវ "អង្គការនយោបាយ" និង "កងកម្លាំងយោធា" ។ ច្បាប់នេះបានប្រកាសថា "មេដឹកនាំ" នៃក្រុមនោះត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្តបទឧក្រិដ្ឋអំឡុងឆ្នាំ១៩៧៥-១៩៧៩ ប៉ុន្តែថ្លែងថា "សមាជិក" នយោបាយ និងយោធានៃក្រុមនេះអាចត្រូវទទួលខុសត្រូវផងដែរចំពោះបទឧក្រិដ្ឋតាមទំហំនៃអំពើដែលគេប្រព្រឹត្តក្នុង "ការសមគំនិតឬចូលរួមដោយផ្ទាល់" នៅក្នុងបទឧក្រិដ្ឋនោះ ។ មាត្រា៣នៃច្បាប់អាចធ្វើការចោទប្តឹង "សមាជិកនៃអង្គការនយោបាយឬកម្លាំងយោធា" នៃ "ក្រុមកម្ពុជាប្រជាធិបតេយ្យ" ចំពោះ "សកម្មភាពនៃការផ្តាច់ខ្លួន អំពើនៃការបំផ្លិចបំផ្លាញប្រឆាំងនឹងរាជរដ្ឋាភិបាល អំពើនៃការបំផ្លិចបំផ្លាញប្រឆាំងនឹងអង្គការនៃអាជ្ញាធររដ្ឋ និងញុះញង់ឲ្យប្រជាជនលើកអាវុធប្រឆាំងនឹងអាជ្ញាធររដ្ឋ" ។ មាត្រាផ្សេងបានផ្តល់រយៈពេលប្រាំមួយខែដែលជាអំឡុងពេលដែលសមាជិកនៃ "ក្រុមកម្ពុជាប្រជាធិបតេយ្យ" អាច "ត្រឡប់មករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល...ដោយមិនយកទោសពៃរ៍ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត" ។ ច្បាប់នេះបានបន្ថែមទៀតថា "មេដឹកនាំក្រុមកម្ពុជាប្រជាធិបតេយ្យ" មិនអាចទទួលប្រយោជន៍ពីការលើកលែងទោសនេះបានទេ ទោះបីជាអាចមានការលើកលែងទោសតាមព្រះរាជសិទ្ធិបន្ទាប់ពីការចាប់ខ្លួន និងការផ្តន្ទាទោសនៃបទល្មើសដែលបានប្រព្រឹត្តមិនត្រូវបានមិនរាប់បញ្ចូលក៏ដោយ ។

នៅខែមករា ឆ្នាំ១៩៩៥ រយៈពេលកំណត់ប្រាំខែត្រូវបានពន្យារនៅក្នុងរយៈពេលមួយមិនជាក់លាក់សម្រាប់ទ័ពព្រៃខ្មែរក្រហមសាមញ្ញ និងប្រជាជនរស់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ដែលត្រូវបានសន្យាថា ទ័ព និងប្រជាជននោះនឹងត្រូវស្វាគមន៍ "ជានិច្ច" និងមិនត្រូវបានចោទឡើយ បើសិនជាទ័ព និងប្រជាជនទាំងនោះប្តូរមកខាងរាជរដ្ឋាភិបាលកម្ពុជាវិញ ។ នៅពេលនោះ រដ្ឋាភិបាលបានអះអាងថា ស្ទើរតែ៦.០០០នាក់បានរត់ចោលបក្សតាំងពីឆ្នាំ១៩៩៤ ហើយបានពន្យល់ថា នៅក្នុងចំណោមអ្នកដែលបានរត់ចោលបក្សតាំងពីខែកញ្ញា ឆ្នាំ១៩៩៣ នោះ ២.៩៧០នាក់បានចូលរួម នៅក្នុងកងទ័ពរាជរដ្ឋាភិបាលរួមមានឧត្តមសេនីយ៍ត្រីបីរូប វរសេនីយ៍ឯកប្រាំបួនរូប វរសេនីយ៍ទោសាមសិបរូប វរសេនីយ៍ត្រី៣៩រូប និងអនុសេនីយ៍ឯក១២០រូប ។ នៅពាក់កណ្តាលឆ្នាំ១៩៩៥ រដ្ឋាភិបាលបានបញ្ជាក់ថា ៥.០០០នាក់បានរត់ចោលបក្សតាំងពីមានការប្រកាសនៃច្បាប់ដាក់ក្រុមខ្មែរក្រហមឲ្យនៅក្រៅច្បាប់ ។

អំឡុងពេលអនុវត្តគោលនយោបាយនេះ រដ្ឋាភិបាលបានផ្លាស់ប្តូរការអនុវត្តឆ្នាំ១៩៧៩ នៃការបែងចែកបីថ្នាក់របស់ថ្នាក់ដឹកនាំខ្មែរក្រហម ។ នៅថ្នាក់កំពូលគឺ "មេដឹកនាំកំពូលដូចជា ប៉ុល ពត, អៀង សារី, ខៀវ សំផន, តាម៉ុក ជាដើម" ដែលរួមបញ្ចូលទាំងអ្វីដែលហៅថា "វគ្គផ្ទៃក្នុងរបស់ខ្មែរក្រហម" ដឹកនាំដោយ ប៉ុល ពត និងរួមមានទាំងអ្នកដទៃផ្សេងទៀតដែលត្រូវបានចាត់ទុកជា "មេកំពូល" ឬខ្មែរក្រហមដែល "មានឋានៈខ្ពស់" ។ បន្ទាប់មកគឺ "មេបញ្ជាការ" យោធា និង "មន្ត្រី" យោធា និងអ្នកដទៃទៀតដែលត្រូវបានចាត់ទុកថាជា "មេដឹកនាំ" ។ ជាចុងក្រោយគឺក្រុមទាហានធម្មតា ។ គោលនយោបាយនេះមានន័យថា អ្នកទាំងឡាយដែលនៅក្នុងប្រភេទពីរចុងក្រោយត្រូវបានស្វាគមន៍ក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ សម្រាប់អ្នកដឹកនាំកំពូលគោលនយោបាយដូចដើមនៃការយកអ្នកទាំងនោះទៅវិនិច្ឆ័យទោសត្រូវបានអះអាងបញ្ជាក់ជាថ្មីនៅពេញឆ្នាំ១៩៩៥ និងនៅឆ្នាំ១៩៩៦ ដែលចំណុចនេះត្រូវបានបញ្ជាក់លម្អិតថា ជនទាំងនោះគួរតែកាត់ទោសនៅក្នុងតុលាការអន្តរជាតិនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ រួមមានទាំងអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តឡើងរវាងឆ្នាំ១៩៧៥ និង១៩៧៩ ។ ឈ្មោះរបស់ ប៉ុល ពត, នួន ជា, អៀង

សារី, ម៉ុក និង ខៀវ សំផន ត្រូវបានបញ្ជាក់ ហើយបញ្ហានេះត្រូវបានបញ្ជាក់ថា ប៉ុល ពត និង អៀង សារី អាចត្រូវបានកាត់ទោសម្តងទៀត ។ គម្រោងការត្រូវបានធ្វើឡើងដើម្បីចាប់ខ្លួនអ្នកទាំងនេះ ។

## ការអភ័យទោស ឬការលើកលែងទោសរបស់ អៀង សារី

នៅពេលនោះ ការបែងចែកថ្នាក់របស់ខ្មែរក្រហម និងកម្មាភិបាលយោធាដែលមានឋានៈខ្ពស់ដែលបានរត់ចោលបក្សត្រូវទទួលស្វាគមន៍ និងដាក់បញ្ចូលទៅក្នុងកងកម្លាំងប្រដាប់អាវុធនៃរាជរដ្ឋាភិបាលកម្ពុជា ដូចជាមេបញ្ជាការនយោបាយនៃកងពលធំលេខ៩៨០ឈ្មោះ ហេង សារ៉ាត់ ។ រដ្ឋាភិបាលក៏បានបើកទូលាយសម្រាប់ការចរចា ដែលជាលទ្ធផលគឺការរត់ចោលបក្សរបស់ កែវ ពង្ស ហៅ ហេង ពង្ស ដែលជាសមាជិកនៃ "គណៈមជ្ឈិម" របស់ខ្មែរក្រហមត្រូវបានតែងតាំងជាមេបញ្ជាការរងនៃភូមិភាគ៣របស់រាជរដ្ឋាភិបាលកម្ពុជា ។ ចាប់ពីខែមេសាឆ្នាំ១៩៩៦ មានការចាប់ផ្តើមកិច្ចពិភាក្សាជាមួយនឹងមេបញ្ជាការនៃកងពលធំខ្មែរក្រហមពីររូបនៅភាគបស្ចិមនៃប្រទេសកម្ពុជា មានកងពលធំលេខ៤១៥ ដែលមានមេបញ្ជាការ អ៊ី ឈាន មានមូលដ្ឋាននៅប៉ៃលិន និងកងពលធំលេខ៤៥០ ក្រោមបញ្ជារបស់ សុខ ភាព មានមូលដ្ឋាននៅតំបន់ម៉ាឡៃ ។ អ៊ី ឈាន និង សុខ ភាព គឺជាអតីតកូនចៅរបស់ អៀង សារី ។ អ៊ី ឈាន ធ្លាប់ជាអ្នកនាំសាររបស់ អៀង សារី នៅក្រសួងការបរទេសអំឡុងពេលដែលខ្មែរក្រហមនៅកាន់អំណាច ប៉ុន្តែបន្ទាប់ពីរបបនោះបានរលំនៅឆ្នាំ១៩៧៩ អ៊ី ឈាន បានភៀសខ្លួនទៅតំបន់ប៉ៃលិនជាកន្លែងដែលគាត់បានបង្កើតកងពលធំលេខ៤១៥ ។ ជំនួសទៅវិញ អៀង សារី បានបង្កើតកងពលខ្លួនឯងនៅឆ្នាំ១៩៧៩ នៅតំបន់ម៉ាឡៃ ជា កន្លែងដែលគាត់កំពុងរក្សាតំណែងជាឧបនាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យទទួលបន្ទុករដ្ឋមន្ត្រីការបរទេស ។ អៀង សារី ត្រូវបានតែងតាំងឲ្យទទួលខុសត្រូវ "តំបន់១០២" ដែលទើបបង្កើតថ្មីដែលមានទីបញ្ជាការនៅម៉ាឡៃ និងដែលបានអនុវត្តអំណាចទៅលើកងពលធំលេខ៤៥០របស់សុខភាព ។ផ្ទុយទៅវិញ នៅឆ្នាំ១៩៨២ អតីតប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានកាន់កាប់ទៅលើមុខងារការបរទេសរបស់ អៀង សារី ហើយ អៀង សារី បានមានជម្លោះជាមួយមេដឹកនាំយោធាជាន់ខ្ពស់នៃរបបខ្មែរក្រហមគឺ សុន សេន ទាក់ទងទៅនឹងយុទ្ធសាស្ត្រយោធា ។ ទោះបីជា អៀង សារី ត្រូវបានចាត់តាំងឲ្យទទួលបន្ទុកហិរញ្ញវត្ថុ និងសេដ្ឋកិច្ចជំនួសទៅវិញក៏ដោយ មកដល់ត្រឹមឆ្នាំ១៩៨៤ ប៉ុល ពត និង ម៉ុក បានចោទប្រកាន់ថា អៀង សារី ទោរទន់ទៅរក "សត្រូវ" ពីព្រោះគាត់មិនព្រមយកភ្នែកមើលទៅលើសកម្មភាពដោះដូរដែលផ្ទុយទៅនឹងមាគ៌ានយោបាយរបស់ខ្មែរក្រហម ។ អៀង សារី ក្រោយមកមានទស្សនៈខុសគ្នាជាមួយនឹង ប៉ុល ពត ទៅលើបញ្ហាថាតើនរណាគួរតែជំនួស ប៉ុល ពត បើសិនជា ប៉ុល ពត ស្លាប់ ហើយពេលនោះ អៀង សារី នឹងធ្វើការតម្រែតម្រង់បន្ថែមទៀត រួមមានការដកខ្លួនចេញពីការពិភាក្សាក្នុងថ្នាក់ដឹកនាំទាក់ទងនឹងការចរចាដើម្បីដោះស្រាយបញ្ហានយោបាយ ។ មកត្រឹមឆ្នាំ១៩៩១ ឬក៏អាចមុននោះទៅទៀត អៀង សារី បានបាត់បង់អំណាចជាមេដឹកនាំជាន់ខ្ពស់ ហើយនៅឆ្នាំ១៩៩២ បានបញ្ឈប់ការអនុវត្តអំណាចយោធា ទោះបីជាគាត់នៅទទួលបន្ទុកមូលដ្ឋានម៉ាឡៃទូទាំងឆ្នាំ១៩៩៣នៅពេលដែលគាត់បានចាកចេញពីតំបន់នោះក៏ដោយ ។ ចាប់ពីឆ្នាំ១៩៩៤មក អៀង សារី បានទៅពិនិត្យសុខភាពនៅទីក្រុងបាងកក និងមិនមានសកម្មភាពនៅក្នុងកិច្ចការខ្មែរក្រហមទៀតទេ ។ ដូច្នេះហើយ អៀង សារី មិនបានចូលរួម និងជាការពិត គឺមិនបានដឹងពីទំនាក់ទំនងរបស់រាជរដ្ឋាភិបាលកម្ពុជាជាមួយ អ៊ី ឈាន និង សុខ ភាព ទេ ។

នៅក្នុងកិច្ចប្រជុំយោធាសម្ងាត់មួយនៅខែមិថុនា ឆ្នាំ១៩៩៦ រដ្ឋាភិបាលបានបញ្ជាក់ពីគោលនយោបាយដើម្បីទទួលយកអ្នករត់ចោលបក្ស ដូច្នេះអ្នកដែលបានបំបែកខ្លួនគួរតែអាចធានាបាននូវសន្តិសុខ មុខងារ ទ្រព្យសម្បត្តិ និងសិទ្ធិនៃការចូលរួមផ្នែកនយោបាយរបស់អ្នកទាំងនោះ ។ អ្នកដែលផ្តាច់ខ្លួនមានទាំងលទ្ធភាពនៃការចូលរួមនៅក្នុងកិច្ចការរដ្ឋបាលយោធារបស់រាជរដ្ឋាភិបាលកម្ពុជាដែរ ។ កិច្ចពិភាក្សាសម្ងាត់ជាមួយ អ៊ី ឈាន និង សុខ ភាព កាន់តែមានសន្ទុះខ្លាំងឡើង ហើយកិច្ចប្រជុំទាំងអស់ត្រូវបានអនុវត្តដោយមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលក្រោមការបញ្ជាផ្ទាល់ពីសហនាយករដ្ឋមន្ត្រី ហ៊ុន សែន និងនរោត្តម រណឫទ្ធិ ។ បទបញ្ជានេះបានលើកទឹកចិត្តឲ្យមានការប្រឆាំងពី

សំណាក់ អ៊ី ឈាន និង សុខ ភាព ទៅនឹងចលនាខ្មែរក្រហម ហើយអ្នកទាំងពីរក៏មានការជំទាស់ទៅនឹងមេបញ្ជាការខ្មែរក្រហមដទៃទៀតដែរដូចជា ប៉ុល ពត, នួន ជា, តាម៉ុក, និង សុន សេន ហើយនៅខែកក្កដា មេដឹកនាំទាំងនោះបានចោទប្រកាន់ អ៊ី ឈាន និង សុខ ភាព ថាក្បត់ដោយគម្រាមថានឹងធ្វើការបន្សុទ្ធ និងអាចចាប់ខ្លួនហើយសម្លាប់ចោល ។

នៅថ្ងៃទី១-២ ខែសីហា អ៊ី ឈាន និង សុខ ភាព បានជួបជាមួយនឹងមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជាដើម្បីបញ្ចប់គម្រោងសម្រាប់ «ការបំបែកខ្លួន» ចេញពីខ្មែរក្រហមជាមួយនឹងអង្គភាពរបស់ខ្លួន ហើយកម្មាភិបាលនិងកងទ័ពផ្សេងទៀតក៏អាចនិងផ្តាច់ខ្លួនដែរ ។ អ៊ី ឈាន និង សុខ ភាព ត្រូវបានប្រគល់ជូននូវកាសែតដែលមានសំឡេងនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលធ្វើការសន្យាជាមួយ និង អ៊ី ឈាន និង សុខ ភាព ថាអ្នកទាំងពីរនឹងនៅតែកាន់តំណែងបច្ចុប្បន្នរបស់ខ្លួនដដែល ប៉ុន្តែជាមន្ត្រីរាជរដ្ឋាភិបាលកម្ពុជាមិនមែនខ្មែរក្រហមទេ ។ នៅថ្ងៃទី៦ ខែសីហា អំឡុងពេលដែល ប៉ុល ពត, នួន ជា, តាម៉ុក, និង សុន សេន បានធ្វើការពិភាក្សានិងបានសម្រេចចាត់វិធានការចាប់ខ្លួនបុរសទាំងពីរ អ៊ី ឈាន និង សុខ ភាព បានផ្តល់ឲ្យ អៀង សារី នូវទិដ្ឋភាពមួយជាលើកដំបូង ហើយកាលនោះ អៀង សារី កំពុងតែទទួលការព្យាបាលនៅទីក្រុងបាងកក ។ អ៊ី ឈាន និង សុខ ភាព បានមកសុំដំបូន្មានពីគាត់ដោយ អ៊ី ឈាន បានមកជួប អៀង សារី ហើយ សុខ ភាព បានសរសេរសំបុត្រ មួយទៅ អៀង សារី ។ អៀង សារី បានផ្តល់ដំបូន្មានដល់អ្នកទាំងពីរឲ្យប្រឆាំងនឹងការចាប់ខ្លួន ។ មកត្រឹមថ្ងៃទី៨ ខែសីហា សុខ ភាព និងមន្ត្រីយោធាជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមនៅក្នុងកិច្ចពិភាក្សាជាមួយ អៀង សារី នៅទីក្រុងបាងកក ជាការពិតដែលត្រូវបានដឹងជាសាធារណៈ ។ ប្រហែលជាដោយសារតែហេតុផលនេះហើយ និងក៏ប្រហែលជាមកពី ប៉ុល ពត ស្មានថា អៀង សារី នៅពីក្រោយភាពរឹងរូសរបស់ អ៊ី ឈាន និង សុខ ភាព វិទ្យុខ្មែរក្រហមបានប្រកាសថា អៀង សារី «បើករបាំងមុខខ្លួនឯងថាជាសត្រូវ» ។

ប៉ុន្មានម៉ោងក្រោយមកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងសុន្ទរកថាដោយគូសបញ្ជាក់ថា គាត់បានទទួលនូវរបាយការណ៍ជាផ្លូវការដែលបញ្ជាក់ថា អ៊ី ឈាន, សុខ ភាព, ទាហាន និងកងពលរបស់អ្នកទាំងពីរ និងកងកម្លាំងខ្មែរក្រហមមួយចំនួនផ្សេងទៀតបាន «បំបែកខ្លួនចេញពីខ្មែរក្រហម» និងចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានធានាថា អ្នកទាំងពីរនេះនឹងត្រូវបានគោរពដោយយោងតាមកិច្ចសន្យាពីមុន ។ នៅពេលដែលគាត់កំពុងថ្លែងសុន្ទរកថា នាយករដ្ឋមន្ត្រី ហ៊ុន សែន បានទទួលទូរស័ព្ទដោយបញ្ជាក់ប្រាប់គាត់ថា «មេដឹកនាំជាន់ខ្ពស់» ខ្មែរក្រហមម្នាក់នឹង «ចូលរួមជាមួយរាជរដ្ឋាភិបាលដែរ» ដែលនេះគឺសំដៅទៅលើ អៀង សារី ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយថាគាត់នឹង «ស្វាគមន៍មេដឹកនាំកំពូល» នេះដែលត្រូវបានបរិហារថាជាជនក្បត់ដោយវិទ្យុខ្មែរក្រហម ហើយនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្តល់ដំបូន្មានឲ្យ អៀង សារី ថាគាត់អាចទៅជ្រកកោននៅក្នុងតំបន់គ្រប់គ្រងដោយកងពលធំលេខ៨១៥ និង ៨៥០ ឬក៏ធ្វើការឆ្លងចូលទៅក្នុងតំបន់ដែលគ្រប់គ្រងដោយរាជរដ្ឋាភិបាលកម្ពុជា និងនាំទ័ពរបស់ខ្លួនមកជាមួយ ។ ជាមួយគ្នានោះដែរ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានចាប់ផ្តើមព្យាយាមបញ្ចុះបញ្ចូល អៀង សារី ឲ្យចាកចេញពីមន្ទីរពេទ្យនៅប្រទេសថៃ ដើម្បីទៅកាន់តំបន់បំបែកខ្លួនដើម្បីចូលជាមួយអ្នកផ្តាច់ខ្លួនពីខ្មែរក្រហម និងផ្តល់ការគាំទ្រផ្នែកសីលធម៌ និងនយោបាយ ។ ហើយ អ៊ី ឈាន និង សុខ ភាព ក៏បានស្នើឲ្យ អៀង សារី មកកាន់ព្រំដែនដើម្បីផ្តល់នូវ «ការណែនាំ» និងភាពជាអ្នកដឹកនាំដល់កងទ័ពរបស់ខ្លួន ។ កងពលធំលេខ៨១៥ និង៨៥០ និងសមាសភាពកងទ័ពខ្មែរក្រហមដទៃទៀតបានប្រកាសជាសាធារណៈថា អ្នកទាំងនោះគាំទ្រ អៀង សារី ដោយបានចាត់ទុក អៀង សារី ថាជា «មេដឹកនាំ» របស់ខ្លួននៅក្នុងសេចក្តីថ្លែងការណ៍កាលពីថ្ងៃទី៨ ខែសីហា ដែលចាក់ផ្សាយដោយវិទ្យុរាជរដ្ឋាភិបាលកម្ពុជានាថ្ងៃបន្ទាប់ ។

ការផ្លាស់ប្តូរភ្លាមៗផ្នែកនយោបាយទាក់ទងនឹង អៀង សារី ត្រូវបានអះអាងដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃទី៩ ខែសីហា នៅក្នុងការប្រកាសជាផ្លូវការមួយក្នុងការស្វាគមន៍ការរត់ចោលបក្សរបស់កងពលធំលេខ៨១៥ និងកងពលធំលេខ ៨៥០ និងប្រកាសដោយសំដៅច្បាស់ដល់ អៀង សារី ថា «បុគ្គលណា» បានចាត់ទុកថា «ក្បត់» ដោយ «មេដឹកនាំ ប៉ុល ពត» តាម

និយមន័យគឺជាបុគ្គល ដែលចង់បាននូវ «សន្តិភាព ការផ្សះផ្សាជាតិ និងការអភិវឌ្ឍ» ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាឲ្យកងពលធំលេខ៤១៥ និង៤៥០ផ្តល់លំនៅដ្ឋានសម្រាប់ អៀង សារី ក្នុងនាមជា «មេដឹកនាំស្នេហាជាតិ» ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានពន្យល់ថា គាត់មានការដឹងគុណចំពោះ អៀង សារី ដែលបាន «ធ្វើកិច្ចការដ៏មានតម្លៃសម្រាប់ប្រជាជនរាប់ពាន់នាក់» និងបាននិយាយថា «អំពើល្អរបស់ អៀង សារី នាពេលនេះ...ទូទាត់» នឹង «កំហុស» របស់គាត់កាលពីអតីតកាល ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើសេចក្តីអំពាវនាវនេះដោយឯកតោភាគី ដោយគ្មានការពិភាក្សាជាមួយសហនាយករដ្ឋមន្ត្រី នរោត្តម រណប្ញទ្ធិ ទេ ពីព្រោះនាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយថានេះជាការចាំបាច់ក្នុងការធ្វើសកម្មភាពភ្លាមៗ «ដើម្បីបញ្ចប់សង្គ្រាម» ។ នៅថ្ងៃទី១២ ខែសីហា អៀង សារី បានយល់ព្រមនឹងសំណើរបស់ អ៊ុំ ឈាន និង សុខ ភាព និងទទួលយកការផ្តល់ជូនរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលនិយាយថា គាត់នឹងបន្តដឹកនាំបំបែកខ្លួនដើម្បី «ការផ្សះផ្សាជាតិពិតប្រាកដ» ដែលហៅថា ចលនារួបរួមជាតិកម្ពុជាប្រជាធិបតេយ្យ ហើយចលនានេះនឹងចូលរួមដោយអ្នកផ្តាច់ខ្លួនដទៃទៀតដែរ ។ នៅថ្ងៃទី១៣ ខែសីហា អៀង សារី បានចូលទៅកាន់មូលដ្ឋានចាស់របស់គាត់នៅម៉ាឡៃជាថ្មីម្តងទៀត ដែលគាត់បានធ្វើសេចក្តីថ្លែងការណ៍ហៅខ្លួនឯងថាជា «អតីតមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ» និងប្រកាស ថាគាត់បានសម្រេចបន្តតួនាទីជាមេដឹកនាំខណៈពេលដែលគាត់កាត់ផ្តាច់ខ្លួនគាត់ «ចេញពីអង្គការនយោបាយ និងនីតិវិធីការងារនៃរបបដ៏ឃោរឃៅ និងហ្វាស៊ីសរបស់ ប៉ុល ពត» ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានឆ្លើយតបទៅវិញដោយនិយាយថា «អំពើល្អដែលគាត់បានធ្វើឡើងដើម្បីលុបលាងនូវកំហុសអតីតកាលរបស់គាត់គួរតែត្រូវបានទទួលស្គាល់ និងស្វាគមន៍» ។

នៅថ្ងៃទី១៧ ខែសីហា នាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើដំណើរទៅដំណាក់របស់សហនាយករដ្ឋមន្ត្រីនរោត្តម រណប្ញទ្ធិ និងបញ្ចុះបញ្ចូលព្រះអង្គឲ្យព្រមព្រៀងថា អៀង សារី គួរតែត្រូវបានលើកលែងទោសដោយព្រះមហាក្សត្រនរោត្តម សីហនុ ចំពោះអ្វីដែល អៀង សារី ត្រូវបានផ្តន្ទាទោសដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាកាលពីឆ្នាំ១៩៧៩ជាមួយនឹង ប៉ុល ពត ពីបទប្រល័យពូជសាសន៍ និងត្រូវបានផ្តល់អភ័យឯកសិទ្ធិពីការផ្តន្ទាទោសអនុលោមតាមច្បាប់ឆ្នាំ១៩៩៤ដែលបានដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់ ។ ព្រះអង្គម្ចាស់នរោត្តម រណប្ញទ្ធិ បានចុះព្រះហស្តលេខាលើលិខិតស្នើរួមមួយផ្ញើជូនទៅព្រះមហាក្សត្រ ប៉ុន្តែព្រះអង្គនៅតែបន្តនិយាយថា ព្រះអង្គជឿថានេះជាការមិនត្រឹមត្រូវទេដែលទុក ឲ្យ អៀង សារី រួចផុតពីទុក្ខទោស ។ មួយសប្តាហ៍ក្រោយមក ព្រះមហាក្សត្រនរោត្តម សីហនុ បានមានព្រះបន្ទូលថា ទ្រង់នឹងពិចារណាសំណើដោយមានភាពស្ទាក់ស្ទើរ បើសិនជារដ្ឋាភិបាល និងរដ្ឋសភារួមគ្នាទាមទារដូច្នេះ នៅក្នុងលក្ខខណ្ឌថាអង្គនីតិបញ្ញត្តិធ្វើដូច្នេះបានលុះត្រាណាមានមតិពីរភាគបីយល់ព្រម ។ នៅថ្ងៃទី១១ ខែកញ្ញា នាយករដ្ឋមន្ត្រី ហ៊ុន សែន បានជំរុញឲ្យដំណើរការទៅមុខ ដោយផ្ញើលិខិតមួយច្បាប់ជូនទ្រង់ រណប្ញទ្ធិ នូវសេចក្តីព្រាងនៃលិខិតលើកទីពីរ ដើម្បីឲ្យផ្ញើថ្វាយព្រះមហាក្សត្រចុះព្រះហស្តលេខាដោយសហនាយករដ្ឋមន្ត្រីទាំងពីរសុំការអភ័យទោសនិងលើកលែងទោសដែលបាននិយាយថាសកម្មភាពរបស់ អៀង សារី គឺ «មានតម្លៃយ៉ាងខ្លាំងសម្រាប់សន្តិភាពនិងការផ្សះផ្សាជាតិ» ហើយការដែលព្រមព្រៀងលើសំណើនឹងមិនធ្វើឲ្យខូចប្រយោជន៍ដល់រដ្ឋាភិបាលឬជាតិឡើយ ។ សហនាយករដ្ឋមន្ត្រីទីពីរ បានចុះព្រះហស្តលេខា ហើយបីថ្ងៃក្រោយមក បានជួបសំណេះសំណាលមួយជាមួយព្រះមហាក្សត្រនរោត្តម សីហនុ ។ ពេលនោះសហនាយករដ្ឋមន្ត្រីទាំងពីរបានបញ្ចុះបញ្ចូលព្រះអង្គថា ការផ្តល់ការលើកលែងទោសដ៏ឆាប់ណាមួយគឺជាការចាំបាច់សម្រាប់ប្រយោជន៍នៃសន្តិភាព និងការផ្សះផ្សាជាតិ ។ ព្រះមហាក្សត្របានយល់ព្រម និងបានចុះព្រះហស្តលេខាបន្ទាប់ពីត្រូវបានធានាដោយសហនាយករដ្ឋមន្ត្រីទាំងពីរថា យ៉ាងហោចណាស់ក៏មានការគាំទ្រពីភាគបីពីសមាជិករដ្ឋសភាដែរ ។

ដើម្បីការពារទៅលើព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានអះអាងថាការអភ័យទោស និងការលើកលែងទោស «មិនបានខុស» ពីអ្វីដែលបានធ្វើរួចមកហើយនៅឆ្នាំ១៩៧៩ទេ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានពន្យល់ថា គោលបំណងចម្បងនៃគោលនយោបាយរបស់គាត់នៅតែ «ដើម្បី

ជំរុញអង្គការកម្ពុជាប្រជាធិបតេយ្យទៅរកការបែកបាក់» តែនៅតែស្វែងរកវិធីមិនអាចបោះ «បដិសេធបទល្មើសនៃអង្គការកម្ពុជាប្រជាធិបតេយ្យទេ» ។ គាត់បានបន្ថែមទៀតថា ការពិតដែល អៀង សារី បាន «បែកបាក់ពីក្រុមកម្ពុជាប្រជាធិបតេយ្យ» បានធ្វើឲ្យគាត់ «ខុសប្លែក» ពី ប៉ុល ពត, ខៀវ សំផន, តាម៉ុក, និង សុន សេន អ្នកទាំងបួននេះនៅតែបន្តប្រឆាំងនឹងរាជរដ្ឋាភិបាលកម្ពុជា ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានបង្ហាញថាបើសិនជា អៀង សារី បន្តសកម្មភាព «ផ្តាច់ខ្លួន» ចេញពីរដ្ឋាភិបាលវិញ អៀង សារី នឹង «មានពិរុទ្ធម្តងទៀតដោយស្វ័យប្រវត្តិ» ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានទុកលទ្ធភាពដែលថា បើសិនជាមេដឹកនាំដទៃទៀតបញ្ឈប់សកម្មភាពប្រឆាំងរបស់ខ្លួន អ្នកទាំងនោះនឹងទទួលបានអ្វីដូច អៀង សារី នៅពេលនេះដែរ ។ ទាល់តែមេដឹកនាំទាំងនោះចុះចូលជាមួយរដ្ឋាភិបាល ទើបអ្នកទាំងនោះចៀសផុតពីពាក្យ «ក្បាលរឹង» ដែលអ្នកទាំងនោះរួមមាន ប៉ុល ពត, នួន ជា, តាម៉ុក, សុន សេន និង ខៀវ សំផន ។

ទាក់ទងទៅនឹងបរិបទនៃភាពមិនប្រាកដប្រជាចំពោះវិសាលភាពនៃការផ្តល់ចំពោះការលើកលែងទោស និងការអភ័យទោសចំពោះច្បាប់ឆ្នាំ១៩៩៤ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានធានាអះអាងម្តងទៀតថា យោធា និងកម្មាភិបាលខ្មែរក្រហមថ្នាក់កណ្តាលកាលពីមុន និងនាពេលបច្ចុប្បន្ន រួមមានទាំងមេបញ្ជាការមានឋានៈស្មើនឹងឧត្តមសេនីយ៍ ដូចគ្នាទៅនឹងទាហានខ្មែរក្រហមធម្មតាដែរគឺថា អ្នកទាំងនោះមិនចាំបាច់ទាមទារការសុំអភ័យទោស ឬការលើកលែងទោសដើម្បីរួចខ្លួនពីខ្មែរក្រហមនោះទេ ។ ហើយអ្នកទាំងនោះអាចបន្តកាន់តួនាទីរបស់ខ្លួនដដែល ប៉ុន្តែជាផ្នែកនៃរាជរដ្ឋាភិបាលកម្ពុជា ។ ចាប់ពីខែសីហា រហូតដល់ខែធ្នូ ឆ្នាំ១៩៩៦ មានកម្មាភិបាលខ្មែរក្រហមថ្នាក់កណ្តាល និងថ្នាក់ក្រោមរាប់ពាន់នាក់ទៀត បានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ដែលជាដំណើរការដែល អៀង សារី ដើរតួនាទីតូចតាចប៉ុណ្ណោះ តែជំនួសទៅវិញ ភាគច្រើនត្រូវបានធ្វើឡើងដោយសហនាយករដ្ឋមន្ត្រី ហ៊ុន សែន និង នរោត្តម រណឫទ្ធិ ។ ការពិត ដំណើរការនោះកើតឡើងដោយកត្តាបែកបាក់ចលនារួបរួមជាតិប្រជាធិបតេយ្យ ដែលទោះជាយ៉ាងណាក៏ដោយ អៀង សារី មិនបានដឹកនាំជាផ្លូវការឡើយ ដោយគោលការណ៍ដើមរបស់ចលនានេះបានប្រកាសថា ចលនានេះមិនបានទទួលស្គាល់អំណាចដែលកាន់ដោយ អៀង សារី ទេ ប៉ុន្តែជាអំណាចរបស់រាជរដ្ឋាភិបាលកម្ពុជាទៅវិញ ។ នៅចុងឆ្នាំ១៩៩៦ រាជរដ្ឋាភិបាលកម្ពុជាបានប៉ាន់ប្រមាណថា ទាហានខ្មែរក្រហមប្រហែលជា១.៨០០នាក់បានផ្តាច់ខ្លួនដែលភាគច្រើនជាកម្មាភិបាលខ្មែរក្រហមថ្នាក់កណ្តាល មានដូចជា នី កន, សំ ប៊ិត, ស៊ូ ម៉េត, មាស មុត, យឹម ទិត, និង អៀង ផាន់ ។ លើកលែងតែ នី កន ម្នាក់ទេ ដែលជាប្អូនប្រុសរបស់ សុន សេន ដែលមិនមែនក្រោមការដឹកនាំរបស់ តាម៉ុក ក្រៅពីនោះ សុទ្ធតែក្រោមការដឹកនាំរបស់ តាម៉ុក ក្នុងរបបបក្សកុម្មុយនីស្តកម្ពុជាគ្រប់គ្រងអំណាច ហើយអ្នកទាំងអស់នោះស្ថិតនៅក្រោមការដឹកនាំរបស់ នួន ជា អំឡុងពេលផ្តាច់ខ្លួន ។ **(នៅមានត)**


ម៉ុក និង ក្រុមគ្រួសារ

**ស៊ីង ហេងឌី**

# រឿងរ៉ាវពិតរបស់ខ្ញុំ

***(តពីលេខមុន)***

## ***ព្រាត់ស្លាប់***

ស្នាមរះភ្លោខាងស្តាំដែលទើបតែធ្លាយពីរបីថ្ងៃមិនទាន់ជាសះស្បើយផង ក៏លេចមុខឪពុករបស់ខ្ញុំត្រូវបានគេសែងយកមកដេកពេទ្យក្នុងសាលអ្នកជំងឺជាមួយខ្ញុំដែរ នៅជួរខាងក្រោយឆ្ងាយពីខ្ញុំប្រាំម៉ែត្រ ។ ពេលដែលឃើញមុខគ្នាទាំងខ្ញុំ និងឪពុកខ្ញុំមិនហ៊ាននិយាយរកគ្នា និងមិនហ៊ានទទួលស្គាល់គ្នាទេ ។ ខ្ញុំក្រឡេកមើលទៅគាត់ គាត់ក្រឡេកមើលមកខ្ញុំវិញ ហើយបានមិចភ្នែកជាសញ្ញាប្រាប់ខ្ញុំថា កុំឲ្យហៅគាត់ ដើម្បីកុំឲ្យគេដឹងថាយើងជាឪពុក និងកូនជាពិសេសកុំឲ្យពេទ្យចាប់អារម្មណ៍ ។ នៅវេលាថ្ងៃត្រង់ស្ងាត់ ពេលពេទ្យទៅសម្រាក ខ្ញុំខំប្រឹងក្រោកតោងក្បាលគ្រែដើរទៅមើលគាត់ ។ នេះជាថ្ងៃទីមួយដែលខ្ញុំបានក្រោកដើរ ដើម្បីទៅជួបអ្នកមានគុណដែលផ្តល់ជីវិតឲ្យខ្ញុំ ។ ខ្ញុំឃើញគាត់មានរូបរាងស្គម ស្បែកស្វាំងសល់តែស្បែកដណ្តប់ឆ្អឹង មុខឡើងខ្មៅ ភ្នែករូងជ្រៅ និងក្បាលជង្គង់ធំជាងភ្លៅ ចំណែកដៃ និងជើងទន់ ។ លើសពីនេះ កែងជើង និងខ្នងជើងខាងឆ្វេងគាត់មានដំបៅរលួយ និងមានដង្កូវបោះស៊ី ឃើញឆ្អឹងកែងជើងទំហំប៉ុនផ្លែក្រសាំង ហើយរូបរាងទាំងមូលមើលទៅឡើងសម្បុរខ្មៅដូចខ្មោចស្លាប់ច្រើនថ្ងៃមកហើយ ។

គាត់មានស្មារតីនឹងនរល្អណាស់ គាត់និយាយខ្សាវៗស្តាប់មិនចង់ឮ មកកាន់ខ្ញុំថា ដំបៅជើងរបស់គាត់មិនឈឺទេ ប៉ុន្តែគាត់ឃ្លានខ្លាំងជាងឈឺទៅទៀត ហើយបានផ្តាំទៀតថា មិនត្រូវឲ្យគេដឹងថាគាត់ជាឪពុក និងខ្ញុំជាកូនឈឺដេកក្នុងពេទ្យតែមួយ ហើយនៅបន្ទប់ជាមួយគ្នាទេ ។ ពេលដែលគាត់ស្លាប់ កុំឲ្យយំ គឺត្រូវធ្វើដូចធម្មតា ដើម្បីរក្សាជីវិតមើលថែទាំម្តាយ និងប្អូនៗរបស់ខ្ញុំ ។ ខ្ញុំបានប្រាប់គាត់ថា កុំឲ្យគាត់និយាយទៀត ទ្រាំមួយសន្ទុះទៀត ដល់ពេលគេចែកបាយល្ងាចហើយ រួចខ្ញុំក៏ដើរតោងគ្រែត្រឡប់មកកន្លែងខ្ញុំវិញ ។ ខ្ញុំអាណិតគាត់ខ្លាំងណាស់ តែមិនអាចជួយអ្វីគាត់បានឡើយ ព្រោះដំបៅជើងរបស់ខ្ញុំទើបតែជា ហើយខ្ញុំទើបតែរៀនដើរប៉ុណ្ណោះ ។

ពេលល្ងាចមកដល់ ពេទ្យបានមកចែកបាយឲ្យអ្នកជំងឺ ។ ខណៈនោះ មិនទាន់ទាំងចែកសម្លឲ្យគាត់ផង ខ្ញុំឃើញគាត់ជួសបាយហូបតែបីស្លាបព្រាក៏អស់ល្មម ។ ឃើញដូច្នេះពេទ្យ ក៏ប្រមូលយកចានបាយ និងចានសម្លរបស់គាត់ដែលមិនទាន់បានហូបទៅវិញ ហើយថែមទាំងបានស្តីបន្ទោសឲ្យគាត់ថា ហូបអាក្រក់ ។ ខ្ញុំនឹកគិតថា មិនដឹងជានៅអង្គភាពភ្ជួរអង្គការបង្អត់អាហារគាត់យ៉ាងដូចម្តេចទេ ព្រោះខ្ញុំគ្រាន់តែដឹងថា នៅទីនោះគេឲ្យហូបតែបបររាវៗ ចំពោះអ្នកឈឺត្រូវកាត់បន្ថយបបរថែមទៀត ។ នឹកឃើញដល់រឿងនេះ ខ្ញុំក៏បានយកបាយមួយដុំលាក់ទុកឲ្យឪពុកខ្ញុំពិសា ប៉ុន្តែពេទ្យមើលឃើញទាន់ ហើយយកបាយនេះទុកវិញ ។ ថ្ងៃស្អែកឡើង ស្រាប់តែពេទ្យចែកបាយខ្ញុំតែបន្តិចប៉ុណ្ណោះ ព្រោះគិតថាខ្ញុំហូបមិនអស់ ។

នៅល្ងាចនោះ ក្នុងចិត្តខ្ញុំកំពុងតែខ្វល់ខ្វាយ ស្រាប់តែខ្ញុំឃើញពេទ្យសែងអ្នកជំងឺម្នាក់ទៀតចូលមកដាក់នៅលើដី ចន្លោះចុងជើងរបស់ខ្ញុំ ដោយដៃជើងខ្លួនរបស់អ្នកជំងឺនោះរឹងក្រញ៉ង់ កម្រើកមិនរួច ចំណែកមាត់បិទមិនជិតទេ ថែមទាំងនិយាយមិនរួចទៀត ។ ខ្ញុំបានមើលអ្នកជំងឺនេះមួយស្របក់ ទើបស្គាល់ថា ជាបងប្រុសទីពីររបស់ខ្ញុំឈ្មោះ លី ប៊ុនយឹម ដែលប្រធានភូមិឈ្មោះ ឡាក់ បញ្ជូនទៅអង្គភាពយុវជន នៅមុនពេលប្រធានភូមិលាជបញ្ជូនខ្ញុំទៅអង្គភាពកុមារមួយថ្ងៃ ។ ខ្ញុំបានបែកពីគាត់រយៈពេលជាងមួយឆ្នាំ និងមិនដែលបានទទួលព័ត៌មានពីគាត់ម្តងណាឡើយ ។ ខ្ញុំគិតថាប្រហែលជាគាត់មិនដឹងថា ខ្ញុំត្រូវធ្លាក់ពីដើមស្វាយបាក់ជើង និងមកដេកពេទ្យនេះដែរ ហើយខ្ញុំក៏មិនដែលបានឮម្តាយខ្ញុំនិយាយអ្វីពីគាត់ដែរ គឺទើបតែបានជួបគ្នាស្ថិតក្នុងសភាពមានជំងឺដូច្នេះ ។ ចំណែក ឪពុករបស់ខ្ញុំវិញប្រហែលជាមើលបងប្រុសរបស់ខ្ញុំមិនស្គាល់ដែរ ព្រោះគាត់មិនបាននិយាយអ្វីប្រាប់ខ្ញុំទេ ម្យ៉ាងទៀតគាត់ចុះខ្សោយណាស់ទៅហើយ ។ ល្ងាចនោះ ពេទ្យបានចែកបបរឲ្យអ្នក

ជំងឺដូចសព្វដង អ្នកជំងឺណាក្រោកមិនរួចក៏ពេទ្យដាក់ចានចែកបបរឲ្យដូចគ្នាដែរ ។

នៅក្នុងមន្ទីរពេទ្យនេះ មានភ្លើងអគ្គិសនីបំភ្លឺត្រឹមម៉ោងប្រាំបួនយប់ ដូច្នេះប្រសិនបើនរណាឈឺធ្ងន់ គឺគ្មានពេទ្យមកមើលទេ ។ ឆៀតពេលហូបបាយល្ងាចរួច ពេលដែលពេទ្យមិននៅ ខ្ញុំក៏ខំប្រឹងគោងគ្រែដើរទៅមើលបងប្រុសរបស់ខ្ញុំ រួចសួរគាត់ថា ស្តាប់ឮខ្ញុំនិយាយទេ? គាត់ខំប្រឹងនិយាយមកខ្ញុំវិញ តែគាត់និយាយមិនចេញ បានត្រឹមបញ្ចេញសំឡេងខ្យល់តាមបំពង់ក និងសម្លឹងមើលខ្ញុំមិនដាក់ ហើយបង្ហូរទឹកភ្នែកប៉ុណ្ណោះ ។ ខ្ញុំបានយកដៃជូតទឹកភ្នែកគាត់ ហើយប្រាប់ថា ឪពុកយើងក៏ឈឺដូចយើងដែរ គាត់ដើរមិនរួចទេ ហើយគាត់សម្រាកនៅគ្រែខាងមុខនេះ ។ និយាយចប់ ខ្ញុំក៏ក្រោកគោងគ្រែបន្តទៅមើលឪពុកខ្ញុំទៀត ។ ទៅដល់គ្រែ ឪពុកខ្ញុំសួរខ្ញុំថានិយាយជាមួយនរណាគេ? ខ្ញុំបានឆ្លើយប្រាប់គាត់ថា ខ្ញុំនិយាយជាមួយបង យឹម និងបានប្រាប់គាត់ពីស្ថានភាពជំងឺរបស់បង យឹម ថា រង់ចាំតែស្លាប់ប៉ុណ្ណោះ ។ ឪពុករបស់ខ្ញុំប្រាប់ថា គាត់ចង់ដើរទៅមើលបង យឹម ដែរ តែក្រោកដើរមិនរួច ។ គាត់បានបន្ថែមថា កុំឲ្យខ្ញុំគិតអ្វីក្រៅពីជួយខ្លួនឯង មនុស្សមួយចំនួនត្រូវស្លាប់ដោយវាយនឹងត្បូងចប ជីករណ្តៅខ្លួនឯង វាយទម្លាក់រណ្តៅ អ្នកខ្លះទៀតកំពុងធ្វើការស្រាប់តែឈ្លបចងដៃទាំងពីរអូសឲ្យរត់តាមសេះ ស្លាប់យ៉ាងវេទនា ចំណែកយើងស្លាប់ដោយអត់អាហារ និងជំងឺចាត់ទុកសំណាងហើយ ។ គាត់និយាយទាំងវង្វេងថា គាត់បានឃើញរទេះសេះចុះមកពីលើមេឃរង់ចាំទទួលគាត់ ហើយគាត់ក៏សន្យាថា ចាំពេលភ្លឺ ព្រោះគាត់សូមផ្តាំផ្ញើប្រពន្ធកូនសិន ហើយពេលគាត់ចាកចេញទៅ កុំឲ្យខ្ញុំយំស្រែក និងកុំឲ្យគេដឹងថាយើងជាឪពុកកូន ។ និយាយចប់ គាត់ក៏បានដេញខ្ញុំឲ្យត្រឡប់មកគ្រែខ្ញុំវិញ ។ ពេលខ្ញុំត្រឡប់មកវិញ ដល់ពេលពន្លត់ភ្លើងល្មម ធ្វើឲ្យក្នុងសាលអ្នកជំងឺទាំងមូលស្ងាត់ជ្រងំ ។ មួយយប់ដល់ភ្លឺ ខ្ញុំឮសូរតែសំឡេងថ្ងូរឈឺចាប់ជុំវិញគ្រែរបស់ខ្ញុំ ព្រោះអ្នកជំងឺដែលមកសម្រាកក្នុងសាលនេះគឺជាអ្នកជំងឺធ្ងន់ទាំងអស់ កម្រមានអ្នកជាបានវិលត្រឡប់ទៅវិញណាស់ ។ លុះស្អែកឡើង ពេលថ្ងៃត្រង់ឪពុកខ្ញុំបានក្រោកហូបបបរដូចសព្វដង មួយសន្ទុះទើបគាត់ប្រះខ្លួនសម្រាន្ត ដោយមានលើកដៃជាសញ្ញាថាលាហើយ ។

ដល់ពេលរសៀល ពេទ្យក៏ដើរពិនិត្យមើលអ្នកជំងឺទាំងអស់ ហើយពេលមកដល់គ្រែឪពុកខ្ញុំ ពេទ្យក៏និយាយខ្លាំងៗថា គាត់ស្លាប់បាត់ហើយ ហើយក៏ដើរបន្តទៅមើលគ្រែអ្នកជំងឺផ្សេងទៀត ។ តាមការពិត ពេទ្យដើរមកនោះ មិនមែនមកពិនិត្យឬព្យាបាលអ្នកជំងឺទេ គោលបំណងដើម្បីដឹងថាតើនរណាខ្លះស្លាប់តែប៉ុណ្ណោះ ព្រោះពេទ្យគ្មានថ្នាំព្យាបាលទេ មានតែថ្នាំសង្គមកិច្ចអាស្ពីរីនដែលធ្វើពីដំឡូងមី និងថ្នាំបំបាត់រាគដែលធ្វើអំពីកន្ទុកនិងសេរ៉ូមច្រកដបទឹកក្រូចប៉ុណ្ណោះ ។ បន្ទាប់ពីពេទ្យនារីចេញទៅបាត់ ពេទ្យប្រុសក្មេងៗបានចូលមកសែងខ្មោចឪពុកខ្ញុំ ។ ខ្ញុំសម្លឹងមើលអ្នកទាំងនោះសែងសពឪពុកខ្ញុំយកទៅដាក់លើរទេះគោជាមួយសាកសពអ្នកជំងឺបួនប្រាំនាក់ផ្សេងទៀត ទាំងរន្ធត់ក្នុងចិត្ត ។

ចំណែក បងប្រុសខ្ញុំនៅមានដង្ហើមនៅឡើយ ក៏ត្រូវពេទ្យសែងយកទៅបោះចោលជាមួយសាកសពអ្នកជំងឺដែរ ។ ខ្ញុំឮពេទ្យនិយាយគ្នាថា មិត្ត (បង យឹម) នេះ ឃ្លានស្ករខ្លាំងពេកហូបស្ករអស់មួយកំប៉ុងវីហ្គោ (កំប៉ុងម្សៅទឹកដោះគោជំនាន់ លន់ ណុល) ក៏ឡើងហើម និងទាញសសៃដៃ សសៃជើង និងរឹងខ្លួនក្រញ៉ង់ ដូចជ្រូកខ្វៃ តែរឿងហេតុពិតយ៉ាងណានោះខ្ញុំក៏មិនបានដឹងប្រាកដដែរ ។ ពេលនោះ ខ្ញុំមិនហ៊ានស្រែកយំឲ្យពេទ្យឮទេ ព្រោះខ្លាចដឹងថាខ្ញុំជាប់សាច់ញាតិនឹងគាត់ទាំងពីរនាក់នោះ ។

ក្រោយពីពេទ្យដឹកសពឪពុក និងបងប្រុសរបស់ខ្ញុំយកទៅកប់ចោលនៅរណ្តៅនៅព្រៃចម្ការក្រូចបានមួយថ្ងៃ លុះពេលថ្ងៃត្រង់ក៏ឃើញម្តាយខ្ញុំបានពរប្អូនប្រុសពៅខ្ញុំចូលមកជួបខ្ញុំទាំងទឹកភ្នែករលីងលោងប្រាប់ថា គាត់បានចូលមកសម្រាកនៅសាលនារីនៃមន្ទីរពេទ្យនេះរយៈពេលបីថ្ងៃមកហើយ ប៉ុន្តែគាត់ទើបដឹងរឿងនេះកាលពីថ្ងៃម្សិលមិញ ពេលគាត់ដើររកមើលខ្ញុំក្នុងសាលអ្នកជំងឺនេះ ព្រោះគាត់សង្ស័យថា ប្រហែលជាខ្ញុំដេកឈឺក្នុងមន្ទីរពេទ្យនេះដែរ ។ គាត់និយាយប្រាប់ខ្ញុំថា គាត់ដើររកបន្លែកន្ទែងឆ្ងាយៗដើម្បីផ្គត់ផ្គង់រោគបាយ ធ្វើឲ្យគាត់គ្មានទឹកដោះឲ្យកូនបៅទេ ហើយចាប់តាំងពីពេលនោះគាត់ចាប់ផ្តើមធ្លាក់ខ្លួនឈឺស្គម ។ ឥឡូវពេលគាត់ដឹងថា ប្តីស្លាប់ និងកូនប្រុសស្លាប់បែបនេះកាន់តែធ្វើឲ្យគាត់អស់សង្ឃឹម និងពិបាកចិត្តខ្លាំងឡើងថែមទៀត ។ គាត់បានផ្តាំខ្ញុំឲ្យខំប្រឹងប្រែងរស់តទៅទៀត ព្រោះក្នុងគ្រួសារខ្ញុំ គាត់សង្ឃឹមតែខ្ញុំ

ម្នាក់ទេដែលអាចនៅមើលថែរក្សាប្អូនៗបាន ។ ចំណែកគាត់ប្រហែលជារស់មិនបានយូរទេ ព្រោះគាត់មិនមានកម្លាំងកំហែង ។ ក្រោយពីនិយាយចប់ គាត់ឱបខ្ញុំ ហើយយំយ៉ាងខ្លាំង រួចឈានជើងដើរស្ទើរមិនរួចត្រឡប់ទៅកន្លែងគាត់វិញ ។

នៅយប់នោះ ខ្ញុំដេកមិនលក់ទេចេះតែស្រមៃឃើញបណ្ដាំឪពុកនិងម្ដាយខ្ញុំ ។ ខ្ញុំយល់សប្តិឃើញ ស្រមោលខ្មៅដែលនៅចាំដើមស្វាយមកសង្កត់ខ្ញុំជាញឹកញាប់ និងវិលវល់ក្បែរគ្រែខ្ញុំមិនព្រមទៅណាទេ ហើយខ្ញុំក៏ចេះតែបណ្ដោយខ្លួនឲ្យខ្មោចនោះសង្កត់ខ្ញុំតាមចិត្តដែរ ដល់យូរៗទៅរឿងខ្មោចសង្កត់វាទៅជាផ្សាំសម្រាប់រូបខ្ញុំ ។ យប់នោះ ខ្ញុំបន់ឲ្យតែឆាប់ភ្លឺ ។ លុះភ្លឺឡើង ក្រោយពេលដឹកថ្នាំសង្គមកិច្ច និងហូបបាយថ្ងៃត្រង់រួច ខ្ញុំក៏រកបានឈើច្រត់ ហើយច្រត់សៀរៗទៅរកម្ដាយខ្ញុំនៅសាលអ្នកជំងឺផ្នែកនារី ។ ប៉ុន្តែពេលចូលដល់សាល ខ្ញុំសម្លឹងរកគាត់មិនឃើញ ខ្ញុំក៏សួរមីងៗដែលសម្រាកព្យាបាលជំងឺនៅទីនោះ ទើបពួកគាត់ប្រាប់ថាម្ដាយខ្ញុំនិងប្អូនខ្ញុំបានស្លាប់កាលពីព្រឹកមិញហើយ ចំណែកសពត្រូវពេទ្យដឹកយកចេញទៅមុនពេលខ្ញុំទៅដល់បន្តិចប៉ុណ្ណោះ ។ ខ្ញុំស្លុតចិត្តយ៉ាងខ្លាំង ចំណែកស្មារតីវង្វេងវង្វាន់ និងចង់ក្លាយជាមនុស្សវិកលចរិត ។ ខ្ញុំទន់ជង្គង់ ងងឹតមុខស្លុប និងរកកលដួល ព្រោះក្នុងរយៈពេលតែបីថ្ងៃប៉ុណ្ណោះ គ្រួសាររបស់ខ្ញុំស្លាប់អស់បួននាក់ ។

រយៈពេលប្រមាណជាងដប់ថ្ងៃក្រោយមក ក៏លេចមុខប្អូនស្រីទីប្រាំមួយរបស់ខ្ញុំឈ្មោះ ប៉ោឈួង អាយុប្រាំពីរឆ្នាំ មករករូបខ្ញុំនៅមន្ទីរពេទ្យ ហើយប្រាប់ខ្ញុំថា នាងរស់នៅជាមួយប្អូនទីប្រាំពីរឈ្មោះ ប៉ោងីម អាយុបួនឆ្នាំ ។ ប្អូនស្រីខ្ញុំរស់នៅតែពីរនាក់ ហើយគ្មានថែរក្សានោះទេ ។ ពេលនោះ នាងបន្តរៀបរាប់ទាំងទឹកភ្នែកថា នៅថ្ងៃដែលអគ្គភាពកុមារធ្វើនំបញ្ចុកហូប នាងបានដឹកដៃប្អូនដើររកបង ស្រីឈ្មោះ ប៉ោលួង អាយុដប់ឆ្នាំ ដែលធ្វើការនៅអគ្គភាពកុមារ ប៉ុន្តែបងស្រីឈ្មោះ ប៉ោលួង និងប្រធានកុមារដេញឲ្យត្រឡប់មកភូមិវិញ ។ បងស្រីមិនត្រឹមតែមិនចែករំលែកនំបញ្ចុកគាត់ឲ្យនាងហូបទេ ថែមទាំងយកកាំបិតមកកាប់ឲ្យត្រូវរបួសដៃទៀតផង ពេលនាងទទូចសុំនំបញ្ចុកហូបបន្ថែម ។ នាងបាននាំប្អូនត្រឡប់មកភូមិ ដែលមានចម្ងាយប្រមាណជាងពីរគីឡូម៉ែត្រដើម្បីបើករបប ប៉ុន្តែពេលមកដល់ភូមិ ក៏ត្រូវអ្នកគ្រប់គ្រងកុមារនៅទីនោះហូបអស់ទៀត ។ យប់នោះ ពីរនាក់បងប្អូនដេកអត់អាហារ បានត្រឹមនំបញ្ចុកមួយម៉ាត់ម្នាក់ប៉ុណ្ណោះ ។

## ព្រាត់រស់

ក្រោយមក មានអ្នកមូលដ្ឋានម្នាក់ចង់យកនាងធ្វើជាកូនចិញ្ចឹម ប៉ុន្តែមិនយក ប៉ោងីម ទេ ព្រោះវាតូចពេកអត់ចេះធ្វើការ គឺចេះតែស្រែកយំប៉ុណ្ណោះ ។ នាងបានមកប្រាប់ខ្ញុំ ហើយខ្ញុំក៏បាននិយាយលួងលោមនាងកុំឲ្យទៅជាមួយអ្នកមូលដ្ឋានអីវង់ចាំខ្ញុំចេញពីពេទ្យដើម្បីយើងបានទៅរស់នៅជុំគ្នាវិញ ។ ប៉ុន្តែនាងមិនព្រម ហើយនាងបានប្រាប់ខ្ញុំថា នាងនឹងទៅរស់នៅជាមួយអ្នកមូលដ្ឋានហើយ រួចក៏លាខ្ញុំត្រឡប់ទៅភូមិវិញទាំងទឹកភ្នែក ។

ខ្ញុំគិតថា ប្អូនស្រីខ្ញុំប្រាកដជាចាញ់សម្ដីលួងលោមរបស់អ្នកមូលដ្ឋាន ព្រោះនាងមានអាយុប្រាំពីរឆ្នាំហើយ អាចប្រើជំនួសដៃជើងរបស់គេបាន ។ ពេលនោះ ខ្ញុំក៏មិនបានស្គាល់អ្នកមូលដ្ឋាននោះឈ្មោះអ្វី? មុខមាត់យ៉ាងដូចម្ដេច? ហើយស្រុកវាលវែងនោះឯណាផង? គឺបានត្រឹមតែឮនាងនិយាយប្រាប់ប៉ុណ្ណោះ ។

ក្នុងចិត្តរបស់ខ្ញុំចង់លួចចេញពីពេទ្យទៅជួបប្អូនៗដើម្បីឲ្យមានការកក់ក្ដៅ ប៉ុន្តែបើសិនជាខ្ញុំហ៊ានលួចទៅគឺត្រូវចំណាយពេលកន្លះថ្ងៃ ហើយមិនដឹងថាខ្លួនខ្ញុំអាចដើរទៅដល់ភូមិដែរ ឬយ៉ាងណាទេ ព្រោះខ្ញុំទើបតែរៀនដើរកាន់ឈើច្រត់ ។ ម្យ៉ាងវិញទៀត ប្រសិនបើនរណាម្នាក់ទៅកន្លែងណាមួយ ដោយគ្មានលិខិតឧទ្ទេសនាមនោះច្បាស់ជាគ្មានរបបអាហារហូបឡើយ ។

ខ្ញុំបានក្លាយទៅជាក្មេងកំព្រា និងក្លាយជនពិការនៅអាយុដប់ប្រាំមួយឆ្នាំ និងត្រូវធ្វើជាអាណាព្យាបាលមើលថែរក្សាប្អូនតូចៗទៀត ។ ប៉ុន្តែដោយសារតែខ្ញុំនៅក្នុងមន្ទីរពេទ្យនៅឡើយ មិនដឹងថា តើប្អូនពីរនាក់នៅអគ្គភាពកុមារមានសុខទុក្ខយ៉ាងណាទេ ចំពោះខ្លួនឯងក៏មិនដែលសង្ឃឹមថាអាចរក្សាជីវិតឲ្យគង់ដែរ ។ មួយសប្ដាហ៍ក្រោយមក មុខរបួសចាប់ផ្ដើមសះ ហើយចំពេលពេទ្យថ្មីផ្លាស់មក ក៏បានធ្វើលិខិតឧទ្ទេសនាមឲ្យខ្ញុំចេញពីមន្ទីរពេទ្យ ។ ព្រឹកមួយ ពេទ្យកុមារម្នាក់ដែលមានអាយុស្របាលខ្ញុំបានយកកង់មួយគ្រឿងមកឌុបខ្ញុំ ហើយនិយាយប្រាប់ខ្ញុំថា ខ្ញុំត្រូវចេញពីមន្ទីរពេទ្យនៅថ្ងៃនេះហើយ ។ ខ្ញុំភ័យផងអរផង ព្រោះជាថ្ងៃទីមួយដែលខ្ញុំបានចេញពីមន្ទីរពេទ្យនេះ ខ្ញុំឃើញវាលស្រែពណ៌បៃតងស្រស់ ទីណា

ក៏មានសន្ទូងពេញស្រែ ប៉ុន្តែខ្ញុំនឹកក្នុងចិត្តថាចុះហេតុដូចម្តេចបានជាខ្ញុំឪពុកម្តាយ និងបងប្អូនខ្ញុំ មិនមានបាយហូបគ្រប់គ្រាន់ មិនត្រឹមតែប៉ុណ្ណោះមានជំងឺ និងអ្នកស្លាប់ជាច្រើនដោយសារអត់ឃ្លាន ។ មានប្រជាជនជាច្រើនបានធ្លាក់ខ្លួនឈឺ ដោយសារអត់អាហារ ហើយបានមកសម្រាកព្យាបាលក្នុងមន្ទីរពេទ្យជាមួយខ្ញុំ ពិសេសប្រជាជនអ្នក១៧មេសា ដែលមិនសូវចេះធ្វើស្រែ ។

កំពុងតែនឹកគិតដល់រឿងនេះ ស្រាប់តែខ្ញុំមានអារម្មណ៍ភ័យព្រួយមួយរំពេច ព្រោះតាមផ្លូវដែលពេទ្យកុមារបានឌុបខ្ញុំមកមិនឃើញមានមនុស្សណាម្នាក់សោះ គឺមានតែពេទ្យនិងរូបខ្ញុំម្នាក់តែប៉ុណ្ណោះ ។ ពេទ្យកុមារនោះមិនបាននិយាយរកខ្ញុំសូម្បីតែមួយម៉ាត់ ហើយខ្ញុំក៏មិននិយាយសួរនាំទៅពេទ្យនោះដែរ ។ ពេលនោះខ្លួនខ្ញុំបានក្លាយទៅជាស្ពឹកស្រពន់ តែខ្ញុំខំប្រឹងទ្រាំដើម្បីឲ្យពេទ្យនោះជូនខ្ញុំចូលមកក្នុងភូមិ ។ ទៅដល់ ពេទ្យនោះឲ្យខ្ញុំអង្គុយនៅកៅអីផ្ទះបាយ រួចហើយក៏ហុចលិខិតខ្ទេសនាមឲ្យខ្ញុំ ដើម្បីយកទៅប្រគល់ឲ្យប្រធានរោងបាយ ។

## សល់ពីស្លាប់

ក្រោយពីប្រធានរោងបាយបានទទួលលិខិតអនុញ្ញាតឲ្យខ្ញុំចាកចេញពីមន្ទីរពេទ្យស្រុកលាច រួចគាត់បានសួរខ្ញុំថា "តើមិត្តឯងឈ្មោះអ្វី?" ខ្ញុំបានជំរាបគាត់ថាឈ្មោះ សៅ ។ ខ្ញុំបានប្តូរឈ្មោះថា សៅ ព្រោះខ្ញុំខ្លាចលេចឮដំណឹងថាខ្ញុំបានចេញពីមន្ទីរពេទ្យ ហើយកុមារផ្សេងៗទៀតនៅក្នុងភូមិនោះស្គាល់ឈ្មោះពិតខ្ញុំ ហើយផ្តល់ព័ត៌មាននេះទៅប្រធានអង្គភាព ប្រាកដជាប្រធានអង្គភាពស្នើឲ្យប្រធានភូមិបញ្ជូនខ្ញុំទៅកន្លែងដើមរបស់ខ្ញុំមិនខាន ។ ពេលនោះ ខ្ញុំច្បាស់ជាត្រូវទទួលទណ្ឌកម្ម ឬអាចស្លាប់បាត់បង់ជីវិត ។

ប្រធានភូមិបានមកជួបខ្ញុំ និងប្រគល់រូបខ្ញុំឲ្យទៅប្រធានរោងបាយគ្រប់គ្រងរួចហើយ គាត់ក៏ត្រឡប់ទៅធ្វើការងាររបស់គាត់វិញ ។ ប្រធានរោងបាយជាស្រ្តីវ័យចំណាស់អាយុជាងសែសិបឆ្នាំ ជាអ្នកមូលដ្ឋាន ហើយមើលទៅទំនងជាមិនចេះអក្សរទេ (កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យថ្នាក់ក្រោម និងរស់នៅតាមមូលដ្ឋានភូមិឃុំភាគច្រើនជាអ្នកដែលមិនបានរៀនសូត្រជ្រៅជ្រះទេ គឺពួកគេចេះតែទ្រឹស្តីបដិវត្តន៍ និងការអនុវត្តតាមការណែនាំរបស់ថ្នាក់លើប៉ុណ្ណោះ) ។ គាត់បានប្រាប់ឲ្យខ្ញុំទៅនៅរោងមួយទៀត (ជារោងកុមារតូចនិងទារកដ្ឋានក្នុងភូមិសង់ពីឈើប្រក់ស្បូវ និងជាកន្លែងយាយ១៧មេសាមើលថែទាំកុមារតូច) ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីរោងបាយរួម ។ គាត់បានប្រាប់ខ្ញុំឲ្យមកហូបបាយជាមួយកុមារក្នុងភូមិពេលណាឮសូរសឡេងរគាំងលើកទីមួយ ចំណែករគាំងលើកទីពីរជាម៉ោងបាយថ្ងៃត្រង់សម្រាប់មនុស្សចាស់ក្នុងភូមិមកហូបបាយ ហើយរគាំងលើកទីបីជាម៉ោងបាយរបស់អ្នកពេញកម្លាំងក្នុងរាស់ដកស្ទូង ។

ខ្ញុំមានអារម្មណ៍ព្រួយបារម្ភខ្លះពីការដែលមិនអាចបំពេញភារកិច្ចជូនអង្គការបាន ព្រោះខ្ញុំទន់ខ្សោយ និងស្លេកស្លាំង ។ ខ្ញុំដើរទៅណាមកណាត្រូវកាន់ឈើច្រត់ជាប់ជាមួយ ហើយដើរបានតែងបួនប្រាំម៉ែត្រក៏ទន់ជើងទន់ដៃទៀត ដោយសារខ្ញុំមិនបានត្រូវពន្លឺថ្ងៃច្រើនខែមកហើយ ។ ពេលនោះជាថ្ងៃទីមួយដែលខ្ញុំបានទទួលពន្លឺថ្ងៃ និងអាចដើរ អង្គុយ ឈរតាមដែលខ្ញុំអាចធ្វើបាន ។ ខ្ញុំដើរកាន់ឈើច្រត់សំដៅទៅរោងកុមារ ខ្ញុំបានឃើញយាយៗជាអ្នកមើលកុមារកំពុងធ្វើការងាររបស់គាត់យ៉ាងស្ងៀមស្ងាត់ ដូចជាមិនភ្ញាក់ផ្អើលនឹងការមកដល់របស់ខ្ញុំសោះ គឺគ្រាន់តែសម្លឹងមករកខ្ញុំ ចំណែកដៃទាំងពីរបន្តដេរស្លឹកមិនឈប់ គឺម្នាក់ៗគិតពីរឿងការងាររៀងខ្លួន ។

## ជួបប្អូនដំបូង

ខ្ញុំបានជម្រាបសួរគាត់ និងនិយាយប្រាប់ថា ខ្ញុំទើបចេញពីមន្ទីរពេទ្យថ្ងៃនេះ គ្រួសាររបស់ខ្ញុំគឺនៅភូមិនេះដែរ ហើយឥឡូវខ្ញុំមករកប្អូនស្រីរបស់ខ្ញុំពីរនាក់ ព្រោះឮថាពួកគេនៅកងកុមារនេះ ។ យាយៗជាអ្នកមើលថែទាំក្មេងតូចប្រាប់ខ្ញុំថា ៖ ប្អូនស្រីក្មួយឯងនៅម្នាក់ទេ ម្នាក់ទៀតបានទៅស្រុកលើជាមួយអ្នកមូលដ្ឋានហើយ គឺនាងតូចនៅអង្គុយត្រង់នោះ ។ ខ្ញុំបានដើរសំដៅទៅរកប្អូនស្រីខ្ញុំ មានរូបរាងស្គមកំព្រឹង សក់ក្បាលសំពីងសំពោង មានចៃពេញក្បាល និងមុខមាត់ប្រឡាក់ស្រម៉ក ។ គ្រាន់តែនាងក្រឡេកឃើញខ្ញុំភ្លាម នាងហាក់ដូចជាភ័យផងអរផង ដែលទំនងដូចជាចង់ភ្លេចខ្ញុំហើយ ។ យាយម្នាក់ដែលនៅក្បែរនោះប្រាប់នាងថា នេះបងប្រុសឯង ពេលនោះនាងក៏យំហ៊ូហើយរត់មកឱបជើងខ្ញុំធ្វើឲ្យខ្ញុំរន្ធត់រហូតស្រក់ទឹកភ្នែកដែរ ។ ប្អូនស្រីខ្ញុំដែលទើបមានអាយុបួនឆ្នាំ

បានរស់នៅកំព្រាគ្មានឪពុកម្តាយ និង បងប្អូនថែទាំរយៈពេលជាង មួយខែមកហើយ ហើយនៅពេលនោះ មិនមែនមានតែក្រុមគ្រួសារខ្ញុំមួយ ទេដែលព្រាត់ប្រាស់គ្នានោះ គឺមានគ្រួសារអ្នកដទៃក៏មានឪពុកម្តាយស្លាប់ចោលដែរ ។ គ្រួសារអ៊ំប្រុសខ្ញុំពីរគ្រួសារ កាលខ្មែរក្រហមជម្លៀសចេញពីភ្នំពេញឲ្យទៅភូមិឃុំលាជជា មួយគ្នាបានស្លាប់អស់ខ្លះ ហើយរហូតក្រោយពេលដែលខ្ញុំចេញពីមន្ទីរពេទ្យមក គឺស្លាប់គ្មានសល់ម្នាក់ឡើយ ។

ក្នុងភូមិបន្សល់ទុកផ្ទះសង់ពីដើមឫស្សីពីរជួរអមសងខាងផ្លូវ ខ្ញុំតែងតែហៅថាផ្ទះឫស្សី គឺសសរផ្ទះ និងរនាបក៏ជាឫស្សី ចំណែកដំបូលប្រក់ស្បូវនិងស្លឹក ។ នៅលើផ្ទះគ្មានមនុស្សនៅសូម្បីតែម្នាក់ គឺឮសូរសំឡេងសត្វស្រែកយំប៉ុណ្ណោះ ។ ពេលនោះខ្ញុំនៅក្មេងនៅឡើយ ប៉ុន្តែខ្ញុំឆ្ងល់ថា ៖ ហេតុអ្វីក៏ផ្ទះរបស់អ្នកភូមិទាំងអស់គ្នាត្រូវបើកចំហគ្រប់ផ្ទះ លើកលែងតែផ្ទះមូលដ្ឋានមានមនុស្សនៅ ទ្វារបិទឬបើកស្រេចលើគេ ។ ភាពស្ងាត់ជ្រងំបែបនេះធ្វើឲ្យខ្ញុំនឹកស្រងេះស្រងោច នឹកឪពុកម្តាយ និងនឹកឃើញកាលនៅភ្នំពេញ និងពាក្យចាស់ៗនិយាយតំណាលថា មានផ្ទះអត់មានមនុស្សនៅ មានផ្លូវអត់មានមនុស្សដើរ ។

## ការងារស្រាល

ក្រោយពីខ្ញុំចេញពីមន្ទីរពេទ្យបានមួយរយៈមក ប្រធានភូមិបានប្រគល់ការងារឲ្យខ្ញុំធ្វើការងាររបស់ខ្ញុំ គឺពុះឫស្សី និងបិទដងកណ្តប និងច្រៀកគៀវត្នោតធ្វើជាក្បាបសម្រាប់យាយៗដេរស្លឹក និងក្រងស្បូវ ។ រៀងរាល់ព្រឹកខ្ញុំខំប្រឹងធ្វើការងាររបស់ខ្ញុំមិនហ៊ានឈប់នៅស្ងៀមឡើយ ។ ចំណែកស្រីៗអ្នកស្ទូងចេញពីផ្ទះអស់ រហូតដល់ថ្ងៃត្រង់ទើបឃើញមកភូមិវិញ ។ បន្ទាប់ពីហូបបាយថ្ងៃត្រង់រួច ក៏នាំគ្នាត្រឡប់ទៅដក ស្ទូងអស់ ដល់ល្ងាចទើបត្រឡប់មកវិញ គឺនៅពេលព្រលប់ៗទៅហើយ ឯប្រុសៗធ្វើការតាមការដ្ឋានទាំងអស់ លើកលែងតែចាស់ៗជាអ្នកភ្ជួររាល់ និងជាងធ្វើផ្ទះបីបួននាក់ មកភូមិហូបបាយជាមួយស្រីៗនៅក្នុងភូមិវិញ ។ ពេលនោះ ក្រៅពីរូបខ្ញុំ និងយាយចាស់ៗមើលកុមារជាងដប់នាក់ មានតែមនុស្សម្នាក់ទៀតប៉ុណ្ណោះនៅធ្វើការក្នុងភូមិនោះទាំងព្រឹកល្ងាច ។

## អ្នកទោសអន្តការ

រៀងរាល់ពេលព្រឹក ខ្ញុំពុះឫស្សីនៅខាងក្រោយរោងបាយរួម ដែលមានទីតាំងស្ថិតនៅជាប់ផ្លូវឆ្ពោះទៅកាន់មន្ទីរសន្តិសុខ ។ នៅពេល មីងៗ និងតាៗចេញពីភូមិទៅដកស្ទូង និងទៅភ្ជួររាស់ នៅវេលាម៉ោងដប់ព្រឹក ខ្ញុំឃើញកងឈ្លបក្មេងៗដែលមានអាយុស្របាលខ្ញុំជិះសេះចេញពីមន្ទីរសន្តិសុខ ដោយមានសម្លៀកបំពាក់ជាយោធាខ្មែរក្រហម និងមានចងក្រវ៉ាត់ក្រមាជាប់ចង្កេះសម្រាប់សៀតដាវ និងមានស្ពាយកាំភ្លើងសេកាសេ ដូចដែលខ្ញុំធ្លាប់ឃើញនៅក្រុងភ្នំពេញកាលពីថ្ងៃទី១៧មេសា ។ កុមារឈ្លបនោះមានច្រើនក្រុម ដោយមួយក្រុមៗមានគ្នាពីរបីនាក់ ជិះសេះកាត់តាមភូមិ ហើយប្រហែលជាពីរម៉ោងក្រោយមកឈ្លបទាំងនោះក៏ត្រឡប់មកមន្ទីរសន្តិសុខវិញ ដោយមានអ្នកទោស (ភាគច្រើនជាប្រជាជន ១៧មេសា) ជាប់ចំណងរត់តាមពីក្រោយសេះមកជាមួយ ។ មានថ្ងៃខ្លះ ខ្ញុំឃើញអ្នកទោសដែលជាយុវជន និងវ័យកណ្តាលដែលរត់មិនទាន់សេះ ត្រូវបានសេះអូសប្រផាប់ប្រផិល និងមានឈាមហូរចេញពីដងខ្លួនទៀត ។ ខ្ញុំមិនដឹងថាខ្មែរក្រហមក្មេងៗទាំងអស់នោះជាយោធា ឬសន្តិសុខទេ ហើយក៏មិនដឹងថាអ្នកទោសមានកំហុសអ្វីដែរ ប៉ុន្តែខ្ញុំមិនដែលឃើញគេចាប់មនុស្សក្នុងភូមិដែលខ្ញុំរស់នៅទេ ។ នៅក្នុងភូមិនេះ មិនដែលមាននរណាម្នាក់ហ៊ាននិយាយពីរឿងនេះទេ គឺម្នាក់ៗប្រឹងតែពីបំពេញភារកិច្ចរៀងៗខ្លួន ។

## អ្នកមានគុណទីពីរ

មួយរយៈបន្ទាប់ពីខ្ញុំចេញពីមន្ទីរពេទ្យ សុខភាពរបស់ខ្ញុំចាប់ផ្តើមប្រសើរឡើងវិញ ព្រោះជារដូវប្រមូលផល និងជាពេលដែលអង្គការផ្លាស់ប្តូរប្រធានភូមិ ។ នៅពេលនោះ ខ្ញុំសង្កេតឃើញថា របបនោះប្រហែលជាផ្លាស់ប្តូរភូមិក្នុងមួយឆ្នាំម្តង ។ ប្រធានភូមិចាស់ឈ្មោះ ឌីវ ត្រូវបានអង្គការប្តូរចេញ ហើយដាក់ប្រធានភូមិថ្មីឈ្មោះ អឿន មកជំនួសវិញ ។ អឿន ជាមនុស្សវ័យកណ្តាល គាត់មានទឹកមុខកាច និងច្បាស់លាស់ជាមួយអង្គការខ្លាំងណាស់ សូម្បីតែប្រជាជនមូលដ្ឋានក៏ខ្លាចគាត់ដែរ ។ អឿន មានបុកពារមើលទៅហាក់ដូចជាកម្មាភិបាលថ្នាក់លើ ហើយគាត់បានដាក់ការងារឲ្យខ្ញុំធ្វើ ដូចជា កាប់ព្រៃ លើកភ្លឺ បើកបិទទឹកស្រែ ភ្ជួរ និងជម្រះស្មៅស្រែ ចំណែកពូៗ និងមីងៗ ក៏ត្រូវធ្វើតាមមុខសញ្ញារៀងៗខ្លួនរបស់គាត់ដែរ ។

ខណៈនោះ ខ្ញុំមានម្តាយធម៌ម្នាក់ឈ្មោះ យេន ជាអ្នកមូលដ្ឋានចាស់ និងជាប្រធានរោងបាយ ហើយប្តីគាត់ឈ្មោះ ជន ជាយោធា ។ គាត់ទាំងពីរនាក់ជាអ្នកស្រុកតាកែវ ប៉ុន្តែគ្រួសារគាត់ត្រូវអង្គការចាត់តាំងឲ្យមកធ្វើការនៅខេត្តពោធិ៍សាត់ ។ ពូ ជន ខ្វាក់ភ្នែកម្ខាង ហើយស្ទើរតែរៀងរាល់ថ្ងៃគាត់បានជិះសេះត្រឡប់មកផ្ទះវិញ ។ គាត់មានកូនបីនាក់ ស្រីពីរ ប្រុសមួយ ។ កូនរបស់គាត់នៅតូចៗនៅឡើយ កូនស្រីច្បងមានអាយុប្រហែលជាដប់ពីរឆ្នាំនៅឃ្វាលសេះ ហើយស្ទើរតែរៀងរាល់ពេលត្រូវសេះធាក់សន្ទប់ធ្វើឲ្យគេខ្លាចសេះរហូត ឃើញដូច្នេះ ពូជន ក៏ប្រើឲ្យខ្ញុំទៅជួយឃ្វាលសេះនោះ ។ ខ្ញុំខិតខំថែសេះនោះ ដោយឲ្យទឹកនិងរកស្មៅឲ្យវា និងបានផ្សាំវារហូតស្គាល់ខ្ញុំច្បាស់ ហើយវាមិនដែលធាក់ខ្ញុំទេ ។ ក្រោយមក ពូជន និងមីង ប្រើខ្ញុំធ្វើការងារផ្ទះរបស់គាត់ទៀត ព្រោះកាលដែលខ្ញុំនៅបិទដងកណ្តប ពុះឫស្សីនៅជិតផ្ទះគាត់ គាត់តែងតែផ្តល់អាហារឲ្យខ្ញុំ និងប្អូនស្រីខ្ញុំហូប ព្រោះផ្ទះរបស់គាត់មានចំណីអាហារមិនខ្វះឡើយ ហើយក្រោយមកគាត់ក៏បានជួយជីវិតខ្ញុំរួចផុតពីការចាប់ខ្លួនទៀត ។ ក្រោយថ្ងៃដែលរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចូលមករំដោះខេត្តពោធិ៍សាត់នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៩ ខ្ញុំមិនដឹងថាគ្រួសារគាត់រស់នៅទីណា ស្លាប់ឬរស់ទេ ។

នៅចុងឆ្នាំ១៩៧៧ ឈានចូលដើមឆ្នាំ១៩៧៨ អង្គការបានធ្វើមហាសន្និបាតបក្ស ដោយប្រជាជនទូទាំងស្រុកភ្នំក្រវាញ ទាំងប្រជាជនចាស់ទាំងប្រជាជនថ្មី ត្រូវមកចូលរួមក្នុងពិធីនេះធ្វើនៅជិតមន្ទីរពេទ្យឃុំលាជ ។ មហាសន្និបាតនេះធ្វើមួយថ្ងៃពេញ ចំណែកអាហារអង្គការយកមកចែកឲ្យហូបគ្រប់គ្នា ។ ក្រោយពីមហាសន្និបាតនេះចប់បានមួយរយៈ អង្គការបានផ្លាស់ប្តូរការងារខ្ញុំទៅធ្វើស្រែវិញ ចំណែកមីង យេន ជាប្រធានរោងបាយការដ្ឋានរួម ក៏ត្រូវផ្លាស់ចេញដែរ គឺគាត់ទៅធ្វើជាប្រធាននារីភូមិលាជ ។ ខ្ញុំត្រូវធ្វើការងារចម្រុះមិនដូចចាស់ៗទេ គឺអាស្រ័យតែប្រធានភូមិប្រើ ដូចជាកាប់ព្រៃតាមភ្លឺស្រែ លើកភ្លឺទប់ស្រែ រាស់ស្មៅស្រែ ឃ្វាលក្របី ។ ចំណែកចាស់ៗធ្វើការងារទៅតាមមុខសញ្ញាច្បាស់លាស់ដូចជាត្រូវធ្វើស្រែមួយឆ្នាំបីដង ប៉ុន្តែមិនមានថ្ងៃសម្រាកទេ លើកលែងថ្ងៃមហាសន្និបាតបក្ស ។

ថ្ងៃមួយ នៅវេលាជិតម៉ោងបាយថ្ងៃត្រង់ ក្រោយពីចាស់ៗភ្ជួរស្រែរួច ខ្ញុំក៏ទៅយកក្របីពីពូម្នាក់ដើម្បីរាស់យកស្មៅចេញ គាត់ក៏ដោះនង្គ័លចេញរួចប្តូរដាក់រនាស់ដែលមានប្រវែងជាងពីរម៉ែត្រមកឲ្យខ្ញុំវិញ ។ ក្របីមួយនឹមនោះជាក្របីឡើងក វាមានកម្លាំងខ្លាំងណាស់ ប៉ុន្តែវាហត់ព្រោះវាអូសនង្គ័លតាំងពីព្រឹកម្ល៉ោងទៀតវាក្តៅផង ទើបខ្ញុំរាស់បានតែពីបីជុំស្រែ វាលែងស្តាប់បញ្ជា ។ ខ្ញុំខំទាញញាក់ខ្សែឲ្យវាបត់ វាស្ទុះលឿនទៅមុខធ្វើឲ្យខ្ញុំរអិលជើងធ្លាក់ទៅខាងមុខរនាស់ ក្របីបានអូសខ្ញុំក្នុងល្បប់ និងកាត់សន្ទូងដែលទើបស្ទូងថ្មីៗពីស្រែមួយទៅស្រែមួយទៀត រហូតរនាស់កល់នៅលើដីទួល ទើបខ្ញុំអាចក្រោកឡើងបាន ។ ចំណែកក្របីនោះនៅតែបោលបន្តទៅមុខទៀត រហូតម្ចាស់វាមកជួយចាប់ទើបវានៅស្ងៀម ។

ហេតុការណ៍នេះបានធ្វើឲ្យខូចសន្ទូងអស់ជាច្រើនស្រែ ។ ប្រធានភូមិឈ្មោះ អឿន បានមកស្តីបន្ទោសខ្ញុំថា មិត្ត “បាក់” (ព្រោះខ្ញុំបាក់ជើង ហើយដើរពាធជើងម្ខាង) ឯងត្រូវទទួលខុសត្រូវរាល់ការខូចខាតសន្ទូង ។ និយាយចប់ គាត់បានយកខ្សែអង្រឹងមកចងដៃខ្ញុំទាំងពីរទៅក្រោយ រួចហើយបណ្តើរខ្ញុំទៅរោង បន្ទាប់មកគាត់ក៏ត្រឡប់ទៅវិញបាត់ ។ ខ្ញុំភ័យយ៉ាងខ្លាំង និងនឹកក្នុងចិត្តថាគាត់នឹងយកខ្ញុំទៅវាយចោលហើយ ។ មួយសន្ទុះក្រោយមក ប្រធានភូមិ និងអ្នកភូមិទាំងប្រុសស្រីដែលមានទាំងអ្នកមូលដ្ឋាន និងអ្នកថ្មីមកឈរព័ទ្ធជុំវិញខ្ញុំ ។ ប្រធានភូមិបាននិយាយកសាងខ្ញុំ និងនិយាយទៅកាន់អ្នកភូមិថា ៈ ខ្ញុំត្រូវទទួលខុសត្រូវរាល់ការខូចខាតសន្ទូងដូច្នេះត្រូវយករូបខ្ញុំទៅធ្វើជីដាក់ស្រែវិញ ។ ពេលឮពាក្យនេះ គ្មាននរណាម្នាក់ហ៊ានបញ្ចេញមតិឡើយ ក្នុងចំណោមអ្នកថ្មីទាំងអស់ ។

បន្ទាប់មក អឿន បានលើកខ្ញុំឲ្យក្រោកឈរ បម្រុងនឹងបណ្តើរចេញទៅ ស្រាប់តែមីង យេន ប្រាប់ឲ្យអ្នកមូលដ្ឋានជិតាស់ដោយលើកឡើងថាខ្ញុំជាកុមារ ថែមទាំងពិការទៀត អង្គការមិនគួរយកកុមារមកធ្វើស្រែជាមួយចាស់ទេ ។ ក្មេងនេះគ្មានចេតនាធ្វើឲ្យខូចសន្ទូងទេ ហើយថែមទាំងរនាស់រាស់ដាច់រលាត់ឈាម ។ មីង យេន និងអ្នកមូលដ្ឋានធានាខ្ញុំ ទើបប្រធានភូមិស្រាយចំណងដោះលែងខ្ញុំ ។ នៅរសៀលថ្ងៃដដែល ប្រធានភូមិមិនឲ្យខ្ញុំទៅធ្វើការទេ

គឺឲ្យខ្ញុំសម្រាកមួយល្ងាចដោយសារខ្ញុំមានរបួស ប៉ុន្តែគាត់មិនបានចែករបបឲ្យទេ ។

### ហេតុការណ៍ថៃផន្ស

ពេលនោះ ឆ្លៀតកាសទំនេរ ខ្ញុំបានចូលទៅក្នុងភូមិដើម្បីទៅសួរសុខទុក្ខមីង យេន ប៉ុន្តែមិនបានទាន់ជួបផង ក៏ស្រាប់តែជួបហេតុការណ៍មួយ គឺខ្មែរក្រហមចាប់នារី ១៧មេសា មានអាយុ ២០ឆ្នាំ សម្បុរស រូបរាងស្អាត និងខ្លួនប្រាណស្រាតនលគោក ចងឆ្កាងដូចរូបព្រះយេស៊ូដាក់លើរទេះក្របី ដោតដើមឫស្សីពីងពង់ដោតពីប្រឡោះជើងធ្លាយរហូតដល់មាត់ ។ ខ្ញុំឃើញឈាមនៅស្រស់ៗហូរចេញពីមាត់ស្រោចដោតពេញខ្លួន និងដោតដើមឫស្សីដែលគេចងភ្ជាប់ទៅនឹងរទេះ ។ ខ្មែរក្រហមបានដង្ហែសាកសពនារីនោះ ពីដើមភូមិរហូតដល់ចុងភូមិ ហើយថែមទាំងស្រែកប្រកូកប្រកាសថា "មិត្តនារីម្នាក់នេះខុសសីលធម៌ហ៊ានលួចលាក់ស្នេហាជាមួយប្រុសឈ្មោលដោយមិនមានការអនុញ្ញាតពីអង្គការ" ។ មិនមានអ្នកភូមិណាដឹងថា ប្រុសសាហាយនោះជានរណាទេ ព្រោះគេមិនបានប្រកាសឈ្មោះ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថានារីនោះមានប្រុសៗនៅមូលដ្ឋានស្រឡាញ់ច្រើននាក់ ។

ក្រោយមក ពេលខ្ញុំទៅឃ្វាលក្របីនៅក្បែរអង្គភាពយុវនារីកងចល័ត (ស្ថិតនៅជិតទំនប់ដំណាក់ឈើក្រម) ខ្ញុំបានឃើញអង្គការរៀបការឲ្យកងចល័ត ដោយឲ្យយុវជនឈរមួយជួរ និងនារីឈរមួយជួរ និងមេកងអង្គុយនៅលើតុចំកណ្តាល រួចហើយហៅឈ្មោះយុវជននិងយុវនារីដែលកត់ក្នុងសៀវភៅឲ្យមកឈរទន្ទឹមគ្នាម្តងមួយគូៗ ដែលសរុបទាំងអស់ជាង១០គូ ។ បន្ទាប់មកគណអធិបតីបង្គាប់ឲ្យប្តីប្រពន្ធថ្មីថ្មោងទាំងនោះចាប់ដៃគ្នាឡើងនិយាយប្តេជ្ញាជូនអង្គការម្នាក់ម្តង ចំណែកយុវជននិងយុវនារីផ្សេងៗទៀតដែលមិនទាន់រៀបការ ត្រូវអង្គុយផ្ទាល់ដីតាមជួរតាមក្រុមដើម្បីអបអរសាទរ ។

ខ្ញុំមិនបានដឹងថាពួកយុវជនយុវនារីទាំងនោះបានស្រឡាញ់គ្នា ឬមានការព្រមព្រៀងគ្នាឬយ៉ាងណានោះ ប៉ុន្តែខ្ញុំសង្កេតឃើញថាមានយុវជននិងយុវនារីមិនសូវរីករាយ និងក្រេកអរក្នុងពិធីនេះទេ ។

### គុកឥតជញ្ជាំង

ពេលចេញទៅឃ្វាលក្របីម្តងៗ ខ្ញុំបានដាក់បាយស្នុកទៅតាមរហូតដល់ពេលរសៀល ទើបខ្ញុំកៀងក្របីមកក្បែរក្រោលវិញ ហើយខ្ញុំតែងតែផ្លាស់កន្លែងឃ្វាលជារឿយៗ ។ ថ្ងៃមួយ ខ្ញុំបានទៅឃ្វាលក្របីនៅមុំផ្ទះគំរូដែលសង់ជាពីរជួរអមសងខាងផ្លូវដីក្រហមស្ថិតនៅក្នុងឃុំលាជ ពេលនោះខ្ញុំឃើញផ្ទះទាំងអស់នោះមានតែស្រីៗដែលមានផ្ទៃពោះនៅម្នាក់ៗឯងប៉ុណ្ណោះ ។ ចំណែកផ្ទះខ្លះខ្ញុំ ឃើញមានកូនខ្ចី ប៉ុន្តែមិនឃើញមានប្រុសនៅជាមួយទេ ។ ខណៈនោះ មានស្ត្រីកូនខ្ចីម្នាក់ស្រែកហៅខ្ញុំឲ្យជួយគាត់ ដោយគាត់ប្រាប់ថាប្តីគាត់ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើការឆ្ងាយ ហើយអង្គការទើបតែឲ្យគាត់មករស់នៅទីនេះ ដោយបើករបបអង្ករ ត្រីងៀត និងបន្លែសម្រាប់ឲ្យគាត់ហូបមួយសប្តាហ៍ ។ គាត់មិនដឹងថា ថ្ងៃណាអង្គការអនុញ្ញាតឲ្យប្តីមកវិញទេ ហើយអង្គការក៏បានមិនអនុញ្ញាតដើរឆ្លងទៅផ្ទះផ្សេងទៀតដែរ ភារកិច្ចរបស់គាត់គឺមើលថែទាំកូនរបស់អង្គការទាំងនេះឲ្យធំធាត់ ។

### ក្របីជួយ

ជាច្រើនថ្ងៃក្រោយមក ដោយខ្លាចក្របីដើរស៊ីប៉ះលើសន្ទូង ខ្ញុំក៏ប្តូរទៅឃ្វាលនៅក្បែរមាត់ស្ទឹង តំបន់បាក់ត្រកួន ដែលមានទីតាំងខាងជើងស្ទឹងជាប់នឹងស្រុកមោងវិញ ។ ទីនោះសម្បូរព្រៃលាស់ ក្របីអាចដើរស៊ីតាមចិត្ត ប៉ុន្តែមានថ្ងៃមួយខ្ញុំប្រហែសបណ្តោយឲ្យក្របីឆ្លងទៅម្ខាងស្ទឹងទាំងអស់ ។ ខ្ញុំខ្លាចហ្វូងក្របីទៅឆ្ងាយ ខ្ញុំក៏ហែលឆ្លងស្ទឹងទៅកៀងត្រឡប់មកវិញ ។

ខ្ញុំហែលដល់ពាក់កណ្តាលស្ទឹង ក៏ទន់ដៃជើងហែលលែងចង់ទៅមុខ ដោយសារពេលនោះជារដូវទឹកឡើងខ្លាំង ។ ខ្ញុំហែលត្រឡប់មកវិញស្រាប់តែជើងរបស់ខ្ញុំរមួលក្រពើ ខ្ញុំនឹកក្នុងចិត្តថាខ្ញុំច្បាស់ជាត្រូវលង់ទឹកស្លាប់ជាមិនខាន ហើយក៏ស្រែកហៅរកមនុស្សជួយ តែគ្មាននរណាម្នាក់ឮសោះ ។ ខ្ញុំខំប្រឹងប្រវេប្រវាស្រែកជាលើកចុងក្រោយ ។ ភ្លាមនោះក្របីមេមួយក្បាលបានបកក្រោយវិញ ខ្ញុំក៏ហក់ទៅតោងស្នែងរបស់វា ។ ខ្ញុំបានតោងស្នែងក្របីជាប់រហូតដល់ទឹករាក់ រួចក៏ដេកលើឆ្នេរខ្សាច់មាត់ស្ទឹងដោយសារហត់ហេវអស់កម្លាំង ។

**(នៅមានត)**

ឡៃ ហួត

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល : truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ : ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ : ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ : រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ : លេខទូរស័ព្ទ អាសយដ្ឋាន) ។




***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ : រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 143, November 2011 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.